OLD VERSION

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-May-2015, 15:36
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៨០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*
ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង
កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត
លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ឯក ហឿន (2-TCW-822) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឯក ហឿន ហៅ អ៊ុល ហឿន** (2-TCW-822)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន ផ្ដើមពី ..........ទំព័រ ៣
សួរដោយលោក លីវ សុវណ្ណា ផ្ដើមពី ..........ទំព័រ ៩
សួរដោយលោក គង់ សំអុន ផ្ដើមពី ..........ទំព័រ ៣៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើអង្គសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ឯក ហឿន តាមរយៈប្រព័ន្ធសោតទស្សន៍។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សី ដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺ លោក ឯក ហឿន តាមរយៈប្រព័ន្ធសោតទស្សន៍។ តាមការបញ្ជាក់ពីផ្នែកសោតទស្សន៍ បានជូនដំណឹងមកថា ការរៀបចំបច្ចេកទេសសម្រាប់ការស្តាប់សក្ខីកម្មនៅពេលនេះបានរៀបចំរួចរាល់។ រីឯសាក្សីបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្តល់សក្ខីកម្មនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនចាប់ចោទ នួន ជា ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិ និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះ

ពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់ក្ដីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលាលើសវនាការលើរូបខ្លួនឡើយ។

[០៩:០៥:៥៨]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា ថ្ងៃនេះ មានអាការៈវិលមុខ ឈឺចង្កេះរ៉ាំរ៉ៃ ហើយនិងឈឺខ្លាំងពេលអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ .វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៦:០៦]

សួស្ដី លោក ឯក ហឿន!

**លោក ឯក ហឿន៖**

បាទ សួស្ដីលោក។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ យើងចាប់បន្តធ្វើសវនាការ ស្ដាប់សក្ខីកម្មរបស់លោកជាបន្តទៀត។

តើលោកត្រៀមខ្លួនរួចហើយឬនៅ?

**លោក ឯក ហឿន៖**

បាទ ត្រៀមរួចហើយ។

**ប្រធានអង្គជំនុំ៖**

អស់លោកចៅក្រម តើលោកមានសំណួរអ្វីសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អរគុណលោកប្រធាន។ ជម្រាបសួរលោក ឯក ហឿន ខ្ញុំមានសំណួរមួយចំនួន សួរដល់លោក។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជាដំបូង ខ្ញុំចង់សួរលោកថា នៅពេលដែលលោកកាន់តំណែងនៅស្រុកត្រាំកក់នោះ លោកបាន តើលោកបានឃើញ ឬក៏បានឮគេនិយាយអំពីទស្សនកិច្ចរបស់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងស្រុកត្រាំកក់ហ្នឹង ឬក៏ជាពិសេសហ្នឹង គឺនៅសហករណ៍លាយបូរដែលជាសហករណ៍គំរូ។ តើលោកធ្លាប់ឮគេនិយាយអំពីការធ្វើទស្សនកិច្ចនេះរបស់មេដឹកនាំខ្មែរក្រហមដែរឬទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ កន្លែងហ្នឹងអត់បានដឹងទេ កន្លែងហ្នឹងវា គេអត់ឲ្យដឹង អត់ដឹងដែរហ្នឹង។ ខ្ញុំមិនដែលធ្វើអ្នកទទួលខុសត្រូវនៅក្នុងអង្គភាពស្រុកទេ ជាមហាជន ជាកម្មករសុទ្ធសាធ បើលោកចង់ដឹងខ្ញុំធ្វើអីៗសូមលោក សួរ តាជឹម។ តាជឹម ហ្នឹងគាត់អ្នក ជាអនុស្រុកហើយ។

[០៩:០៨:២១]

**ស៖** តើលោកធ្លាប់ឮអំពីមន្ទីរមួយដែលគេហៅថា មន្ទីរ៨៧០ ដែរឬទេ? ប្រសិនបើលោកធ្លាប់ឮ តើលោកដឹងទេថា មន្ទីរ៨៧០ ហ្នឹងគេ-- គឺជាមន្ទីរអ្វីដែរ?

**ឆ៖** បាទ អត់ដែលបានដឹងទេ អាមន្ទីរ៨៧០ ហ្នឹងអត់ដឹង តែខ្ញុំនៅកម្មករជក់ ខ្ញុំទៅរកក្រដាសជក់ ទៅយកអាក្រោមកញ្ចែគេមើលហើយ គេដាក់ក្នុងកញ្ចែគេហ្នឹង យកក្រដាសជក់ ពេលនោះ តាជឹមនៅអង្គុយសរសេរលើតុហ្នឹង។ គាត់ថា “ជក់ៗទៅកុំមើល”។ ដល់ថាអ៊ីចឹង ខ្ញុំពិនិត្យ ពិនិត្យទៅឃើញគេសរសេរថា ក្នុងក្រដាសហ្នឹងគេសរសេរថា “សូមមិត្តបោសសម្អាតខ្មាំងឲ្យអស់ជាបន្ទាន់នៅតាមសហករណ៍សហជីព ខ្មាំងនៅច្រើនណាស់។ ហត្ថលេខា សមមិត្ត ឃាង អ្នកមន្ទីរ៨៧០ ធ្វើនៅខែ១០” ឃើញប៉ុណ្ណឹង។ ហើយខ្ញុំថា ខ្លួនឯងហ្នឹងវាមើលអក្សរមិនច្បាស់ យកមកសួរស្មៀន។ សួរស្មៀនថា ឯងមើលទៅស៊ីញ៉េនេះរួចទេ? អាស្មៀនហ្នឹងថ្នាក់ទី១២ មកធ្វើស្មៀន តាជឹម ហ្នឹង។ គេថា “អូ! អាហ្នឹងហើយ

ស៊ីញេ សមមិត្តយាង" ហើយខ្ញុំក៏អានថាសមមិត្តយាង អ៊ីចឹងដែរ។ យកទៅសួរគេ គេថា សមមិត្តយាងដែរ។ ប៉ុនក្នុងមន្ទីរ៨៧០ អត់មានឈ្មោះសមមិត្ត យាង ទេ។ មិនដឹងសំបុត្រអនាមិកពីណា គេសរសេរយកដាក់ធុងសំរាមហ្នឹង។

[០៩:១០:២២]

**ស៖** តើលិខិតហ្នឹងគឺជាសារទូរលេខដែលជាសារទូរលេខចុះហត្ថលេខាដោយផ្ទាល់ដៃដោយសមមិត្ត គឹម -- ឃិន -- យាង អ៊ីចឹងមែនទេ?

**ឆ៖** បាទ យកទៅសួរគេ គេថាស៊ីញេហ្នឹងសមមិត្ត យាង។ គេបញ្ជាក់ប្រាប់ខ្ញុំអ៊ីចឹង ហើយខ្ញុំក៏មើលថា សមមិត្ត យាង ដូចគេដែរ។ ប៉ុនដឹង យាង ហ្នឹងគេនៅឯណា អត់ដែលឮឈ្មោះ។

**ស៖** តើលិខិតហ្នឹងមានខ្លឹមសារយ៉ាងដូចម្ដេចដែរ? តើលិខិតហ្នឹងមានការបង្គាប់បញ្ជា ឬក៏ការណែនាំអ្វីខ្លះដែរ?

**ឆ៖** បាទ អត់ គេនិយាយតែប៉ុនដូចខ្ញុំលើកឡើងអម្បាញ់មិញហ្នឹងអ៊ីចឹង។

**ស៖** តើលោកអាចបញ្ជាក់មួយសាទៀតបានទេដើម្បីឲ្យយើងដឹងច្បាស់ ហើយថាតើការបង្គាប់បញ្ជា ឬក៏ការណែនាំនេះត្រូវបានគេអនុវត្ត ឬត្រូវបានគេធ្វើតាមដែរឬទេ នៅពេលដែលគេបានផ្ញើលិខិតហើយបានទទួលលិខិតនោះ?

**ឆ៖** បាទ កន្លែងលិខិតហ្នឹងគេសរសេរថា ឃើញនៅក្នុងកញ្ចេរទៅ ខ្ញុំរើសយកមកជក់។ តាជឹមថា "មិត្តជក់ៗទៅកុំមើល"។ ដល់ថាអ៊ីចឹង ខ្ញុំស្រវាពិនិត្យ ពិនិត្យទៅឃើញគេសរសេរថា "សុំមិត្តបោសសម្អាតខ្មាំងឲ្យអស់ជាបន្ទាន់ ខ្មាំងនៅតាមសហករណ៍ សហជីព ច្រើនណាស់, ហត្ថលេខា សមមិត្ត យាង, គណៈមន្ទីរ៨៧០ ផ្ញើនៅខែ១០" ខ្ញុំមើលឃើញតែប៉ុណ្ណឹង។ ហើយអត់ទាន់បានរៀបចំតាមផែនការទេ។ ចូលថ្ងៃ១២ ម៉ោងប្រាំកន្លះ គឺយួនចូលដល់ជប់ហើយ នាំគ្នារត់ចោលទីតាំងរហូតទៅ អត់មានធ្វើតាមផែនការហ្នឹងទេ។

[០៩:១៣:០៥]

**ស៖** ខ្ញុំមិនប្រាកដថា ខ្ញុំបានយល់ទៅលើអ្វីដែលលោកកំពុងតែនិយាយប្រាប់ ព្រោះថាលោកហាក់ដូចជានិយាយអំពីខែតុលា ប៉ុន្តែប្រសិនបើខ្ញុំគិតអំពីពេលដែលលោកមកដល់ជប់ គឺនៅខែតុលា ឆ្នាំ៧៨។ ប៉ុន្តែលោកនិយាយ ឥឡូវហ្នឹង និយាយថានៅថ្ងៃទី១២ ខែតុលា ដដែលហ្នឹង វៀតណាមមកដល់ជប់វិញ។ តើលោកចង់និយាយអំពីថ្ងៃ១២តុលា ឆ្នាំ៧៨ មែនទេ? ហើយលោកចង់បញ្ជាក់ថានៅថ្ងៃ១២ តុលា ៧៨

ហ្នឹងវៀតណាមមកដល់ជប់។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលនោះគេធ្វើសារាចរហ្នឹងគឺឃើញនៅខែ១០ ហើយខ្ញុំទៅដល់ជប់ ទៅពីស្រុកទៅដល់ជប់ហ្នឹង ៧៨ ខែ៨ ថ្ងៃ០៨ ហើយដល់តែទៅបាន ចូលខែ១០ ឃើញសារាចរហ្នឹងៗ ហើយរហូតមកដល់ខែ១២ ម៉ោងប្រាំកន្លះល្ងាច ខែ១២ ថ្ងៃ៣១។ ថ្ងៃ៣១ហ្នឹង ម៉ោងប្រាំកន្លះល្ងាច គឺយួនចូលបាញ់ដល់ចាត់ការជប់ហ្នឹងហើយ។ ដល់បាញ់ចាត់ការជប់នាំគ្នារត់ចូលទីតាំងរហូតមកទល់សព្វថ្ងៃនេះមក។ បើខ្ញុំវាមិនចាំថ្ងៃខែហ្នឹងច្បាស់ហ្នឹង។ ដឹងថ្ងៃរត់ហ្នឹង ថ្ងៃចាំច្បាស់ហើយ ថ្ងៃ៣១ ខែ១២ ម៉ោងប្រាំកន្លះល្ងាច រត់ចោលទីតាំងទាំងអស់គ្នា។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំនឹងពិភាក្សាអំពីប្រធានបទថ្មី លោកបានផ្តល់ចម្លើយជាមួយអ្នកស៊ើបអង្កេត ជាមួយសហចៅក្រមស៊ើបអង្កេត លោកបាននិយាយអំពីហេតុការណ៍មួយ ប្រហែលជាមិនជាការសមស្របប៉ុន្មានទេ ប៉ុន្តែលោកនិយាយអំពីខ្មែរ៩០នាក់ ដែលត្រូវបានគេសម្លាប់។ នេះគឺជាប្រជាជនខ្មែរនៅខាងវៀតណាម ហើយត្រូវបានគេចាត់តាំងឲ្យទៅធ្វើការនៅខ្ពបត្របែក – នៅការដ្ឋានខ្ពបត្របែក។ ហើយការងារនៅខ្ពបត្របែកហ្នឹង គឺលោកនិយាយថាជីកទំនប់ ជីកប្រឡាយ។ ហើយលោកបានបញ្ជាក់ថា តាម៉ុក គាត់ខឹងនឹង ពេជ្រ ជឹម ដោយសារតែ ពេជ្រ ជឹម បញ្ជាឲ្យសម្លាប់ខ្មែរទាំង៩០នុ៎ង។ តើលោកអាចរៀបរាប់ឲ្យបានលម្អិតបន្តិចបានទេអំពីការសម្លាប់ប្រជាជនខ្មែរ ៩០នាក់ហ្នឹង? ហើយតើលោកចាំទេថា ហេតុការណ៍ហ្នឹងកើតឡើងនៅពេលណាដែរ? សូមលោកជួយបញ្ជាក់។

[០៩:១៦:៣០]

**ឆ៖** ខ្ញុំវាមិនអត់ចាំថ្ងៃខែច្បាស់ទេ ការលើកទំនប់ហ្នឹងមិនទាន់រំដោះប្រទេស មុនរំដោះប្រទេស។ ឆ្នាំ៧៤ គឺទប់ទំនប់ខ្ពបត្របែកហ្នឹង គឺទប់ទំនប់ទាំងអស់គ្នានៅក្នុងមួយខេត្តហ្នឹង មានទាំងលោកសង្ឃ មានទាំងចិន យួន ចាម ជ្វាអីទៅទប់ទាំងអស់គ្នា។ ហើយពេលនោះ តាម៉ុក យកកម្លាំងជនជាតិវៀត-ណាមនៅក្នុងប្រទេសកម្ពុជា នៅក្នុងស្រុកត្រាំកក់ហ្នឹងយកទៅដូរខ្មែរនៅស្រុកយួន។ ដូរខ្មែរនៅស្រុកយួនបានមក យកមកប្រគល់ឲ្យ តាជឹម នៅជីកប្រឡាយខ្ពបត្របែកហ្នឹងទៅត្បូង។ ដល់ តាម៉ុក ប្រគល់ឲ្យ២០០នាក់ឲ្យ តាជឹម – តាជឹមគាត់ថា យប់ឡើងរវល់តែដើរលួចចានឆ្នាំងបោះដាក់ទឹកបោះដាក់ត្រពាំង អ៊ីចឹងឲ្យគេយក៩០នាក់ហ្នឹងទៅសម្លាប់ចោលរណ្តៅអាបេខាងលិចទៅលើប្រឡាយហ្នឹង ហៅថាជើងភ្នំដំរីរមៀលហ្នឹង។ សម្លាប់អស់។ ដល់ពេល តាម៉ុក ទៅសួរថា "ចុះឯណាមនុស្ស៩០នាក់ដែលអញយកមកឲ្យហ្អែង? ថាអ្ហ៎! ខូចពេកសម្លាប់ចោលអស់ហើយ។ យី! ហ្អែងសម្លាប់គេ ហ្អែងហ្នឹងអ្នករកមនុស្ស

បាន? អញតើអ្នកទៅរកមនុស្សមកឲ្យហ្អែងប្រើ! ហេតុអីបានហ្អែងសម្លាប់គេ?” សម្លុតអ៊ីចឹង តាជឹម អេះអុញៗ ចូលកៀនបាត់ទៅ សម្លាប់គេហើយអស់។ ហ្នឹងខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** យោងតាមអ្វីដែលលោកដឹង ហើយនិងតាមដែលលោកចាំ តើលោកអាចប្រាប់បានទេថាតើ តាជឹម អាចសម្រេចដោយខ្លួនឯងក្នុងការសម្លាប់មនុស្សហ្នឹង ឬមួយក៏គាត់ចាំបាច់ត្រូវមានការអនុញ្ញាតពីថ្នាក់លើដើម្បីសម្លាប់មនុស្សនុំងបាន?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ អត់មានទទួលផែនការពីលើទេ គាត់សម្រេចចិត្តគាត់ ឲ្យគេយកទៅសម្លាប់ចិត្តគាត់ បាន តាម៉ុក គាត់ខឹងហ្នឹង។ សូម្បីតែកូនគាត់ក៏គាត់ប្រមាថកប់ត្រឹមក បររនាស់ដែករាស់ដែរ សម្លាប់គេ។ ហើយដល់ តាជឹម ក៏គាត់កិនដូចកូនគាត់អ៊ីចឹងដែរ។ សម្លាប់គេអត់បានទេ បើ តាម៉ុក ដឹងនោះ។

[០៩:១៩:២២]

**ស៖** ឥឡូវនេះលោកប្រាប់យើងថា តាម៉ុក គាត់ខឹង។ តើគេមានដាក់ទណ្ឌកម្មអីចំពោះ តាជឹម ដែរឬទេ? ព្រោះថា តាជឹម គាត់អត់ធ្វើទៅតាមបញ្ជារបស់ថ្នាក់លើ តើគេមានដាក់ទណ្ឌកម្ម តាជឹម ដែរឬទេ?

**ឆ៖** បាទ សូមជម្រាប្រសាសន៍ ចំណែកទណ្ឌកម្មអីគឺអត់ដាក់ទេ គ្រាន់តែ តាម៉ុក ខឹងចំពោះមុខមហាជនដែលនៅទប់ទំនប់ប្រឡាយហ្នឹង គឺខឹង គឺគាត់ដាច់ក្តិតដាច់ក្បាល ហើយអត់មានទោសពៃរ៍អី គឺរួចខ្លួនរហូតទាល់សព្វថ្ងៃហ្នឹង។

**ស៖** ខ្ញុំក៏ប្រហែលជាចង់ឲ្យយល់អំពីនីតិវិធីដែលថា គេចាត់ទុកថាប្រជាជនខ្មាំង ហើយយកទៅសម្លាប់នោះផងដែរ។ ខ្ញុំប្រហែលជាអាចយល់អំពីអ្វីដែលលោកប្រាប់អំពី ដែលថាថ្នាក់ឃុំឲ្យមានសិទ្ធិអំណាចក្នុងការសម្រេចសម្លាប់មនុស្សទេ គឺមិនអាចសម្លាប់មនុស្សដែលគេចាត់ទុកថាជាខ្មាំងដោយខ្លួនឯងនោះទេ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវដូចការពិតហើយ។

**ស៖** ខ្ញុំចង់ធ្វើការដកស្រង់ឯកសារ E319/8.2.4 គឺនៅសំណួរចម្លើ១៣៤។ គឺថាលោកបាននិយាយអំពីព្រៃខ្មោចកូនក្មេង កន្លែងសម្លាប់នៅព្រៃខ្មោចកូនក្មេង។ តើអ៊ីចឹងមានន័យថាអាហ្នឹងឈ្មោះគេហៅថា “ព្រៃខ្មោចកូនក្មេង” អ៊ីចឹងមែនទេ? ហើយលោកបាននិយាយជាទូទៅអំពីកន្លែងសម្លាប់ នេះគឺជាអ្វីដែលលោកបានបញ្ជាក់។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ដោយសារតែឯកសារមានតែជាភាសា

អង់គ្លេស៖ "កន្លែងសម្លាប់មនុស្សទាំងអស់នោះ ខ្ញុំគិតថាថ្នាក់ឃុំត្រូវចាប់ផ្ដើមសម្លាប់ប្រជាជនថ្មី ដោយសម្ងាត់ដោយខ្លួនឯងផ្ទាល់"។ ឥឡូវនេះ តើលោកចាំដែរ ឬទេថាលោកបាននិយាយអំពីចំណុចនេះ ហើយតើលោកមានន័យយ៉ាងម៉េចនៅពេលដែលលោកនិយាយថាថ្នាក់ឃុំលួចសម្លាប់ប្រជាជនថ្មី ដោយខ្លួនឯងនោះ?

[០៩:២២:៥៤]

**ឆ៖** បាទ ថ្នាក់ឃុំអត់មានសិទ្ធិលួចសម្លាប់ទេ ប្រជាជនថ្មីគឺអត់ដែលបាត់ទេក្នុងឃុំត្រពាំងធំ គឺដូចថាមនុស្សណាដែលទំនាស់ជាមួយមេឃុំហ្នឹងគេអាចលួចសម្លាប់បាន។ គេសម្លាប់អត់ឲ្យអង្គការខាងលើៗដឹង គេលួចសម្លាប់ខ្លួនគេហ្នឹងសម្លាប់បាន បើថាឲ្យគេសម្លាប់អ្នកថ្មី អ្នកចាស់ គេអត់ហ៊ានទេគេមានតែរាយការណ៍ឲ្យស្រុកសម្រេច។ ដឹងតែប៉ុណ្ណឹងទេ។

**ស៖** អ៊ីចឹងខ្ញុំអាចនិយាយបានទេថា ក្រៅពីអាព្រៃខ្មោចកូនក្មេងហ្នឹង គឺក្រៅពីកន្លែងសម្លាប់ព្រៃខ្មោចកូនក្មេងដែលលោកបាននិយាយហ្នឹង តើមានកន្លែងសម្លាប់មនុស្សផ្សេងទៀតទេនៅក្នុងឃុំ? ប្រសិនបើមាន តើកន្លែងសម្លាប់ផ្សេងហ្នឹងជាកន្លែងសម្ងាត់ -- សម្លាប់មនុស្សសម្ងាត់ដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍ ចំពោះកន្លែងព្រៃខ្មោចកូនក្មេងហ្នឹង គឺកន្លែងសម្លាប់ចំហ អត់មានឃុំយកទៅដល់ទេ ឆ្ងាយពីឃុំណាស់។ ឃុំសំរោង មកកន្លែងព្រៃខ្មោចកូនក្មេងហ្នឹង វាឆ្ងាយ។ អ៊ីចឹងឃុំត្រពាំងធំខាងត្បូង យកទៅព្រៃខ្មោចកូនក្មេងហ្នឹងក៏ឆ្ងាយ មានតែអង្គការស្រុកទេ ដែលគេប្រមូលមនុស្សពីគ្រប់ទិសទី យកឲ្យអង្គការស្រុកហ្នឹង។ អង្គការស្រុកយកទៅធ្វើអ្វី ខ្ញុំអត់ដឹង អត់ដឹងគេសម្លាប់ឯណាឯណី ប៉ុនអាព្រៃខ្មោចកូនក្មេងហ្នឹង វាមានឈ្មោះពីមុន៧០មក គេកូនក្មេងវាឈឺអុត ឈឺកញ្ជ្រឹលស្លាប់ទៅគេកប់នៅនឹងព្រៃកូនក្មេងហ្នឹង យកកប់នឹងព្រៃខ្មោចហ្នឹង។ ព្រៃខ្មោចហ្នឹងហៅ "ព្រៃស្រមរ" –ព្រៃស្រមរហ្នឹងហៅថា "ព្រៃឡង់" – ព្រៃឡង់ហ្នឹងក្រោមផ្លូវមេព្រៃ។ បាទ សូមជម្រាបខ្លីតែប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមសង្ខេប ឬក៏សាមញ្ញឲ្យសាមញ្ញបន្តិច គឺថាក្រៅពីកន្លែងសម្លាប់មនុស្សនោះ តើមានសម្លាប់មនុស្សផ្សេងទៀតដែរឬទេ? គឺកន្លែងសម្លាប់មនុស្សដែលគេចាត់ទុកថាជាខ្មាំងរបស់សហករណ៍ដែរឬទេ តើមានកន្លែងសម្លាប់មនុស្សផ្សេងទៀតទេ?

**ឆ៖** បាទ ដូចអត់មានទេ ព្រោះតែទំនាស់អីក៏ដោយគឺកងស្រុកត្រូវនាំទៅឲ្យ យាយខុម ហើយតែដល់ផ្ទះ យាយខុម ហើយ យាយខុមនៅខាងជើងព្រៃខ្មោចកូនក្មេងហ្នឹង អត់ដល់២០០ម៉ែត្រផង យាយខុម យកទៅប្រមូលទៅដាក់ព្រៃខ្មោចកូនក្មេងហ្នឹងទាំងអស់ អត់មានកន្លែងសម្ងាត់ក្រៅពីហ្នឹងទេ។

[០៩:២៦:៤៦]

**ស៖** សូមអរគុណ។ អ៊ីចឹងដើម្បីឲ្យច្បាស់ថាខ្ញុំយល់អ្វីដែលលោកនិយាយហ្នឹង តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើមេឃុំអាចៗ -- ថាតើមេឃុំអាចអនុវត្តការសម្លាប់មនុស្សដោយមិនចាំបាច់មានការណែនាំពីថ្នាក់ស្រុកដោយរបៀបណា? ថាតើវាអាចកើតឡើងបានតាមរបៀបណាដែរ លោកអាចប្រាប់ខ្ញុំបានទេ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំអត់បានដែលដឹងរឿងឃុំសម្លាប់ទេ អត់ដែលមានទេ ឃើញតែឃុំហ្នឹង បើថាមានឈ្មោះមនុស្សវាមិនល្អហើយគេរាយការណ៍មកស្រុកហើយ តែស្រុក ដល់តែស្រុកទទួលបានគេឲ្យទ័ពគេតាមស៊ើបតាមអង្កេតច្បាស់ហើយ បានគេឲ្យឃុំហ្នឹងចាប់ -- ឲ្យឃុំហ្នឹងរាយការណ៍មកគេវិញ។ និយាយការណ៍មកគេវិញ គេឃើញហើយ ច្បាស់ហើយបានគេឲ្យកងទ័ពគេទៅចាប់យកទៅឲ្យយាយខុម ហ្នឹង។ ឃុំអត់មានសម្លាប់ខ្លួនឯងទេ បើលួចសម្លាប់ អានោះទាស់ទែងជាមួយប្រពន្ធកូនគេហ្នឹង គេលួចសម្លាប់អត់ឲ្យអង្គការដឹងទេ អាហ្នឹងមានហើយ ឃុំណាក៏មានដែរ លួចសម្លាប់គេអ៊ីចឹង។

[០៩:២៨:២០]

**ស៖** តើប្រជាជនដែលរស់នៅក្នុងស្រុកត្រាំកក់មុនពេលដែលប្រជាជនថ្មីមកដល់ហ្នឹង ថាតើអ្នកទាំងអស់ហ្នឹងគាត់មានអារម្មណ៍ស្អប់ ឬក៏ប្រឆាំង ឬក៏គាត់ធ្វើអី គឺថាតើគាត់មានស្អប់ខ្ពើម ឬក៏ប្រឆាំងជាមួយប្រជាជនមកដល់ថ្មីដែលគេជម្លៀសមកដល់ដែរឬទេ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ការពិតណាស់ អារឿងប្រជាជនចាស់ថ្មីហ្នឹងដាច់ខាត គឺអត់ឲ្យថាគេថ្មី អត់ឲ្យថាគេប្រជាជន១៧មេសា អីក៏អត់ឲ្យថាដែរ រាប់រកគ្នាជាបងប្អូន ហើយខ្មែរក្រហមគឺរាបសាណាស់ត្រង់ហ្នឹង អត់ប៊ានឈ្លោះប្រកែក អត់ប៊ានមើលងាយមើលថោកគេ គឺអាណាប៊ានឈ្លោះគេ អាហ្នឹងគេវាស់ដីឲ្យរែក អាណាប៊ានទាស់គេ រែកដីឲ្យតែឯងហើយ គេអត់ឲ្យរែកជាមួយគ្នាច្រើនទេ ឲ្យរែកតែឯង អាហ្នឹងទាស់គ្នា។ អាហ្នឹងរឿងប្រជាជនចាសថ្មី គឺស្រឡាញ់គ្នាដូចអ្នកចាស់ទាំងអស់ គោរពគ្នាទៅវិញទៅមកទាំងអស់។ ហ្នឹងក្នុងស្រុកត្រាំកក់ ខ្ញុំដើរសុំបន្លែ សុំអីតាមភូមិ ខ្ញុំឃើញទាំងអស់ដូចតែគ្នាទាំងអស់ក្នុងមួយស្រុក។ ប្រជាជនមានសីលធម៌ល្អស្លូតបូតណាស់ ខ្លាចច្បាប់ តែខុសច្បាប់ គេធ្វើបាប រែកដីហាលថ្ងៃ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី។ ខ្ញុំមិនមានសំណួរបន្ថែមទៀតទេ។ សូមអរគុណ។

[០៩:៣០:២៨]

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារ។ ដំបូងនេះ ប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី ឯក ហឿន។ សូមអញ្ជើញបាទ!

**លោក លីវ សុវណ្ណា៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន សូមគោរពលោកចៅក្រម និងអង្គសវនាការ។ ខ្ញុំបាទឈ្មោះ លីវ សុវណ្ណា ជាមេធាវីការពារឲ្យលោក នួន ជា។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ជម្រាបសួរលោក ឯក ហឿន។ ខ្ញុំថ្ងៃនេះក្នុងនាមខ្ញុំបាទឈ្មោះ លីវ សុវណ្ណា ជាមេធាវីការពារក្ដី នួន ជា សូមតាំងសំណួរមួយចំនួនដូចតទៅនេះ។ កាលពីម្សិលមិញម៉ោងប្រហែលជាបីនិងសែសិបប្រាំនាទី លោកបានផ្ដល់សក្ខីកម្មថា មានការប្រជុំដាក់បញ្ជាឲ្យប្រធានភូមិត្រូវខិតខំផ្ដល់ជម្រក និងស្រូវអង្ករដល់ប្រជាជនថ្មី។ តើអង្គប្រជុំនោះធ្វើឡើងនៅពេលណាដែរបាទ?

[០៩:៣១:៣៩]

**លោក ឯក ហឿន៖**

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ រឿងគេប្រជុំដាក់ផែនការ ខ្ញុំបាទអត់បានដឹង អត់បានឃើញ ហើយបើថាផ្ដល់ជំនួយហូបចុកគឺចិនគេដឹកអង្ករពីប្រទេសគេយកមកឲ្យខ្ញុំដាក់អង្ករហ្នឹងចង់ងាប់ហើយ ដាក់ចែកប្រជាជនចាស់ថ្មីហ្នឹង។

**ស៖** ចុះហេតុអីម្សិលមិញ លោកបានមានប្រសាសន៍ថា មានការដាក់ផែនការឲ្យតាមភូមិខិតខំរកជម្រក និងស្រូវអង្ករជួយដល់ប្រជាជនថ្មី។ តើលោកបានព័ត៌មាននេះពីណាមកបាទ?

**ឆ៖** បាទ អាហ្នឹងខ្ញុំអត់បានដឹងទេ ខ្ញុំបាននិយាយ ខ្ញុំចាំ ប៉ុន្តែអត់បាននិយាយ គ្រាន់តែថាឲ្យប្រជាជនហ្នឹងទៅទទួល -- ឲ្យមេឃុំមេភូមិហ្នឹងទៅទទួលកម្លាំងគេជម្លៀសមកនៅចំប៉ាលើកហ្នឹងទទួលយកមកតាមឃុំ។ ឃុំត្រពាំងធំបានប៉ុន្មាន ឃុំសំរោងបានប៉ុន្មាន ឃុំត្រាំកក់បានប៉ុន្មាន ទទួលយកមក ហើយផ្ទះមានស្រាប់ហើយ ផ្ទះគេធ្វើអាផ្ទះក្នុងដីរំដោះហ្នឹង គេឲ្យទៅធ្វើមេឃុំមេភូមិនៅខេត្តក្រៅ ស្រុក

ក្រៅទៅ គឺនៅផ្ទះទំនេរគ្រប់តែផ្ទះហ្នឹង។ គេប្រគល់អាផ្ទះដែលគេចេញចោលហ្នឹងឲ្យអ្នកដែលទៅនៅថ្មីហ្នឹង។ អត់មានពិបាកធ្វើជួសជុលទេ។

**ស៖** ខ្ញុំសូមសួរសំណួរមួយទៀត តាមចម្លើយរបស់លោកនៅក្នុងឯកសារ E305/13.23.451 ត្រង់ ERN ជាភាសាខ្មែរមានលេខ 0096889, អង់គ្លេសលេខ 00050182 លោកបានផ្តល់ចម្លើយនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកបានទៅលើកដាក់លីសែងសម្ភារៈគេដឹកអង្ករ និងស្បៀងមកឲ្យប្រជាជនដែលគេជម្លៀសមកពីភ្នំពេញ។ "ខ្ញុំលីអង្ករតែគ្នាពីរនាក់ តែពីរឡាន ហើយអង្ករ៦០បាវលីចង់ងាប់ លីទាំងយប់លីទាំងថ្ងៃទាំងគ្នាទាំងពីរនាក់"។ ហើយចម្លើយ -- សំណួរមួយទៀត គាត់សួរថា តើអ្នកសួរៗថា៖ តើអង្ករហ្នឹងមកចែកអ្នកថ្មី? លោកបានឆ្លើយថាបាទ។ ហើយកាលពីម្សិលមិញនៅម៉ោងប្រហែលជាបីនិងហាសិបនាទី លោកបានផ្តល់សក្ខីកម្មថា លោកជាអ្នកលីអង្ករ និងសម្ភារៈដែលជំនួយរបស់ចិនសម្រាប់បើកឲ្យប្រជាជនថ្មី ហើយការបើកនេះរហូតដល់ឆ្នាំ៧៦ នៅពេលអស់ជំនួយពីចិន។ អ៊ីចឹងខ្ញុំបាទសូមសួរថា តើពេលណាក្នុងឆ្នាំ៧៦ហ្នឹង នៅពេលណាដែលអស់ជំនួយរបស់ចិនបាទ?

[០៩:៣៤:៣៦]

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍ ពេលអស់ជំនួយចិនចូលដល់៧៥ ដល់៧៦ ខែ១១ គឺចិនលែងផ្តល់អីទៅឲ្យទាំងអស់ហើយ គឺដាច់ហើយ។ ៧៦ ខែៗស្រូវចេញហ្នឹង ខែប៉ុន្មាន ស្រូវចេញ ស្រូវឱនហើយ លែងចិនលែងឲ្យអង្ករឲ្យអីមកហើយ។ ដាច់ត្រឹមហ្នឹងហើយ ចូល៧៦ ខែស្រូវចេញ ស្រូវទុំហ្នឹងចិនលែងឲ្យហើយ ដាច់រហូតហើយ។ មិនដឹងខែប៉ុន្មានទេ អត់ចាំ។

**ស៖** បាទ សូមអរគុណ។ ចុះលោកមានបានដឹងទេថា នៅក្នុងស្រុកត្រាំកក់យើង គេចាប់ផ្តើមរៀបចំហូបរួមហ្នឹងនៅក្នុងខែណា ឆ្នាំណាដែរបាទ?

**ឆ៖** អត់ច្បាស់ៗ សូមអាន។

**ស៖** បាទៗ ខ្ញុំសូមជម្រាបសួរម្តងទៀត។ តើនៅក្នុងស្រុកត្រាំកក់ ការចាប់ផ្តើមហូបបាយរួមគ្នានៅក្នុងសហករណ៍ចាប់ផ្តើមនៅពេលណាឆ្នាំដែរបាទ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ឆ្នាំ៧៣ គឺហូបបាយរួមតាមភូមិ។ ដល់៧៤, ៧៥ ហូបបាយរួមគឺនៅ -- ៧៤, ៧៥ ហ្នឹង គេៗហូបរួមគ្នាទាំងឃុំ។ ក្នុងមួយឃុំហ្នឹងគេហូបជាពីរចង្ក្រាន ហើយដល់តែចូលទៅហូប អត់ហូបគ្រប់គ្រាន់ទេ មានអ្នកដំណើរចូលទៅហូបដែរ ខ្វះរបបអ្នកនៅក្នុងហ្នឹង។ ទៅធ្វើការមកវិញដល់មកវិញដល់ម៉ោង អត់បាយហូបទេ គេឲ្យអ្នកដែលដំណើរទៅសុំហូបហើយអស់

ហើយ។ ហើយដល់ដាំថែម ម៉ោងមួយ ម៉ោងពីរហើយបានទៅធ្វើការរែកដី ហើយដល់អ៊ីចឹងទៅអត់ទាន់គេរិះគន់ ដល់រិះគន់អ្នករែកដី អ្នករែកដីរិះគន់អ្នកដាំថា "មកពីដាំបាយឲ្យខ្ញុំហូបអត់ទាន់ ខ្ញុំចាំហូបដល់ម៉ោងមួយ ម៉ោងពីរ ហើយខ្ញុំទៅរែកដីម៉េចនឹងទាន់គេ"។ ដល់អ៊ីចឹង គេទាស់តែគ្នាហូបរួមហ្នឹងវរល់តែទាស់អុកឡុក។ ដល់តែពេលនោះតាម៉ុកគេចូលទៅដល់រោងបាយ គេថា៖ "អាណាឲ្យហ្អែងហូបបាយៗរួម ហ៊ឹះ! អាណា?" ហើយយាយៗថា៖ "តាឯងហ្នឹងណ៎ា! មកឲ្យគេហូបបាយរួមពិបាកចង់ងាប់" "យី! អញអត់ដឹងទេ" ដល់ថាអ៊ីចឹងតាម៉ុកមកៗកន្លែងហ្នឹង ស្អែកឡើងស្រាប់តែមិនហូបតែប្រាំប្រាំមួយភូមិ ឡើងហូបដល់ដប់ភូមិ ហូបពីរភូមិហូបតែពីចង្ក្រាន អ៎! មួយឃុំហូបពីរចង្ក្រាន។ ដល់អ៊ីចឹងទៅវាដល់ អូ! ហូបអត់គ្រប់គ្រាន់ បាយអត់ ហូបតែអង្ករាវៗ ទឹករាវៗអត់មានសម្លអត់មានកាកអីទេ មានតែបាយ មានតែទឹកហ្នឹង ហើយទៅធ្វើការ ២៤ម៉ោង ទាំងយប់ទាំងថ្ងៃទៀតហ្នឹង។ ខ្ញុំដើរបេះស្លឹកឈើស៊ី ក្អួតចង់ងាប់ ធ្វើហេវចង់ងាប់។

[០៩:៣៧:៣៥]

**ស៖** បាទ តើ -- ខ្ញុំបាទចង់សួរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺ ឆ្នាំ៧៥ ដល់ ៧៩។ តើនៅពេលដែលឆ្នាំ៧៥ បែកភ្នំពេញភ្លាមហ្នឹងស្ថានភាពនៅស្រុកត្រាំកក់ហ្នឹងគេហូបរួម ឬមួយក៏មិនទាន់ហូបរួមនៅឡើយទេ នៅឆ្នាំ៧៥ ហ្នឹង?

**ឆ៖** បាទ តាមហូបរួម--

**ស៖** ឆ្នាំ៧៥ បាទ។

**ឆ៖** កាលហូបបាយរួម -- គេចាប់ផ្ដើមហូបបាយរួមនៅឆ្នាំ៧៣ ខែបីហ្នឹង ច្រូតហើយ គេចាប់ផ្ដើមហូបហើយ ហូបៗតែមួយភូមិៗ មានមួយចង្ក្រានៗហ្នឹង។

**ស៖** ចុះមានដែល -- លោកមានដឹងថានៅក្នុងឆ្នាំណាមួយគេឈប់ហូបរួមគ្នា គេហូបជាឯកជនវិញទេ លោកមានបានដឹងពីព័ត៌មាននេះទេបាទ?

**ឆ៖** បាទ ទាល់ ៧៩ ៗ យួនចូលស្រុកហើយ បែកឆ្នាំងបាយរួមហើយ ខ្ញុំរង់ឡើងភ្នំដងរែកឆ្នាំ ៨០ ខែ៧ ទៅដល់លើភ្នំដងរែកតា សុន សេនហ្នឹង ឲ្យស៊ីបាយរួមរហូត។ ស៊ីបាយរួមរហូតទាល់ៗឆ្នាំ ២០០០ បានលែងស៊ីបាយរួម។ នៅតែហូបឆ្នាំបាយរួមរហូតហ្នឹង។

[០៩:៣៨:៥៤]

**ស៖** ខ្ញុំសូមតាំងសំណួរបន្ត។ តើនៅក្នុងពេលដែលលោកបំពេញភារកិច្ចលី ថាលីអង្ករ ឬក៏ធ្វើការ

នៅៗមន្ទីរពាណិជ្ជកម្មស្រុកត្រាំកក់ ពេលនោះលោកមានដែលឮបទបញ្ជាថ្នាក់លើណាមួយដែលបញ្ជាឲ្យស្រុកត្រូវខិតខំដោះស្រាយជីវភាពប្រជាជនដែរឬទេ?

**ឆ៖** បាទ អាត្រង់ហ្នឹងអត់ដែលបានដឹង អត់ដែលបានឮគេនិយាយថាយ៉ាងម៉េចទេ ឃើញតែដល់យប់ចែកយប់ ដល់ថ្ងៃចែកថ្ងៃ។ អត់ដែលឃើញឮសួរណែនាំថាយ៉ាងម៉េច។ បើ តាម៉ុក ឲ្យអីមក តាម៉ុក ថា៖ "អញយកទៅចែកឲ្យប្រជាជន។ ទៅដល់យប់អញចែកយប់ ទៅដល់ថ្ងៃអញចែកថ្ងៃ មិនមែនយកទៅទុកឃ្លាំងហ្អែងទេ"។ ដល់តែចែកទៅៗដល់ភូមិត្រពាំងធំគេយកដាក់ឃ្លាំង អត់ចែក ដល់អត់ចែក តាម៉ុក សួរខ្ញុំថា៖ "ហ្អែង យកអង្ករ យកថ្នាំពេទ្យអី ទៅចែកឃុំត្រពាំងធំដែរអត់? ថាចែក។ ចុះម៉េចបានអញទៅប្រជាជនមកសុំថ្នាំអញ? ខ្ញុំអត់ដឹងទេលោកពូ។ អ៊ីចឹង ហ្អែងទៅមើល"។ ដល់ទៅមើលខ្ញុំទៅជួបប្រធានឃុំហ្នឹង -- មិនមែនប្រធានឃុំទេ ប្រធានមន្ទីរ សមាជិកគេអ្នកកាន់ឃ្លាំងហ្នឹង ខ្ញុំសួរថា "ចុះថ្នាំពេទ្យ ឆន ឯងទៅយកមកទុកឯណាឥឡូវហ្នឹង? ហ៊ឺ! អាហ្នឹង តាអត់ឲ្យចែកទេ តាទុកនៅផ្ទះឯណោះ។ ខ្ញុំថាទៅយកមកចែកឲ្យរហ័ស។ តាតាមទាន់ហើយហ្អែង។ អញឲ្យចែក យកដល់យប់ ចែកយប់ យកដល់ថ្ងៃ ចែកថ្ងៃ ហ្អែងយកមកលាក់"។ ដល់អ៊ីចឹងយកមកចែកទាំងថ្ងៃហ្នឹង ប្រជាជនទៅសុំតាហ្នឹង។ ខ្ញុំសូមជម្រាបខ្លីប៉ុណ្ណឹង។

[០៩:៥០:៥៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណណាស់លោក ហឿន សូមនិយាយឲ្យបានយឺតជាងហ្នឹងបន្តិច ព្រោះមានការបកប្រែភាសា។ ហើយលោកនិយាយលឿនបកប្រែភាសាអត់ទាន់ទេ ហើយម្យ៉ាងវិញទៀតឲ្យមានការឃ្លាតគ្នាបន្តិចរវាងការតាំងសំណួរ ហើយនិងឆ្លើយ ពីព្រោះអំមិញហ្នឹងគឺថា យើងតាំងសំណួរទៅជាភាសាខ្មែរបកប្រែជាភាសាអង់គ្លេស ហើយនិងបារាំងហ្នឹងមិនទាន់ទេ។ ហើយលោកចាប់ឆ្លើយ អ៊ីចឹងគឺ មានការបាត់នូវព័ត៌មានជាភាសាអង់គ្លេស និងភាសាបារាំង។ មេធាវី ដូចគ្នា សូមឲ្យបង្អង់បន្តិច មុនពេលដែលសាក្សីឆ្លើយចប់ ដើម្បីទុកឱកាសឲ្យការបកប្រែភាសាហ្នឹងបានពេញលេញត្រឹមត្រូវ។

សូមអញ្ជើញបន្តទៀតចុះ!

**លោក លីវ សុវណ្ណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** លោក ឯក ហឿន ខ្ញុំបាទសូមតាំងសំណួរបន្ត។ តើលោកដែលបានឃើញ ឬបានដឹងថា សហករណ៍នីមួយៗ បើសហករណ៍ណាដែលធ្វើការបង្កបង្កើនផលបានលើស ហើយសហករណ៍មួយទៀត ខ្វះខាត តើមានការចែករំលែកគ្នាពីសហករណ៍មួយទៅសហករណ៍មួយដែរឬទេ បាទ?

**លោក ឯក ហឿន៖**

**ឆ៖** បាទព្រ។ សូមជម្រាបប្រសាសន៍ សហករណ៍គឺលោកតាមឃុំចាត់ចែង ហើយសម្ភារៈ គឺស្រុកផ្តល់មកគ្រប់ចំនួនហើយ ប៉ុន្តែចែកទៅតាមរោងបាយ អារោងបាយហ្នឹងគឺលាក់លៀមអង្ករ។ លាក់លៀមអង្ករដូចថា គេឲ្យ ១០កំប៉ុង គ្នា២០នាក់ គេមិនបបរ១០កំប៉ុង គេបបរតែ៥កំប៉ុង ដល់អ្នកហូបទៅដេញដោលថា ម៉េចមានតែទឹក សម្លក៏មានតែទឹក បើអញទៅធ្វើការរែកដីមួយថ្ងៃទល់យប់ មកស៊ីតែទឹកអ៊ីចឹងមានកម្លាំងឯណាធ្វើ? អ៊ីចឹងឃុំតាមដាន។ ដល់ឃុំតាមដាន សួរ សួរដឹង ចែកស្មើគ្នា ម៉េចក៏បានឃុំខ្លះមានប្រាំ មាន១០ អ៊ីចឹងដេញដោលទៅឃើញ អ្នកចង្ក្រានបាយលាក់។ អ្នកចង្ក្រានបាយលាក់គេផ្លាស់ប្តូរអ្នកចង្ក្រានបាយហ្នឹងថ្មី។ ហ្នឹងសូមជម្រាបបាទ។

[០៩:៤៣:០០]

**ស៖** បាទ ក្នុងអំឡុងពេលដែលលោកនៅពាណិជ្ជកម្មស្រុកហ្នឹង តើមានដែលឃុំណាមួយគេបានរាយការណ៍ថា ខ្វះស្បៀង ហើយស្នើសុំឲ្យខាងស្រុកជួយដោះស្រាយដែរឬទេ?

**ឆ៖** បាទ មាន។ បាទ ឃុំច្រើនណាស់ដែលខ្វះ ឃុំលាយបូរ ខ្វះដល់ជួយលែងឈ្នះ ប្រជាជនបានស្លាប់អស់៥០០។ ស្លាប់តែម្តងអត់អីហូប ស្លាប់៥០០។ ហើយឃុំត្រពាំងធំ ខ្វះៗទៅសុំឃុំញ៉ែងញ៉ង ញ៉ែងញ៉ងចិញ្ចឹមម៉េចក៏មិនរស់ អត់មានអីហូប ប៉ុននៅជិតព្រៃដំឡូងចម្ការដាំ ដាំដំឡូងមី ដាំរួម យកមកស្ងោរឲ្យគាត់ហូបអត់មានស្លាប់ទេ។

**ស៖** អ៊ីចឹងមានន័យថាតាមគណៈដឹកនាំនីមួយៗបានខិតខំដោះស្រាយជីវភាពរបស់ប្រជាជនដែរ តើអ៊ីចឹងមែនទេបាទ?

**ឆ៖** បាទ ពិតណាស់ ខំដោះស្រាយកំណត់ចែក ដឹកមកដល់ចែកអស់ៗ ឲ្យចែករបបហូបមានប៉ុន្នាន កំណត់ដូចគ្នាស្មើគ្នា ប៉ុនខ្វចអាចង្ក្រានបាយហ្នឹងវាលាក់លៀម។

**ស៖** លោក ឯក ហឿន ក្រៅពីការងារនៅមន្ទីរស្រុក តើក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ៧៥ ដល់ឆ្នាំ -- ខែ១០ ឆ្នាំ៧៨ ដែលលោកបានចេញទៅកំពង់ចាមហ្នឹងក្នុងអំឡុងពេលនោះ តើលោករស់

នៅក្នុងភូមិណាដែរនៅក្នុងស្រុកត្រាំកក់ បាទ?

[០៩:៤៤:៥០]

**ឆៈ** បាទ ខ្ញុំកំណើតនៅឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ឆ្នាំ៧៨ ខែ៦, ខែ៧ ហ្នឹងខ្ញុំនៅក្នុងមន្ទីរស្រុក។ ដល់តាសឿន ឪអាឈ្លួសនេះ យកមនុស្សពីកោះអណ្តែតមកបីនាក់ ចៅហ្វាយស្រុក, អនុចៅហ្វាយហ្នឹង (អាលេខាស្រុក), អនុលេខា (សមាជិក) ចាប់គេមក។ ចាប់យកមក ហើយខ្ញុំនៅលើគ្រែក្នុងផ្ទះ គេមកដល់ គេកន្ត្រាក់វាំងននខ្ញុំដណ្តប់ កន្ត្រាក់ខ្នោកមក ខ្ញុំមុត-ក ត្រង់មុខងាកទៅគេចាំងពិលដាក់មុខ ខ្ញុំសួរថា៖ អ្នកណាគេរកអី? កុំចាំងពិល ស្រវាំង មិនដឹងអ្នកណាអ្នកណើទេ មើលគ្នាអត់ស្គាល់ទេ។ ហើយដល់ខ្ញុំដេកមុខទៅកើត១ គាត់កន្ត្រាក់ត្រូវស្មាខ្ញុំ ខ្ញុំថា៖ យី! ចុះរកអីហ្នឹង? អត់ព្រមនិយាយគ្នា ចេះតែចាំងពិលដាក់ អាងមិត្តឯងសម្បូរថ្ម? បានថា អ៊ីចឹងទៅ គាត់ដើរទៅរកផ្លូវទៅលិច ទៅកើត ចេះតែហៅ៖ អើយតាឈឿន១! ហើយ អាជាល ថា៖ អត់មាន តាឈឿន ទេ តាឈឿនទៅផ្ទះហើយ នៅតែ តាហឿន។ ដល់តែអាពាក្យហ្នឹងទៅដល់ អាជាល១ ជូនខ្ញុំមក។ ជូន តាឈឿនហ្នឹង តាឈឿន – ឪអាឈ្លួស។ ជូនទៅដល់ គេស្រែកថា សួរខ្ញុំថា៖ អីតា?, ខ្ញុំថា៖ បាទ។ តាឯងធ្វើម៉េចដល់កោះអណ្តែត? យីមិនដឹងអាម៉េចទេវ៉ឺ អញមើលអត់ស្គាល់ អត់មានធ្វើអីគេទេ។ ដល់អ៊ីចឹង គេមកចុះចាប់ដៃខ្ញុំ ខ្ញុំចាប់ដៃគេសួរថា៖ ចុះបងថាមានមនុស្សពីណាមក យកមកបីនាក់? គេថា៖ នោះ! នៅឡានហ្ន៎។ គេថាអ៊ីចឹង។ ដល់ថាអ៊ីចឹង ជិតពិលហ្នឹង តាឈឿន នៅដេកជិតហ្នឹង ប៉ុន្តែគេថាទៅផ្ទះ។ តាឈឿនហ្នឹងប្រធានមន្ទីរ, សោម ជន ចេញទៅ តាឈឿន ឡើងធ្វើប្រធានមន្ទីរហ្នឹង គេទទួលមនុស្សហ្នឹងហើយ តាឈឿន ហ្នឹងក៏ឲ្យគេយកទៅដាក់សាលា ម៉េង សាលាកែប្រែហ្នឹងទៅ។

**សៈ** អ៊ីចឹង លោកមានដឹងថា ពេលដែលប្រជាជនមានជំងឺ តើអាចសុំច្បាប់ឈប់សម្រាកបានដែរឬទេបាទ?

**ឆៈ** បាទ បើគេមានជំងឺ គឺមេកងគេបញ្ជូនទៅពេទ្យ។ គេអត់បាច់រាយការណ៍មកស្រុក រាយ-ការណ៍ទៅណាទេ សម្រេចលើមេកងគេបញ្ជូនទៅពេទ្យមើល។ អត់ពិបាកទេកន្លែងហ្នឹង។

**សៈ** ចុះចំពោះស្ត្រីដែលមានផ្ទៃពោះ តើការធ្វើការរបស់គាត់គេឲ្យគាត់ធ្វើអ្វីខ្លះបាទ?

**ឆៈ** បាទ កាលហ្នឹងគឺគេអត់ទាន់មានប្រើពេទ្យសម័យទេ។ គេប្រើតែពេទ្យពីបូរាណ យាយឆ្មប។ គេមានយាយឆ្មបគេ។ បាទ តែឈឺគេ ខ្ញុំឮ ចូលខែ១ ១០ហើយ គេឲ្យទៅសម្រាកនៅផ្ទះ។ ទៅសម្រាកផ្ទះ គេឲ្យយាយឆ្មបទៅដេក ទៅនៅជាមួយទៅ។ គេពេលឆ្លងទន្លេតែប៉ុណ្ណឹងទេ។

[០៩:៤៧:៥១]

**ស៖** បាទ ចុះនៅពេលដែលគាត់សម្រាលកូននោះ តើគេឲ្យគាត់ឈប់សម្រាករយៈពេលប៉ុន្មានដែរបាទ?

**ឆ៖** បាទ គេឲ្យហូប គេសម្រាកដល់មួយខែ។ គ្រួសារខ្ញុំក៏អ៊ីចឹងដែរ គេឲ្យសម្រាកមួយខែ តាំងពីថ្ងៃចេញទៅសម្រាករហូតដល់កើតហើយ បានតែមួយខែ រែកដីទៀតហើយ។

**ស៖** ម្សិលមិញ នៅម៉ោងប្រហែលជាបួននិងពីរនាទី លោកបានមានប្រសាសន៍ថា ការរៀបការបើមិនចុះសម្រុងគ្នាទេ គឺគេឲ្យខាងស្ត្រីទៅនៅកន្លែងកប់ខ្មោចមួយដើម្បីឲ្យគាត់ភ័យខ្លាច ហើយគាត់នឹងហៅប្ដីគាត់ឲ្យទៅជួយ ឲ្យទៅជិតគ្នា។ សំណួរខ្ញុំ ខ្ញុំសួរថា ចុះបើសិនជាគាត់នៅតែមិនព្រមរួមរស់ជាមួយគ្នាទៀត តើពួកគាត់មានសិទ្ធិបែកគ្នាដែរឬទេ?

**ឆ៖** បាទ ពីជំនាន់ហ្នឹង ខ្មែរក្រហមគឺស្លូតបូតរាបសា អត់ចេះឈ្លោះប្រកែកគ្នាទេ រាបសាគោរពស្រឡាញ់គ្នា ទោះបីគេអត់ស្រឡាញ់ ទៅបង្ខំឲ្យគេទៅដេកទៅនៅជាមួយ ចូលទៅស្រីហ្នឹង ខ្ញាំខ្ញាចរយះរយាយអស់។ អាប្ដីរត់មកប្រាប់ប្រធានមន្ទីរទៀត។ ប្រធានមន្ទីរថា បើអ៊ីចឹងគេអស់មានលទ្ធភាពហើយឯងឈប់ចង់។ ប៉ុន្តែវាអត់ឈប់ វានៅតែស្រឡាញ់គ្នា ប៉ុន្តែអាណាទៅយក មនុស្សកើតស្រែង កើតឃ្លង់ប្រពន្ធវាល្អ វាអត់យក អត់បានគ្នារហូត។

**ស៖** អ៊ីចឹង មានន័យថាគេឈប់បង្ខំ គេឈប់ អត់មានការបង្ខំឲ្យគាត់ត្រូវតែរួមរស់ជាមួយគ្នាដែរមែនទេបាទ?

**ឆ៖** បាទ មែន។

[០៩:៥០:១០]

**ស៖** ទាក់ទងនឹងព្រះសង្ឃ ដែលលោកមានប្រសាសន៍ពីម្សិលមិញថា បានទៅធ្វើការជាមួយនឹងប្រជាជនធម្មតា ហើយលោកចាប់ផ្ដើមសឹកម្ដងម្នាក់ពីរនាក់ជាបន្តបន្ទាប់។ ហើយអម្បាញ់មិញនេះលោកបានផ្ដល់សក្ខីកម្មថា លោកសង្ឃបានទៅជួយជីកទំនប់ខ្ទបត្របែកដែរនៅក្នុងឆ្នាំ៧៤។ អ៊ីចឹងសំណួរខ្ញុំសួរថា លោកចាប់ផ្ដើមសឹកតាំងពីឆ្នាំ៧៤មកម្ល៉េះ ឬមួយយ៉ាងណា?

**ឆ៖** បាទ ចាប់ផ្ដើមសឹកនៅឆ្នាំ៧៤ ដែលអង្គការតម្រូវឲ្យធ្វើទំនប់ ធ្វើប្រឡាយទាំងអស់ លោកអត់ចង្ហាន់ទៀត បានណាបានបាយណា មានហូបបាយរួម។ អត់មានចង្ហាន់ អ៊ីចឹងលោកសឹក លោកបកស្បង់ចីពរចោល មកផ្ទះរៀងខ្លួន មកធ្វើការ។ អ្នកខ្លះដែលនៅពេញវ័យគឺចូលធ្វើទ័ព ចូលធ្វើទ័ពទាំងអស់

សឹកទាំងអស់ សឹករហូតពី៧៤រហូតមកទល់៧៦ នៅបងប្អូន តាម៉ុក ឈ្មោះសង្គ្រាជ នៅ, សង្គ្រាជ នៅហ្នឹងជាអនុគុណខេត្ត គាត់អត់ព្រមសឹកទៅនៅព្រៃធាតុណា, តាម៉ុក ឲ្យគេទៅនៅព្រៃធាតុហ្នឹង អត់ឲ្យលោកនៅហ្នឹងបាន។ គាត់ទៅវត្តណា តាម៉ុក យកវត្តហ្នឹងធ្វើកន្លែងក្រោលគោ។ ទៅនៅឯណា តាម៉ុក តាមផ្ដាញ់ផ្ដាលដល់៧៦ ខែ៦ ទៅហើយហ្នឹង តានៅ សឹក។ ដល់ តានៅ សឹក, តាម៉ុក យក តានៅ ទៅការប្រពន្ធឲ្យ។ ការប្រពន្ធ តានៅ អត់ទៅរួមដំណេក តាម៉ុក លែងទទួលស្គាល់។ ដល់អ៊ីចឹង ប្រាំមួយខែបានទៅផ្សំដំណេកជាមួយប្រពន្ធ។ ដល់ត្រូវគ្នាជាមួយប្រពន្ធហើយ តាម៉ុក ទៅឲ្យ តានៅ ហ្នឹងទៅធ្វើគណៈភស្តុភារខាងភាគនិរតីហ្នឹង បាទ។

[០៩:៥២:១៥]

**ស៖** អ៊ីចឹង តើការសឹករបស់លោកពីឆ្នាំ៧៥ហ្នឹង ជាការសឹកដោយខ្លួនឯង ឬក៏សឹកដោយមានការបង្ខិតបង្ខំ?

**ឆ៖** បាទ អត់មានបង្ខិតបង្ខំទេ អត់ចង្អាន់លោកសឹកខ្លួនឯង។ តាម៉ុក ផ្ដាច់ជើងអត់ឲ្យឧបាសកកាលណាបាយរួម អ្នកណាយកខុសផែនការ អត់ស៊ីខ្លួនឯង។ អ៊ីចឹងមានតែបាយគ្រាន់តែហូបខ្លួនឯង មានបាយឯណាយកប្រគេនលោក អ៊ីចឹងស៊ីតែខ្លួនឯង លោកអត់។ ដល់អ៊ីចឹងទៅធ្វើទំនប់ធ្វើប្រឡាយក៏អត់អង្ករ អត់អីដាំ អ៊ីចឹងលោកបង្ខំសឹកខ្លួនឯង។

**ស៖** បាទ អម្បាញ់មិញលោកបានមានប្រសាសន៍ទាក់ទងនឹងឈ្មោះ សឿន ដែលជាគណៈស្រុកកោះអណ្ដែត ដែលថាបាន -- លោកធាក់ត្រូវ ហើយរកសម្លាប់លោក។ អ៊ីចឹងទាក់ទងនឹងឈ្មោះ សឿន នេះខ្ញុំបាទសូមតាំងសំណួរមួយចំនួន។ ឯកសារលេខ 305/13.23.451, ត្រង់ ERN ជាភាសាខ្មែរមាន 00968892 អ៎! 93 (សូមទោស) ហើយ ERN ជាភាសាអង់គ្លេសមាន 00050186 ដល់ 87 លោកបានឆ្លើយថា៖ “ដល់ពេលដែលគេយកមិត្តនោះទៅបាត់ គេអត់លាទេ គេទៅសុំចៅហ្វាយស្រុកយកខ្ញុំទៅសម្លាប់ សុំតាំងពីម៉ោងដប់ទល់ម៉ោងប្រាំមួយព្រឹក សុំយកសម្លាប់”។ ហើយនៅក្នុងចម្លើយមួយទៀតគឺមានលេខឯកសារដដែល មានលេខ ERN 00968805, ជាភាសាអង់គ្លេស 01050194 លោកបានឆ្លើយបន្ថែមថា “កុំអីគេយកទៅបាត់ហើយ អាសឿន គេប្រុងសម្លាប់ខ្ញុំ សុំគេមួយយប់ទល់ភ្លឺ គេអត់ឲ្យ រកសម្លាប់ខ្ញុំ។ ព្រឹកឡើងនីរសារខ្ញុំរត់ទៅប្រាប់ខ្ញុំថា តាឯងធាក់បងកោះអណ្ដែត ម៉េចអំមិញគេសុំ តាអ៊ួច ទៅសម្លាប់ហើយ។ គេប្រាប់អ៊ីចឹង ខ្ញុំកំពុងតែរៀបលុបមាត់ព្រឹកឡើង លុបមុខតែមួយឆាច់ទាញម៉ូតូទៅខេត្ត ទៅជួប តាគិត ថា៖ ពូគេរកសម្លាប់ខ្ញុំហើយ។ ថាអាណា? ថាអាសឿន កោះអណ្ដែត។

ថាអាសឿនហ្នឹង អាណាចាត់តាំងឲ្យ អាសឿន ទៅនៅនុ៎ង? អញឲ្យទៅជួបវា អញសួរវាមួយម៉ាត់។ វាក្រពាត់ដៃដើរទៅនេះ ដើរទៅនោះ ឡានអញរអិលធ្លាប់ព្រែក។ អាហ្នឹងឲ្យនីរសារទៅហៅ ទៅហៅអាសឿន ឲ្យមកជួប។ ដល់ហៅនីរសារយកពីស្រុកខ្ញុំទៅហ្នឹង ខ្ញុំថា៖ អ្ហែង បើតាគិត សម្រេចឲ្យគេសម្លាប់អញ ហ្អែងប្រាប់អញ ម៉េចៗហ្អែងទៅប្រាប់អញ។ ដល់ខ្ញុំផ្ដាំវាអ៊ីចឹង វាទៅហៅកោះអណ្ដែត និងទល់គ្នាម៉ោងពីររសៀលទើបមកដល់ ឆ្ងាយណាស់។ មកដល់ តាគិតថា ម៉េច សឿន--

**ប្រធានអង្គជំនុំ៖**

មេធាវីដកស្រង់វែងណាស់ ហើយម្សិលមិញប្រាប់ហើយ គួរតែរៀបចំសំណួរណាដែលខ្លីល្មមអាចឲ្យគាត់ចងចាំ ហើយនិងអាចឆ្លើយតបបាន។ បាទ ឥឡូវហ្នឹងខាងសហព្រះរាជអាជ្ញា -- តំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានបញ្ហាអី សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ថាសូមឲ្យមេធាវីផ្ដល់ ERN ជាបីភាសាតែម្ដង។ ហើយខ្ញុំដឹងថា មេធាវីការពារថ្មីគាត់ថ្មី ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំឃើញថា ERN ជាភាសាបារាំង គឺខ្ញុំកត់អត់ទាន់ទេ ព្រោះគាត់អានលឿនជ្រុល ហើយអ្នកបកប្រែគាត់បកបានតែពាក់កណ្ដាល។ ដូច្នេះ គឺខ្ញុំចង់បញ្ជាក់ថា ចំពោះឯកសារជាបារាំង គឺខ្ញុំមើលអត់ឃើញ ខ្ញុំរកអត់ឃើញ។ ដូច្នេះ សង្ឃឹមថាមេធាវីការពារក្ដីគាត់អាចផ្ដល់ ERN ជាភាសាបារាំងដើម្បីឲ្យខ្ញុំអាចរកឯកសារបាន។ ហើយសូមសំណូមពរម្ដងទៀត សូមឲ្យមេធាវីការពារក្ដីគាត់អានឲ្យបានយឺតៗ។

[០៩:៥៧:៣៨]

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណ។ ខ្ញុំសូមអភ័យទោស ដោយសារខ្ញុំបាទអត់បានរៀបចំជាភាសា -- ERN ជាភាសាបារាំង ហើយក៏សូមអភ័យទោស ហើយអាចយល់អច្ឆាស្រ័យ ដោយសារខ្ញុំបាទយកតែ ERN តែពីរភាសា។ អ៊ីចឹង ប្រហែលជាខ្ញុំដកស្រង់តែចំណុចនេះមួយទៀតទេ គឺអស់ដកស្រង់ ERN ហើយបាទ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ខ្ញុំសូមបន្ត៖ "អាសឿន ឯងមានអំណាចទៅគំរាមកំហែងគេ សុំគេយកទៅបាញ់ចោល។ សឿន ឯងធ្វើហ្នឹងធ្វើម៉េចហ្នឹង មិត្តហ្នឹងទេ បើក្រៅពីមិត្តហ្នឹង សឿនឯងយកគេទៅវ៉ៃយកបាត់ហើយ"។ ហើយម្យ៉ាងទៀត គឺឯកសារមានលេខ 319 (សូមទោស) ឯកសារលេខ E319.1.31 ចម្លើយទី៤៨។

ក្នុងហ្នឹងចម្លើយរបស់លោកបានឆ្លើយថា៖ "ពេល តាសឿន ឡើងជាចៅហ្វាយស្រុកកោះអណ្តែត គាត់បានចាប់ខ្លួនគណៈស្រុកកោះអណ្តែតទាំងបីនាក់ ហើយបញ្ជូនទៅសម្លាប់"។ អ៊ីចឹង សំណួរខ្ញុំសុំសួរលោក ឯក ហឿន ថានៅពេលនោះការចាប់ខ្លួន គណៈស្រុកមានសិទ្ធិចាប់ខ្លួនយកគេទៅសម្លាប់ ដូចដែលលោកបានផ្តល់សក្ខីកម្មនេះមែនដែរឬទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ ការពិតណាស់ត្រង់ហ្នឹង។

[១០:០០:២២]

**ស៖** សំណួរខ្ញុំបន្តទៅទៀត គឺឯកសារលេខ E319.1.31 ដដែល ត្រង់ចម្លើយទី២៩ លោកបានឆ្លើយចំពោះមុខចៅក្រមស៊ើបអង្កេតថា៖ "តាម៉ុក មានទំនាក់ទំនងជាមួយជំទប់ ជាល ម្នាក់ (ជំទប់លេខ ៣ នៅសម័យសង្គមរាស្ត្រនិយម) ពេលនោះ យាយខុម បានយកជំទប់ ជាល នោះទៅសម្លាប់។ ហើយលោកបានមានប្រសាសន៍កាលពីម្សិលមិញ គឺ តាម៉ុក គាត់បានលើកនៅក្នុងអង្គមីទ្ទិងបីលើកទាក់ទងនឹងជំទប់ ជាល ហើយតាម៉ុក គាត់បានលើកថា ជំទប់ ជាល ជាស្ត្រី វាមិនមែនជាគិញ វាមិនមែនជាខ្មាំងជាមនុស្សស្រីហ្នឹង ហេតុអីបានជាយកវាទៅសម្លាប់?"។ អ៊ីចឹងចំណុចនេះ ខ្ញុំបាទចង់សួរលោកថា លោកអាចបញ្ជាក់បានទេថាហេតុអីបានជាគាត់សង្កត់ធ្ងន់ មិនចង់ឲ្យគេសម្លាប់ជំទប់? ខ្ញុំសូមតាំងសំណួរម្តងទៀត លោកអាចបញ្ជាក់បានទេថា ហេតុអីបានជាគាត់ប្រើពាក្យថា "ជំទប់ជាល មិនមែនជាគិញទេ មិនមែនជាខ្មាំងទេ ម្តេចក៏សម្លាប់វា"?

**ឆ៖** បាទ អាហ្នឹង ខ្ញុំសូមឆ្លើយប្រសាសន៍ ការពិតណាស់ដែលតាម៉ុក ឲ្យតែសម្លាប់អ្នកណាក៏ដោយ គឺគាត់កាន់ជើងតែទាំងអស់ អត់ឲ្យសម្លាប់ទាល់តែសោះ ហើយមកសម្លាប់ក្តើគាត់ ពួកម៉ាក់គាត់គាត់ខឹង។

**ស៖** អ៊ីចឹងមានន័យថា ការសម្លាប់ជំទប់ជាល គឺធ្វើឡើងដោយ យាយខុម ដែលជាគណៈស្រុក ១០៥ គឺស្រុកត្រាំកក់។ តើអ៊ីចឹងមែនទេបាទ?

**ឆ៖** បាទ ពិតណាស់ត្រង់ហ្នឹង យាយខុម សម្រេចអី ធ្វើតែខ្លួនគាត់ហ្នឹង។

**ស៖** អ៊ីចឹងទាក់ទងនឹងការសម្លាប់ប្រជាជនដែលដូរពីវៀតណាមមកចំនួន៩០នាក់ ដែលលោកបានមានប្រសាសន៍អម្បាញ់មិញ តើការសម្លាប់នោះ តាម៉ុក គាត់មិនបានដឹង ឬមួយក៏គេរាយការណ៍ឲ្យគាត់ហើយបានសម្លាប់ជាក្រោយបាទ?

[១០:០៣:៤១]

**ឆ៖** បាទ គេសម្លាប់ហើយ ក៏គេអត់រាយការណ៍តាម៉ុក ដែរ ទាល់តែតាម៉ុកហ្នឹងគាត់ទៅមើល គេទប់ គេជីកប្រឡាយ ទៅមើលទៅចូលកន្លែង តាជឹម។ សួរថា ឯណាមនុស្សអញយកមកឲ្យហ្វែង ៩០នោះ?" តាជឹម មិងមាំងៗហើយបានឆ្លើយភរគាត់ថា "អាហ្នឹងលួចគេ យប់ឡើងបាត់ចាន បាត់ឆ្នាំង ឲ្យគេយកសម្លាប់អស់ហើយ" តាម៉ុក ខឹងទើង។

**ស៖** អ៊ីចឹងមានន័យថាការសម្រេចសម្លាប់នេះ គឺធ្វើឡើងដោយ តាជឹម ដែលជាគណៈស្រុក ហើយវាមិនមែនជាគោលនយោបាយដែល តាម៉ុក ដាក់ចេញទេ អ៊ីចឹងមែនទេបាទ?

**ឆ៖** បាទ ពិតណាស់ មិនមែនផែនការ តាម៉ុក ទេ។

**ស៖** អ៊ីចឹង ខ្ញុំសូមអនុញ្ញាតទៅតាំងសំណួរថ្មីមួយទៀតទាក់ទងនឹងឯកសារលេខ E319.1.32 ត្រង់ចម្លើយទី៦៣។ សូមទោស ខ្ញុំសូមសំណួរនេះបានសួរហើយ ខ្ញុំសូមទៅទាក់ទង E319/8.2.4 ត្រង់សំណួរចម្លើយទី២៤ លោកបានឆ្លើយចំពោះមុខចៅក្រមស៊ើបអង្កេតថា៖ "បាទ ត្រឹមត្រូវហើយ ឧទាហរណ៍ខេត្តបញ្ជូនរបាយការណ៍ដែលមានចំណារទឹកប៊ិកក្រហមឲ្យចាប់នរណាម្នាក់ទៅស្រុក នោះស្រុកនឹងបញ្ជូនរបាយការណ៍នោះបន្តទៅឃុំទៀត។ បន្ទាប់មក ឃុំបានចាប់មនុស្សទាំងនោះទៅតាមចំណារប៊ិកក្រហម ហើយចុងក្រោយមនុស្សដែលចាប់នោះនឹងត្រូវបញ្ជូនទៅឲ្យ យាយខុម"។ អ៊ីចឹងសំណួរខ្ញុំ ខ្ញុំសួរថា តើការចាប់បញ្ជូនទៅ យាយខុមនេះ –ដែលលោកមានប្រសាសន៍ថាមានប៊ិកក្រហមនេះ– តើលោកបានឃើញគេចារប៊ិកក្រហម ប៊ិកខៀវ ដោយរបៀបណាដែរបាទ?

**ឆ៖** បាទ គេប៊ិកក្រហមហ្នឹង គឺគេសម្រេចឯកភាពគ្នាទាំងឃុំ ទាំងស្រុក ទាំងខេត្តហើយ បើកាលណាឃើញឈ្មោះ "ក" ហ្នឹងមានរង្វង់ក្រចកទឹកប៊ិកក្រហម គឺចាប់សំដៅទៅឲ្យ យាយខុម ទៅអត់មានដោះស្រាយទេ។ បើកាលណាឈ្មោះ "ក" ហ្នឹងរង្វង់ក្រចកទឹកប៊ិកខៀវ គឺចាប់យកទៅដាក់នៅមន្ទីរស្រុក ស្រុកយកទៅដាក់សាលាកែប្រែ គេហៅថាទោសកម្រិតស្រាល។ ឃើញច្បាស់នឹងភ្នែក ឃើញរាល់ថ្ងៃហ្នឹង។ ឃើញអាសំបុត្រគេសរសេរដាក់ក្នុងធុងសំរាមហ្នឹង។

[១០:០៧:១៥]

**ស៖** តើលោកដឹងថាការចារបែបនេះ គឺមានការប្រជុំណែនាំ ឬក៏លោកដឹងដោយវិធីណាបាទ?

**ឆ៖** បាទ ឃើញសំបុត្រមកពីខេត្ត ឃើញឲ្យចាប់អ្នកណា ក៏ឃើញរង្វង់ក្រចកទឹកប៊ិកក្រហមហ្នឹង ឃើញទឹកប៊ិកខៀវហ្នឹង ឃើញដូចតែគ្នា មិនដឹងគេសម្រេចពីថ្នាក់ណាមក អត់បានដឹងទេ។

**សៈ** បាទ ខ្ញុំសូមចូលទៅឯកសារដដែល គឺ E319/8.2.4 ត្រង់ចម្លើយទី២៥ លោកបាន -- “សំណួរសួរថា តើយាយ ខុម មានតួនាទីអ្វីដែរ? លោកបានឆ្លើយថា គាត់ជាសមាជិកខេត្ត ឬតំបន់១៣ ហើយមន្ទីរដែល យាយខុម ធ្វើការគឺមានចម្ងាយប្រហែល២០០ម៉ែត្រខាងជើងពីកន្លែងសម្លាប់មនុស្ស ឈ្មោះព្រៃខ្មោចក្មេង – ព្រៃខ្មោចកូនក្មេង”។ អ៊ីចឹងអម្បាញ់មិញលោកបានឆ្លើយថា ការចាប់បញ្ជូនទៅឲ្យ យាយខុម ហើយលោកសំណួរទី២៥ លោកថា យាយខុម ជាគណៈតំបន់។ អ៊ីចឹងលោកអាចគិតឡើង វិញបានទេថា តើបញ្ជាឲ្យចាប់មនុស្សនេះ គឺធ្វើដោយ យាយខុម ឬធ្វើដោយអ្នកណា?

**ឆៈ** បាទ សូមជម្រាបប្រសាសន៍ គឺផែនការពីលើមកគេមានទិសគេហើយអស់ហើយហ្នឹង។ គេថា “សក្តិភូមិ នាយទុន ប្រតិកិរិយា ត្រូវប្រហារឲ្យអស់ កម្ទេចទាំងរបប កម្ទេចទាំងបុគ្គល” ហើយ យាយខុម ដើរចាត់ការ និងសម្រេចលើ យាយខុម ហ្នឹង។ គឺចាប់តាមពាក្យស្លោករបស់គេហ្នឹង។ ប៉ូលិស ទាហាន គ្រូបង្រៀន អតីតទាហានវ៉ឺត្រែតក៏គេចាប់ដែរ អ្នកមានធនតូចៗ ក៏គេចាប់យកសម្លាប់ទាំងអស់ ហើយ។ ភូមិមានមនុស្សឯណា មានតែនៅម្នាក់ពីរនាក់ហ្នឹង ចាប់អស់។

[១០:០៩:២៧]

**សៈ** អ៊ីចឹងការចាប់មនុស្សហ្នឹង គឺមានដែលថាលោកមានប្រសាសន៍ថា នាយទុន សក្តិភូមិ និង អតីតទាហាននេះគឺតែក្នុងអំឡុងពេល យាយខុម កាន់អំណាចទេ។ តើក្រោយពី យាយខុម កាន់អំណាច មានការចាប់ទៀតដែរឬទេ?

**ឆៈ** បាទ សូមជម្រាបប្រសាសន៍ គេចាប់តាំងពីឆ្នាំ៧០។ ៧០ គេធ្វើរដ្ឋប្រហារសម្តេច សីហនុ ហើយពួកខ្មែរក្រហម គេហៅថា “*ខ្មែររំដោះ*” ហ្នឹងគេចេញពីព្រៃមកហើយ។ ចេញពីព្រៃមក គេមកមក ចាត់តាំងរដ្ឋអំណាចគេ ដូចខ្ញុំជម្រាបប្រាប់ថា ទី១ ខ្ពបត្របែក, ទី២ ត្រពាំងធំខាងជើង, ទី៣ ជាងទង, ទី៤ ត្រពាំងធំខាងត្បូង, ទី៦ សំរោង, ទី៧ គុស និងទី៨ ញ៉ែងញ៉ង។ អាហ្នឹង ទឹកដីហ្នឹង ខ្មែរក្រហម វាមកចាត់តាំងរដ្ឋអំណាចគេហើយ។ ចាត់តាំងរដ្ឋអំណាចគេហើយ ស្អែកឡើងគេចាប់ហើយ។ ឃើញ តែបណ្តើរហែៗទៅ ហើយអាអ្នកមានកូនម៉ាស៊ីនស្រូវតូចក៏គេចាប់ដែរ គេថាអាហ្នឹងអនុធន ជិះជាន់ក ប្រជាជនផ្ទាល់ត្រូវតែចាប់។ ចាប់អាអ្នកមានម៉ាស៊ីនស្រូវហ្នឹង។ ផ្ទះមួយគ្រាន់តែមានកូនស្វាយប្រហែល ១០-២០ដើម ហ្នឹងក៏គេចោទថាអ្នកអនុធនដែរ។ អាហ្នឹងគេចាប់ទាំងអស់។ អាអ្នកមានស្រូវហូបបន្តិច បន្តួចគ្រាន់តែសល់ខ្លះហ្នឹង ក៏គេចោទថាអ្នកមាននាយទុនដែរ។ អាហ្នឹងចាប់ៗរហូតទាល់តែមនុស្ស ភ័យខ្លាច ខ្សឹបខ្សៀវពេញភូមិ បានយប់ឡើងត្រជាក់ខ្លួន ខ្លាចទាំងអស់គ្នា ទាំងភូមិៗតាមស្រុកទាំងអស់

ខ្លាចទាំងអស់ៗគ្នាហ្នឹង វាធ្វើអ៊ីចឹង។

**សៈ** អ៊ីចឹង ខ្ញុំសូមបញ្ជាក់បន្តិច សុំកាត់បន្តិចដោយសារនេះ -- ខ្ញុំសូមបញ្ជាក់បន្តិចថា អ៊ីចឹង សំណួរដែលលោកឆ្លើយនេះ គឺទាក់ទងនឹងការចាប់ខ្លួននៅមុនឆ្នាំ១៩៧៥ ឬយ៉ាងណា?

**ឆៈ** សុំអានម្តងទៀត ដូចតាមអត់ទាន់ច្បាស់។

**សៈ** បាទ អំមិញខ្ញុំសួរថា ការចាប់ខ្លួននេះ តាមបញ្ជារបស់ យាយខុម ដែលលោកបានឆ្លើយថា តាមបញ្ជារបស់ យាយខុម។ ហើយខ្ញុំសួរថា តើបន្ទាប់ពី យាយខុម មានការចាប់ខ្លួនទៀតដែរឬទេ? លោកថាការចាប់នេះគឺមាននៅតាំងពីឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារខ្មែរក្រហមចាត់តាំងរដ្ឋអំណាច ហើយធ្វើការចាប់ខ្លួន។ អ៊ីចឹងសំណួររបស់ខ្ញុំសួរថា ចម្លើយដែលលោកឆ្លើយថាគឺគេចាប់តាមចំណារទឹកប៊ិកក្រហម ហើយបញ្ជូនឲ្យ យាយខុម។ តាមបញ្ជា យាយខុម នេះតើចម្លើយរបស់លោកនេះ គឺសំដៅលើមុនឆ្នាំ៧៥ ឬក្រោយឆ្នាំ៧៥?

**ឆៈ** បាទ គឺត្រឹមឆ្នាំ៧៦ ទៅ៧៥ ហ្នឹងវាចាប់ហើយ។ ដល់ពេល៧៦ ខែ៣ គឺចាប់យួន។ ដល់ ៧៧ ខែ៨ អស់ហើយ ឯករាជ្យហើយ ប្រជាជនលែងភ័យ លែងខ្លាច។ ពេលនោះ គ្រូអ៊ូច គាត់ឡើងធ្វើលេខាស្រុក(ឮមិនច្បាស់) ប្អូនថ្លៃ តាម៉ុក។ អស់ការចាប់ចងហើយ ស្រុកឯករាជ្យរហូតហើយ។

**សៈ** អ៊ីចឹងបន្ទាប់ពី យាយខុម គាត់ឈប់ធ្វើជាគណៈស្រុក១០៥ ស្រុកត្រាំកក់ អស់មានការចាប់ខ្លួនហើយ ឬយ៉ាងម៉េច?

[១០:១៣:១៧]

**ឆៈ** បាទ មានដល់៧៦។ ៧៦ តាចាយ បោសសម្អាតយួននៅក្នុងស្រុក ក្នុងប្រទេសកម្ពុជាក្នុងស្រុក១០៥ ហ្នឹងគឺផែនការ តាចាយ។ ផែនការ តាចាយ គាត់ទទួលផែនការពីលើមកទៀតទេ មិនមែនត្រឹមគាត់ទេ ព្រោះតាហ្នឹងមនុស្សកាន់សីល១០ៗ អត់ហ៊ានសម្លាប់សត្វ សម្លាប់អីតូចធំ ក៏អត់ហ៊ានដែរ គាត់ទទួលផែនការពីលើដែរ។ ឃើញគាត់ហៅមេឃុំគ្រប់ឃុំទៅប្រជុំនៅកន្លែងស្រុកហ្នឹង។ ហើយខ្ញុំលួចស្តាប់ ព្រោះថាគេប្រជុំ គេប្រើខ្ញុំហើយ។ គេប្រើយកទឹកក្តៅ ទឹកត្រជាក់ទៅឲ្យគេ ខ្ញុំលបស្តាប់ចេះតែឮហើយ។ ឮថាគោលការណ៍ត្រូវចាប់យួនបញ្ជូនទៅស្រុក។ អ៊ីចឹង តាចាយ គាត់ថា "ហ៊ឺ! អញមិនដឹងសម្រេចយ៉ាងម៉េចទេអ្ហា បើប្រជាជនខ្លួនឯងសុទ្ធសាធហើយហ្នឹង បើមានកូនប្រុស កូនស្រីអីទាំងអស់ កូនក្រមុំ កូនកំលោះអស់ទៅហើយ ទៅចាប់គេយ៉ាងម៉េច អញធ្វើអត់កើតទេអ្ហា"។ គាត់ថាអ៊ីចឹង គាត់ថាប្រកែក។

**សៈ** បាទ សូមអរគុណ។ ខ្ញុំបាទសូមទៅសំណួរថ្មីមួយទៀត។ ដោយសារលោកបានស្គាល់ យាយខុម ហើយយាយខុម ក៏ធ្លាប់ តាមចម្លើយរបស់លោកគឺធ្លាប់តាមសម្លាប់លោកដែរ។ អ៊ីចឹងខ្ញុំបាទចង់សួរថា តើ យាយខុម គាត់ចរិតយ៉ាងណាដែរ តាមការកត់សម្គាល់របស់លោក តាមការសង្កេតរបស់លោក?

**ឆៈ** បាទ គាត់អត្តចរិត បើមិនបានសម្លាប់គេ គាត់នៅអត់សុខទេ គាត់ដើរចាប់ ដើរចងគេយកតែទាំងថ្ងៃហ្នឹង អត្តចរិតគាត់តែអ៊ីចឹង។ ហើយដើរថា អត់មាន អត់ញញើតប្រជាជន គំរាមកំហែងប្រជាជនសុទ្ធតែអាសក្តិភូមិ សុទ្ធតែពួកអានាយទុន សុទ្ធតែពួកអាប្រទេកកិរិយាដើរដល់ណាថាដល់ហ្នឹងតែអ៊ីចឹង អាណាក៏ស្អប់ដែរ។

[១០:១៥:១១]

**សៈ** ខ្ញុំបាទសុំដកស្រង់ តាមកំណត់ហេតុប្រតិចារឹកសវនាការថ្ងៃទី០៥ ខែ៥ ឆ្នាំ២០១៥ ដែលបានសួរលោកស្រី ខឹម បឿន គឺត្រង់នាទីទី ១០:០៦:៥១ គឺចម្លើយរបស់ យាយបឿន គាត់បានឆ្លើយថា៖ "ខុម ជាមនុស្សដែលគាត់មិនដូចយើងគ្រប់គ្នា។ គាត់មានរបៀបហៅថា សរសៃប្រសាទ ឬក៏ពាក្យគេថាឆ្កួត ប៉ុន្តែមិនជាប់ ពេលខ្លះឆ្កួត ពេលខ្លះជា។ ហ្នឹងខ្ញុំស្គាល់ប៉ុណ្ណឹង"។ ម្យ៉ាងទៀត តាមចម្លើយរបស់លោក ពេជ្រ ជឹម ហៅតាជឹម ដែលបានផ្តល់សក្ខីកម្មនៅថ្ងៃទី២៤ ខែ៤ ឆ្នាំ២០១៥ នៅនាទី នៅវេលាម៉ោង ១៣:៥៨:៥៩ គឺគាត់បានឆ្លើយថា៖ "កាលនោះ គិតគ្នារកវិធីមើល រកពេទ្យ ពេទ្យកងអ្នកមើល។ យកពេទ្យវៀតណាមទៀត ហើយវិភាគទាំងគ្នាថាឈឺសរសៃប្រសាទ។ បញ្ជាក់អ៊ីចឹង ហើយមិនមែនថាគាត់ឆ្កួត វិកលចរិត មិនគ្រប់ទឹកអ៊ីចឹង មិនមែនទេ។ គឺមិនដល់ថ្នាក់ហ្នឹងទេ។ គាត់ប៉ះពាល់សរសៃប្រសាទ។ ប៉ុន្តែគាត់មានចិត្តឆៅណាស់ ម៉ាត់ណាម៉ាត់ហ្នឹងហើយ។ ផ្តាក់ឈឺអ៊ីចឹងម្តង"។

អ៊ីចឹង សំណួរខ្ញុំសុំសួរថា តើលោកឯកភាពនឹងសក្ខីកម្មរបស់ យាយបឿន និង តាជឹម ដែរទេ ដែលថា យាយខុម គាត់មានជំងឺសរសៃប្រសាទ?

**ឆៈ** បាទ ខ្ញុំអត់ឯកភាពទេ ព្រោះ យាយខុម នៅមន្ទីរឆ្ងាយពីផ្ទះខ្ញុំដែរ ១០០ម៉ែត្រហ្នឹង ខាងជើងក្រាំងតាចាន់ ហ្នឹង។ អត់ដែលឆ្កួតទេមនុស្សហ្នឹង ដើរតែចាប់ចងគេសម្លាប់តាមអំពើចិត្តហ្នឹង។ ខ្ញុំអត់ឯកភាពតាមសំណួរ តាជឹម និង យាយបឿន ទេ ព្រោះអាហ្នឹងជាមេរបស់គេ គេកាន់ជើងអ៊ីចឹង គេលាក់បាំងអ៊ីចឹង។ តែខ្ញុំជាអ្នករងគ្រោះ ខ្ញុំអត់លាក់ទេ ធ្វើបាបខ្ញុំ។

[១០:១៨:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់សាមសិបប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោក ឯក ហឿន ឥឡូវនេះ ដល់ពេលសម្រាកហើយ ឥឡូវលោកអាចសម្រាកបានហើយ ហើយលោកមកអង្គុយកន្លែងផ្តល់សក្ខីកម្មនៅវេលាម៉ោងដប់ និងសាមសិបប្រាំនាទី។ លោក ហឿន?

**លោក ឯក ហឿន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨ នាទី ដល់ម៉ោង ១០:៣៨ នាទី)*

[១០:៣៨:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ហើយសួរស្តី លោក ឯក ហឿន លោកបានត្រៀមខ្លួនរួចហើយឬនៅ?

**លោក ឯក ហឿន៖**

បាទ ត្រៀមរួចស្រេចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរៗគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

បាទ អត់លោកៗ នួន ជា។ អត់ៗទេ បាទ។

**លោក លីវ សុវណ្ណា៖**

បាទអរគុណ លោកប្រធាន បាទ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** លោក ឯក ហឿន ខ្ញុំបាទសូមបន្តសំណួររបស់ខ្ញុំ។ ទាក់ទងនឹង ពាក់ព័ន្ធនឹង យាយខុម តើលោកកត់សម្គាល់ឃើញថាចរិតរបស់ យាយខុម ជាមនុស្សស្លូតបូត ឬក៏គាត់ជាមនុស្សកាច បាទ?

[១០:៣៩:២៣]

**លោក ឯក ហឿន៖**

**ឆ៖** បាទ អត់ស្លូតបូតទេមនុស្សហ្នឹងនោះ គឺកាចណាស់ សូម្បីតែដើរច្រូត ហើយគាត់ទៅមើលច្រូត គាត់យកឡានទៅ ហើយយាយខ្ញុំពរកូនខ្ចី, ថា "បោះចោលកូនទៅ! មកជួយរុញឡាន!"។ ស្រែកឱ្យគេជួយរុញឡាន។ យាយហ្នឹងអត់ជួយរុញ។

**ស៖** បាទ។ តើគាត់ជាមនុស្សដែលស្តាប់បញ្ជាថ្នាក់លើ ឬមួយក៏គាត់អត្តនោម័តិដោយខ្លួនគាត់នៅក្នុងការសម្រេចភារកិច្ច បាទ?

**ឆ៖** បាទ អត់មានទទួលផែនការពីលើទេ គឺគាត់សម្រេចអត្តនោម័តិតែខ្លួនគាត់ ធ្វើតែខ្លួនគាត់ចិត្តគាត់តែម្តង។ តាមមើលទៅ អត់មានទទួលផែនការពីលើទេ។ គាត់ជាសមាជិកតំបន់ ហើយគាត់ឯកភាពជាមួយតំបន់ហើយ បានគាត់មកធ្វើ។ អត់មានទទួលផែនការពីលើទេ។

**ស៖** បាទ។ ខ្ញុំបាទសូមចូលសំណួរថ្មី គឺឯកសារ E319/8.2.4 ត្រង់សំណួរទី៣៤។ សំណួរដែលគេសួរថា នៅចំពោះមុខចៅក្រមស៊ើបអង្កេត សំណួរសួរថា "មនុស្សដែលត្រូវបានចាប់ខ្លួន គឺបញ្ជូនទៅសម្លាប់នៅតែកន្លែងមួយ គឺ ព្រៃខ្មោចកូនក្មេង ប៉ុណ្ណោះ។ ក្រោយរបបខ្មែរក្រហមត្រូវបានផ្តួលរលំ គឺគេឃើញមានកន្លែងសម្លាប់មនុស្ស មានច្រើនកន្លែង។ តើលោកពន្យល់រឿងនេះបានដែរឬទេ?

**ឆ៖** បាទ ខ្ញុំ--

**ស៖** បាទ សូមទោសខ្ញុំអត់ទាន់បានសួរ បាទ។ នេះជាសំណួរ ហើយលោកបានឆ្លើយថា៖ "កន្លែងនោះ គឺប្រហែលជាថ្នាក់ឃុំលួចសម្លាប់ប្រជាជនថ្មីដោយខ្លួនឯង។" អ៊ីចឹង ខ្ញុំសូមសួរថា តាមការសង្កេតរបស់លោក ហើយការឆ្លើយរបស់កន្លងមករបស់លោក គឺការសម្រេចសម្លាប់មនុស្សនេះ គឺថ្នាក់ឃុំមិនមានសិទ្ធិទេ។ តើលោកអ៊ីចឹងមែនទេបាទ?

[១០:៤១:៤៥]

**ផ៖** បាទ រឿងសម្លាប់ច្រើនកន្លែងហ្នឹង វាដូចអត់មានផែនការទេ។ អាសម្លាប់ច្រើនកន្លែងហ្នឹង ដូចមេឃុំខ្ញុំថា លួចសម្លាប់ខ្លួនឯងហ្នឹង។ ហើយអាសម្លាប់ផ្លូវការ គឺគេបញ្ជូនទៅតាមខ្សែរយ: យាយខុម ហ្នឹង--

**ស៖** បាទ--

**ផ៖** ប្រគល់ឱ្យ យាយខុម ហ្នឹង--

**ស៖** បាទ

**ផ៖** សូមអស់យោបល់។

**ស៖** អ៊ីចឹង ខ្ញុំសូមបន្តសំណួរខ្ញុំ។ ដែលទាក់ទងនឹងឯកសារលេខ E127/7.1.8 គឺទាក់ទងនឹង សាក្សី ដែលគាត់ធ្លាប់ធ្វើជាមេឃុំនៅឃុំជាងទង។ តើលោកស្គាល់លោក សៅ វ៉ន ទេបាទ?

**ផ៖** បាទ អត់ដែលឮឈ្មោះ អត់ដែលស្គាល់។

[១០:៤២:៥៥]

**ស៖** គាត់ជាអតីតមេឃុំនៅឃុំជាងទង ហើយក្រោយមក ត្រូវបានផ្លាស់ទៅកាន់តំបន់២៥?

**ផ៖** បាទ អត់បានស្គាល់ទេ អត់ដែលឮឈ្មោះផង។

**ស៖** បាទ។ អ៊ីចឹង នៅក្នុងសំណួរ១ចម្លើយទី២៥ គឺគាត់បាន -- គេសួរថា គាត់បានឆ្លើយថា៖ "ក្នុងនាទីខ្ញុំជាគណ:ឃុំ ខ្ញុំមិនមានចិត្តនិន្នា ឈ្នានីសអ្នកណាម្នាក់ដែលធ្វើខុសទេ ប៉ុន្តែថ្នាក់ឃុំ អាចមាន សិទ្ធិរាយការណ៍ទៅឱ្យថ្នាក់លើបានដែរ។ ខ្ញុំមានសិទ្ធិត្រឹមរាយការណ៍ទៅថ្នាក់លើប៉ុណ្ណោះ"។ ហើយខ្ញុំ សូមដកស្រង់បន្ត៖ "ក្នុងបញ្ហានេះ តាម៉ុក បានដាក់បញ្ជាថា ត្រឹមថ្នាក់ឃុំ ស្រុក តំបន់ គឺគ្មានសិទ្ធិបញ្ជា ឱ្យចាប់ ឬសម្លាប់មនុស្សទេ"។ ហើយនៅក្នុងសំណួរ-ចម្លើយទី៧ គាត់ឆ្លើយ១ថា -- (សុំ១ទោស) ទី៩ គាត់ឆ្លើយថា៖ "តាម៉ុក បានធ្វើការប្រកាសនេះ នៅមុនឆ្នាំ៧៥ នៅពេលមានកិច្ចប្រជុំបូកសរុប ដែលត្រូវ បានធ្វើឡើងក្នុងព្រៃមួយឆ្នាំម្តង ដែលមានការចូលរួមពីគណ:ឃុំ ស្រុក ខេត្ត និងកងវរ:។ ក្រោយឆ្នាំ ១៩៧៥ មានការប្រជុំម្តងទៀតនៅទីរួមខេត្តតាកែវ ដែលមាន តាម៉ុក ចូលរួម ហើយឈ្មោះ សោម ដែល ជាគណ:តំបន់១៣ បានធ្វើការប្រកាសថា ហាមប៉ះពាល់ទាហានរបប លន់ នល់ ពីស័ក្តិ១ ដល់ស័ក្តិ៥ មិនត្រូវប៉ះពាល់"។ អ៊ីចឹងតើលោកឯកភាពជាមួយនឹងសក្ខីកម្មរបស់សាក្សីរូបនេះ ដែលថាតំបន់ ស្រុក ឃុំ ពុំមានសិទ្ធិចាប់ និងសម្លាប់មនុស្សទេ ឯកភាពដែរឬទេបាទ?

[១០:៤៥:៣២]

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ រឿងតាម៉ុក ប្រជុំធ្វើអីៗអត់បានដឹងទេ ដឹងតែត្រឹមឃុំ ហើយនិងស្រុក អាហ្នឹងខ្លួនខ្ញុំនៅរស់នៅក្នុងមន្ទីរស្រុក ហើយទាក់ទងទៅនឹងឃុំគេដឹងទាំងអស់ អត់បានឯកភាពជាមួយ(ឮមិនច្បាស់) នេះទេ។

[១០:៤៥:៥២]

**ស៖** បាទ អ៊ីចឹងខ្ញុំសូមបន្តទៅសំណួរថ្មី។ នៅក្នុងសវនាការម្សិលមិញលោកបានផ្តល់សក្ខីកម្មថា៖ "ព្រៃខ្មោចកូនក្មេងនោះ គឺមានកប់ខ្មោចកូនក្មេងនៅមុនឆ្នាំ១៩៧០ ហើយក្រោយឆ្នាំ១៩៧០ មានការសម្លាប់ទាហាន លន់ នល់ នៅទីនោះដែរ" ហើយលោកបានឆ្លើយទៀតថា៖ "នៅដើមឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមចូលឈ្លានពានកម្ពុជា ប្រជាជនបានរត់ចូលទៅព្រៃនោះ ហើយក៏មានការបាញ់សម្លាប់ប្រជាជននៅតំបន់កប់ខ្មោច ព្រៃកប់ខ្មោចកូនក្មេងដែរ" ហើយអម្បាញ់មិញនេះលោកបានបញ្ជាក់ថា៖ "ក្បាលខ្មោច -- ការស្លាប់នៅវាលខ្មោចកូនក្មេងនោះ -- ការកាប់សម្លាប់ (សូមទោស) ការកាប់សម្លាប់នៅទីតាំងឧក្រិដ្ឋកម្ម គឺមានតែនៅព្រៃខ្មោចកូនក្មេងតែមួយប៉ុណ្ណោះ"។ អ៊ីចឹងសំណួរ ខ្ញុំសូមសួរថាតើក្បាលខ្មោចទាំងអស់ដែលនៅព្រៃកប់កូនក្មេងនោះ ជាក្បាលខ្មោចដែលសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ១៩៧៥ ដល់៧៩ ឬក៏ជាក្បាលខ្មោចដែលស្លាប់ទាំងពីមុន៧៥ និងក្រោយថ្ងៃ០៧ មករា ឆ្នាំ១៩៧៩?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ក្បាលខ្មោចពីមុន៧០ គឺគេកប់ គេយកទៅដុត យកទៅបូជា អត់មានចោលលើដីទេ។ អាចោលលើដី គឺសុទ្ធតែក្រោយឆ្នាំ៧០ហ្នឹងទាំងអស់ គ្រប់កន្លែងណាក៏គេចេះតែលួចតែអ៊ីចឹងដែរ។ ហើយបើ យាយខុម គាត់យកទៅសម្លាប់តែមួយកន្លែង ព្រៃខ្មោចកូនក្មេងហ្នឹង អត់ដែលរាយប៉ាយទេ។

[១០:៤៨:២១]

**ស៖** ខ្ញុំសូមបន្តសំណួរ។ កាលពីម្សិលមិញនៅនាទី ប្រហែលជាម៉ោង១ពីរជាង លោកបានឆ្លើយថា នៅឆ្នាំ២០០០ មានការប្រមូលក្បាលខ្មោចពីព្រៃកប់ខ្មោចកូនក្មេងទាំងអស់ យកមកដាក់ជង្រុកនៅក្រាំងតាចាន់។ តើព័ត៌មាននេះលោកដឹងពីអ្នកណាបាទ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបប្រសាសន៍ ខ្ញុំឆ្នាំ២០០៤ ខ្ញុំចេញពីសំឡូតទៅលេងស្រុកតាកែវ ភូមិខ្ញុំនៅភូមិត្រពាំងប្រីយ៍ ឃុំត្រពាំងធំខាងត្បូង គឺជាប់ក្រាំងតាចាន់ហ្នឹង ប្រហែលបួនប្រាំរយម៉ែត្រតែប៉ុណ្ណឹងទេ។ ហើយ -- ហឺ! ភ្លេចហើយ មិនដឹងគាត់សួរអីអំមិញ។

**ស៖** បាទ ខ្ញុំសូមសួរម្តងទៀត។ គឺតើដែលលោកដឹងថា ក្បាលខ្មោចទាំងអស់ដែលប្រមូលបានពីព្រៃកប់កូនក្មេងត្រូវយកទៅដាក់នៅក្នុងជង្រុកនៅក្នុងក្រាំងតាចាន់។ តើព័ត៌មាននេះអ្នកណាជាអ្នកជម្រាបលោក?

[១០:៤៩:៥៧]

**ឆ៖** បាទ ត្រង់ហ្នឹង ខ្ញុំសូមជម្រាបប្រសាសន៍ នៅក្រាំងតាចាន់ហ្នឹង គឺមិនដឹងជាអាជ្ញាធរគេធ្វើជង្រុក ឬប្រជាជនគេឯកភាពគ្នាធ្វើជង្រុក ទៅប្រមូលក្បាលខ្មោចចេញពីព្រៃមកដាក់ក្នុងជង្រុកហ្នឹង។ អាជង្រុកហ្នឹង កន្លែងហ្នឹងគឺព្រៃធាតុ ប្រជាជន ជីដូនជីតាមក គេយកមកធ្វើជង្រុកក្នុងព្រៃខ្មោចហ្នឹង។ ហើយអាក្បាលខ្មោច ព្រៃខ្មោចកូនក្មេងហ្នឹងចម្ងាយពីគ្នា ក្រាំងតាចាន់ និងព្រៃខ្មោចកូនក្មេងហ្នឹង វា៥០ម៉ែត្រហ្នឹងខាងលិចផ្ទល់ ខាងក្រោមផ្ទល់ហ្នឹង ជាប់គ្នា។ ដល់អ៊ីចឹង ក្បាលខ្មោចដែលនៅក្នុងព្រៃស្រមរហ្នឹង គឺប៉ុល ពល សម្លាប់តែមនុស្សធំ។ ដល់អាក្បាលតូចៗហ្នឹង ខ្ញុំឆ្ងល់ អាហ្នឹងមិនមែន៧៩ទេ ប្រជាជនដែលធ្វើការក្នុងជួរ ប៉ុល ពត រែកអម្រែកទៅទាំងគ្រួ ទៅចូលព្រៃឡង់ហ្នឹង។ ដល់៧៩ យួនចូលស្រុក ស្រាប់តែមានក្បាលតូចតាច ក្បាលធំ ក្បាលចាស់ គឺមានពេញព្រៃទាំងអស់។ អ៊ីចឹងហើយមិនដឹងថាអជ្ញាធរ ឬប្រជាជនទេ គេធ្វើជង្រុកប្រមូលមកដាក់ក្រោយឆ្នាំ២000ហ្នឹង។ ខ្ញុំទៅលេងស្រុកៗ ឆ្នាំ២00៤ គេនិយាយប្រាប់គ្រប់គ្នា ខ្ញុំទៅលបមើលឃើញ។

**ស៖** បាទ តើនៅពេលដែលលោកកាន់ការងារនៅពាណិជ្ជកម្មស្រុកត្រាំកក់ លោកមានដែលបានឮ ឬបានឃើញមន្ទីរក្រាំងតាចាន់នេះដែរឬទេ?

**ឆ៖** មន្ទីរកសិកម្ម?

**ស៖** មន្ទីរក្រាំងតាចាន់នេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលលោកបានរស់នៅស្រុកត្រាំកក់នេះ លោកដែលបានឃើញ ឬឮថាមានមន្ទីរក្រាំតាចាន់នេះ ដែរឬទេ?

**ឆ៖** បាទ សូមមានប្រសាសន៍ កាលមុន៧0--

[១០:៥២:00]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោក ហឿន! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមកែតម្រូវ។ អម្បាញ់មិញនេះ គឺថាមន្ទីរហ្នឹង គឺបង្កើតនៅមុនហ្នឹងទៀត គឺមិនត្រឹមត្រូវទេ

ដែលថាបង្កើតនៅក្នុងរបបនោះនោះ។ ហើយមួយទៀត គឺសាក្សីគាត់បាននិយាយរួចហើយកាលពីម្សិលមិញថាគាត់មិនដឹងពីមន្ទីរក្រាំងតាចាន់ហ្នឹងទេនៅក្នុងរបបខ្មែរនោះ ទាល់តែក្រោយមកទេបានគាត់ដឹង។

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន ដើម្បីជាកំណត់ត្រា កាលពីម្សិលមិញសាក្សីបានឆ្លើយនៅក្នុងសវនាការ គឺនៅប្រតិចារឹកត្រង់ម៉ោង១០:១០:០៦ សាក្សីថាគាត់បានដឹងរឿងក្រាំតាចាន់ គឺប្រហែលជាខ្ទង់ឆ្នាំ២០០០ ទៅហើយទេបានគាត់ដឹងពាក់ព័ន្ធនឹងបញ្ហាក្រាំងតាចាន់។ អ៊ីចឹងនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ សាក្សីមិនដែលធ្លាប់បានឆ្លើយពាក់ព័ន្ធទៅនឹងបញ្ហានេះទេ។ សូមអរគុណ។

[១០:៥៣:១៣]

**លោក លីវ សុវណ្ណា៖**

អ៊ីចឹង ខ្ញុំបាទសូមបន្តទៅសំណួរថ្មី។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** លោក ឯក ហឿន លោកធ្លាប់ផ្តល់សក្ខីកម្មថា លោកជាប់និន្នាការដែលមានឪពុកជាមេភូមិពីសង្គមរាស្ត្រនិយម ហើយម្តាយលោកជាជនជាតិវៀតណាម។ តើគេដែលនាំលោកចូលមន្ទីរអប់រំកែប្រែដែរឬទេ ចំពោះការជាប់ពាក់ព័ន្ធនិន្នាការរបស់លោកនេះ?

**ប្រធានអង្គជំនុំ៖**

លោក ឯក ហឿន ស្តាប់សំណួរបានទេ? អត់ឮលោកឆ្លើយ មានបញ្ហាអីទេ?

**លោក ឯក ហឿន៖**

**ឆ៖** ស្តាប់បាន ប៉ុន្តែសូមអានមួយសាទៀត។

**ប្រធានអង្គជំនុំ៖**

មេធាវីតាំងសំណួរចុងក្រោយអំមិញសាជាថ្មីម្តងទៀត!

បើកក្បាលមេក្រូហ្វូន១!

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ដោយសារលោកត្រូវជាប់និន្នាការ តើលោកដែលត្រូវបានគេហៅលោកទៅរៀនសូត្រ ឬអប់រំកែប្រែដែរឬទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ចំពោះនិន្នាការនយោបាយ មិនតែខ្ញុំទេ វាច្រើនណាស់ក្នុងស្រុកមួយៗ ហើយគេអត់ដែលហៅយកទៅចូលសាលាកែប្រែ យកទៅអប់រំ អត់មានអី គេដើរតែថាពួក កា.ហ្សេ.បេ, ពួក សេ.អ៊ី.អា, ពួកអាសក្តិភូមិ នាយទុន គេដើរថាតែអ៊ីចឹង ហើយយើងអ្នកមានខ្លួនចេះតែភ័យខ្លាចហើយ អត់ដែលចូលសាលាកែប្រែ អត់ដែលចូលអប់រំទេ។

**ស៖** ម្សិលមិញលោកបានផ្តល់សក្ខីកម្មថា មានមន្ទីរអប់រំកែប្រែមួយនៅអង្គរកា ហើយអ្នកដែលធ្វើខុស ដូចជាខុសសីលធម៌ជាដើម ត្រូវទៅធ្វើការអប់រំកែប្រែ គឺមិនលើសពីប្រាំមួយខែទេ ត្រូវបានដោះលែងវិញ។ តើលោកដែលបានទៅជិត ឬក៏បានចូលទៅកន្លែងអប់រំកែប្រែនេះញឹកញាប់ដែរឬទេបាទ?

**ឆ៖** បាទ នៅជិតគ្នាប្រហែល១០០ម៉ែត្រជាងហ្នឹង ចេញចូលៗរាល់តែថ្ងៃហ្នឹង ហើយក្រោយមកខ្ញុំវាកាយក៏យ៉ាប់ សោម ដន គេទៅហៅអ្នកទោសហ្នឹងមកធ្វើការជាមួយគ្នាហ្នឹង ហើយអប់រំ។ គេអប់រំថាអ្នកណាខ្ជិល អាហ្នឹងឡើងដល់ប្រាំមួយខែ អាណាឧស្សាហ៍ត្រឹមមួយខែកន្លះហ្នឹង បានទៅផ្ទះវិញហើយ។ ដល់អ៊ីចឹងវាខំធ្វើការទាំងអស់គ្នា បានទៅផ្ទះ អ្នកខ្លះអត់ទៅ ខ្ជិល។

[១០:៥៦:២៥]

**ស៖** បាទ អរគុណ។ ឥឡូវ ខ្ញុំចូលដល់ចំពោះជនជាតិចាម លោកបានផ្តល់សក្ខីកម្មថាការធ្វើការនៅការដ្ឋាន មានទាំងចាម មានទាំងខ្មែរ មានទាំងលោកសង្ឃ។ តើជនជាតិចាមដែលរស់នៅស្រុកត្រាំកក់នោះ និងជនជាតិខ្មែរយើងមានគោលនយោបាយ ឬការណែនាំពីអង្គការឲ្យបែងចែកគ្នាដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលនិយាយរឿងជនជាតិចាម ខ្ញុំថាអត់ដែលមានចាមនៅស្រុក១០៥ ហ្នឹងផងអត់បាននិយាយ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងចូលសំណួរមួយទៀត គឺទាក់ទងនឹងទាហានលន់នល់ អតីតទាហានលន់ នល់ និងអ្នករាជការ។ ទាក់ទងនឹងលោកបានផ្តល់សក្ខីកម្មថាមានទាហាន -- ការប្រមូលផ្តុំនៅវត្តចំប៉ាលើក ហើយមានការស្រង់ប្រវត្តិរូប ហើយលោកបានថ្លែងសក្ខីកម្មពីម្សិលមិញថាមានការប្រមូលទាហាន និងអតីតមន្ត្រីរាជការលន់ នល់ នោះ ដឹកចេញទៅ។ តើលោកមានដឹងថាគេដឹកចេញទៅណាដែរទេ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ចំពោះអ្នកមានបណ្តាស័ក្តិ គេឃោសនាយកៗអ្នកមានបណ្តាស័ក្តិហ្នឹង គេឃោសនាថាអ្នកណាធ្វើជំទប់ ធ្វើមេឃុំ មេភូមិ សូមឲ្យប្រាប់គេ ៗចុះឈ្មោះហើយគេធ្វើ

ការអី គេឲ្យធ្វើការហ្នឹងវិញដដែល ធ្វើជំទប់លេខ១ លេខ២ លេខ៣ គេឲ្យធ្វើវិញ ស័ក្តិ១ ស័ក្តិ២ គេឲ្យធ្វើស័ក្តិ១ ស័ក្តិ២វិញ ឲ្យតែប្រាប់គេ។ ដល់អ៊ីចឹងទៅ ប្រាប់គេទាំងអស់ទៅ ដល់ពេលគ្រប់មួយអាទិត្យហើយ គេធ្វើបញ្ជីហើយអស់ អ្នកត្រូវចេញ គេបញ្ជូនឃើញទិសទៅត្បូង ចេញទៅត្បូង។ ហើយអ្នកប្រជាជនដែលត្រូវចេញតាមភូមិ តាមឃុំ គឺតាមឃុំគេមកយកកម្លាំងហ្នឹងទៅដល់ភូមិផ្ទះគេហ្នឹង។ ឃើញតែប៉ុណ្ណឹងទេ។

**សៈ** បាទ។ អ៊ីចឹងលោកបានឃើញត្រឹមតែគេដឹកចេញទៅខាងត្បូង អ៊ីចឹងមែនទេបាទ?

**ឆៈ** អ៊ីចឹងហើយ ពិតមែនហើយ។

**សៈ** ហើយម្សិលមិញដដែល គឺលោកបានឆ្លើយថា ការស្រង់បញ្ជីប្រវត្តិរូបទាហាន និងអតីតលន់នល់ នៅវត្តចំប៉ាលើក ឃើញតែស្រង់ ប៉ុន្តែគេបានបញ្ជូនទៅភូមិ ឃុំ លោកឃើញទៅដល់ភូមិ ឃុំ។ ចុះសក្ខីកម្មរបស់លោកត្រង់នេះ យ៉ាងម៉េចដែរលោក?

[១០:៥៩:៤៦]

**ឆៈ** បាទ ត្រង់ហ្នឹង ខ្ញុំអត់យល់ទេ ព្រោះអត់ដែលឃើញស្រង់បញ្ជីបញ្ជូនមកឃុំផង បើគេស្រង់បញ្ជីបាន ស្រុកគេយកទៅត្រួតពិនិត្យរបស់គេច្បាស់ហើយបានគេផ្ញើមកឃុំវិញ។ អាហ្នឹងចេញរាងបញ្ច្រាស អត់បានដឹងទេ។

**សៈ** កាលពីម្សិលមិញ លោកបានផ្តល់សក្ខីកម្មថាកម្មាភិបាលដែលធំជាងគេនៅទីនោះគឺមានតែលោក សោម ដន ដែលជាបងប្អូនជីដូនមួយជាមួយលោក ហើយនិង ហើយគ្មានវត្តមាន តាម៉ុក ឬយាយខុម ទេ។ ហើយបន្ថែមពីនេះ លោកបានមានប្រសាសន៍ថា លោកបានទៅទីនោះតែមួយម៉ោងទេ លោកមិនដឹងរឿងអ្វីច្រើនទេ។ ចុះហេតុអ្វីបានជាពេលនេះ លោកឆ្លើយថាមានការស្រង់ប្រវត្តិរូបទាហាន និងអតីតមន្ត្រីរាជការ ជំទប់ ហើយដឹកទៅត្បូង?

**ឆៈ** បាទ ត្រង់ហ្នឹងដូចអត់ដែលបានដឹងទេ នៅត្រង់បញ្ជីធ្វើអីគេអត់ដែលប្រកាសប្រាប់យើងទេ គេលួចធ្វើស្ងាត់ៗតែគ្នាគេទេ អត់ដឹង អត់ដែលបាននិយាយផង។

**សៈ** អ៊ីចឹងខ្ញុំសូមបញ្ជាក់ឡើងវិញថា លោកមិនបានពីការស្រង់ឈ្មោះអតីតទាហាន លន់ នល់ និងអតីតអ្នករាជការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងទីតាំងវត្តចំប៉ាលើកទេ។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ ពិតណាស់ត្រង់ហ្នឹង គេទៅធ្វើកន្លែងគេដែលប្រមូលប្រជាជនមកនៅស្នាក់នៅហ្នឹង គេធ្វើបញ្ជីចប់សព្វគ្រប់ហើយ បានគេបញ្ចេញទៅតាមឃុំហើយ។ ហ្នឹងពិតហើយ។

[១១:០២:០៧]

**ស៖** ឥឡូវខ្ញុំសូមតាំងសំណួរថ្មី គឺទាក់ទងការប្រព្រឹត្តិទៅលើជនជាតិវៀតណាម។ តើលោកដែលបានឃើញបញ្ជីឈ្មោះជនជាតិវៀតណាម ឬអតីតទាហាន ឬអ្នករាជការលន់ នល់ ដែរឬទេ?

**ឆ៖** បាទ អត់ដែលឃើញទេ បើប្រជាជនសុទ្ធ គេចេញពីបន្ទាយមក គេយកទៅនៅក្នុងភូមិក្នុងស្រុកហ្នឹង ឃើញ។ ដូចជនជាតិវៀតណាមជាតិអី គេមិនដែលធ្វើបញ្ជីធ្វើអីឲ្យយើងដឹងឲ្យយើងឃើញទេ អត់ដឹងទេ។ ប៉ុនដល់ពេលគេយកទៅសម្លាប់ បានឃើញគេដឹកឡាន ហើយឈ្មោះ ឡូន ម៉ូញ ហ្នឹងវានៅក្នុងមន្ទីរស្រុកដែរ។ ឡូន ម៉ូញ ហ្នឹងត្រូវប្អូនថ្លៃ តាម៉ុក គេយកឡានអាវែងទៅដើរដឹក ស្រុកសម្រេចឲ្យឃុំប្រមូលដាក់មួយកន្លែង កំណត់មួយអាទិត្យគេដឹក យកឡានទៅដឹកចេញ "ឲ្យទៅស្រុក" គេថាអ៊ីចឹង។ ហើយដល់ ឡូន ដឹកហើយ ខ្ញុំទៅជួប ឡូន ខ្ញុំសួរថា ឡូន ប៉ុនខ្ញុំអត់ហៅ ឡូន ហ្នឹងហៅឈ្មោះវា អាម៉ូញ អាឡូន ហ្នឹងគេហៅតែ អាម៉ូញៗទេ។ ខ្ញុំសួរថា "អាម៉ូញ ហ្អែងដឹកគេបានប៉ុន្មាននាក់? វាថា ៩០០០"។ ៩.០០០ ហ្នឹងខ្ញុំអត់បានបញ្ជាក់ថា ៩.០០០នាក់ ឬក៏៩.០០០គ្រួសារ អត់បានបញ្ជាក់ត្រង់ហ្នឹង។ វាថា ៩.០០០។ អ៊ីចឹង ៩.០០០ ហ្នឹង វាយកទី១ ឃុំពពេល, ទី៣ តាភេម, ទី៤ អង្គតាសោម, ទី៥ ស្រែរនោង, ទី៦ លាយបូរ។ ប្រាំមួយឃុំហ្នឹង ឡូន ដើរយកប្រាំមួយឃុំហ្នឹងបាន៩.០០០ មិនដឹង ៩.០០០គ្រួសារ ឬ៩.០០០នាក់ អត់ដឹង។

[១១:០៤:៣៥]

**ស៖** បាទ។ ខ្ញុំសូមតាំងសំណួរបន្ត។ តើលោកបានឃើញគេសម្លាប់ជនជាតិវៀតណាមទាំងនោះផ្ទាល់ភ្នែកដែរឬទេ?

**ឆ៖** បាទ អត់បានឃើញទេ បើឃើញគេដឹកឡានហ្នឹង ឃើញ។ ឃើញខ្ញុំដើរធ្វើការវាស់ប្រឡាយ ធ្វើក្រសួងសុរិយោដីហ្នឹង ឃើញឡានគេរត់កាត់មុខអ៊ីចឹង ឃើញៗពេញៗឡាន។ គេដឹកទៅដល់ផ្លូវបែកគុស គេបត់ទៅផ្លូវជាតិលេខ៣ ស្រាប់តែជនជាតិវៀតណាមហ្នឹងយំ យំទាំងអស់ពេញលើឡាន។ គេថាបើទៅស្រុកយួន ហេតុអីមិនទៅតាមផ្លូវ៣១ៗទៅត្បូងត្រង់ ស្រាប់តែទៅលិច គេថាផ្លូវហ្នឹង គេថាផ្លូវហ្នឹង នែ៎អ្នកដឹកទៅគេថាផ្លូវហ្នឹង(ឮមិនច្បាស់) ឮសួរអីវ៉ាៗហ្នឹង អ៊ីចឹងទៅផ្លូវវាង។ ទៅផ្លូវវាងទៅបាត់អស់ទៅ។ ខ្ញុំសួរ ឡូន ម៉ូញ វាថាអ៊ីចឹង។ ហើយឃើញនឹងភ្នែកគេដឹកទៅផ្លូវជាតិលេខ៣ ហ្នឹង ផ្លូវហ្នឹងបត់ទៅលិច។ ផ្លូវ៣១ ទៅត្បូងទៅតានី។

**ស៖** តើលោកដែលបានឃើញសាកសពរបស់ជនជាតិវៀតណាមបន្ទាប់ពីត្រូវបានគេសម្លាប់

ដែរឬទេ?

**ធ៖** អត់បានឃើញទេ គេយកទៅសម្លាប់ក្នុងព្រៃភ្នំឯណោះ យើងអត់បានដើរដល់ភ្នំទេ អាណាទៅភ្នំអត់មានការងារអីនោះ ព្រោះកុនខ្លួនដែរ។ ដល់ទៅធ្វើក្រសួងសុរិយោដី ដើរកាត់វាលស្រែ ក្នុងភូមិ ក្នុងផ្ទះ អត់ដែលឃើញទេ។

**ស៖** បាទ ចុះលោកដឹងថា គេសម្លាប់ជនជាតិវៀតណាមនៅភ្នំនេះ ដោយរបៀបណា?

**ធ៖** បាទ រឿងវិធីគេសម្លាប់ អត់ដឹងដែលហ្នឹង មិនដឹងគេធ្វើវិធីណាអត់ដឹង។

**ស៖** អ៊ីចឹងព័ត៌មានដែលថា សម្លាប់ជនជាតិវៀតណាមនេះ លោកបានពីណាមកដែលបាទ?

**ធ៖** បាទ អាហ្នឹងខ្ញុំឃើញនឹងភ្នែក ខ្ញុំនៅក្នុងមន្ទីរហ្នឹង ឃើញតាចាយ ប្រជុំៗ ទាំងយប់ហ្នឹង។ ដល់ស្អែកឡើងបានថាឲ្យ ឡួន ហ្នឹងទៅប្រាប់គ្រប់ឃុំថា ឲ្យមេឃុំហ្នឹងប្រមូលជនជាតិវៀតណាមដាក់មួយកន្លែង ហើយ ឡួន ឯងយកឡានទៅដឹកទៅ។ ដល់ប្រមូលបានថាមួយអាទិត្យទៅដឹក ឡួន ហ្នឹងយកឡានទៅដឹកទៀតទៅ។ អាហ្នឹង តាចាយ ប្រជុំ ហើយព្រឹកឡើងឃើញ ឡួន ទៅប្រាប់តាមឃុំ អ៊ីចឹង។ ឡួន ហៅ ម៉ូញ ហ្នឹង ឥឡូវនៅអន្លង់វែងឯណោះ។

[១១:០៧:១៧]

**ស៖** អ៊ីចឹងលោកបានចូលរួមអង្គប្រជុំនោះដែរ មែនទេ?

**ធ៖** អត់បានទេ គ្រាន់តែគេប្រើឲ្យយកទឹកតែ ទឹកក្ដៅទៅជូនគេអ្នកប្រជុំហ្នឹងបាន។ បើឲ្យប្រជុំ គេអត់ឲ្យចូលទេ មនុស្សនិន្នាការនយោបាយគេ។ គ្រាន់ថាលួចស្ដាប់ហ្នឹង ដឹង។

**ស៖** អ៊ីចឹងមានន័យថា លោកដឹងត្រឹមឲ្យ ឡួន នោះទៅប្រមូលប្រជាជនវៀតណាមដឹកឡាន។ តើអ៊ីចឹងមែនទេ បាទ?

**ធ៖** បាទ ពិតណាស់អាហ្នឹង ឡានវែង។

**ស៖** ហើយឯការកាប់សម្លាប់ប្រជាជនវៀតណាមនោះ លោកមិនបានដឹងទេ។ អ៊ីចឹងមែនទេ?

**ធ៖** បាទ។

[១១:០៨:០២]

**ស៖** លោកបានផ្ដល់សក្ខីកម្មពីម្សិលមិញថា បើប្ដីដែលមានប្រពន្ធវៀតណាម ឬប្រពន្ធខ្មែរដែលមានប្ដីជាជនជាតិវៀតណាម និងកូនៗរបស់ពួកគាត់ត្រូវយក ដឹកយកទៅទាំងអស់។ ដោយឡែកខ្ញុំមានចម្ងល់មួយ តើឪពុកនិងម្ដាយរបស់លោកមានជោគវាសនាដូចគេដែរឬទេ? ព្រោះម្ដាយលោកជាជនជាតិ

វៀតណាម?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ត្រង់ហ្នឹងគឺគេថា កង់ប្រវត្តិសាស្ត្រត្រូវតែកិនហើយ ប៉ុន តាយាយហ្នឹងចាស់ហើយទុកឲ្យគាត់ងាប់ខ្លួនឯងទៅ។ ហ្នឹងយាយខុម ថាផ្ទាល់មាត់អ៊ីចឹងវាអត់សម្លាប់។

**ស៖** ចុះលោក និងបងប្អូនលោកដែលជាកូនរបស់ម្តាយជាជនជាតិវៀតណាម តើគេយកទៅសម្លាប់ដែរឬទេ?

**ឆ៖** បាទ អាប្អូនពៅខ្ញុំមួយគេដាក់គុកតាំងពី ៧៣ដល់ ៧៦ បានលែង។ គេថា ម៉ែយួនហ្នឹងមានគេប្តឹង ទៅជាប់គុកនៅខេត្តកំពង់សោម ឆ្នាំ៧៣ វាទៅហ្នឹង។

**ស៖** អ៊ីចឹងមានន័យថា កាលណាមានម្តាយជាជនជាតិវៀតណាម កូនត្រូវទទួលទណ្ឌកម្មយកទៅដាក់គុក មិនមែនយកទៅសម្លាប់ទេ។ តើអ៊ីចឹងមែនទេ បាទ?

[១១:០៩:៥២]

**ឆ៖** បាទ អត់មានដាក់គុកទេ។ គេអត់ធ្វើអីផង ប៉ុន្តែគេគ្រាន់តែដើរថា ថាយួន ថាខ្មែរអ៊ីចឹងទៅ គេអត់ដាក់គុក អត់ដាក់សាលាកែប្រែទេ។ បើវៀតណាម ប្តីប្រពន្ធកូនយួនអី ខ្មែរអី និយាយតែយួន រាល់តែថ្ងៃហ្នឹង អាហ្នឹងគេចាប់ទៅអត់បាច់សួរទេ។ ចាប់ទៅទាំងសំបុកៗទាំងអស់ហ្នឹង។ អត់មាននៅសល់បន្តិចទេ យកទាំងអស់ៗហ្នឹង។

**ស៖** លោកមានដែលបានដឹងថា មានការដូរជនជាតិវៀតណាមដែលរស់នៅស្រុកខ្មែរជាមួយជនជាតិខ្មែរដែលរស់នៅស្រុកវៀតណាមដែរឬទេ បាទ?

**ឆ៖** បាទ កាលជំហានទី១ តាម៉ុក ប្រមូលជនជាតិវៀតណាមហ្នឹងទៅដូរអ៊ីចឹងហើយ ដល់តែដូរមកវាដាច់ យកមកដល់ស្រុកខ្មែរអត់មានអីហូប ដល់អត់អីហូប យប់ឡើងដើរលួចដំឡូង លួចមាន់ លួចទាគេស៊ី។ អ៊ីចឹង តាម៉ុក លែងដូរៗ រហូតទៅ។

**ស៖** សូមអរគុណ បាទ។ សុំអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។

[១១:១១:២០]

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជម្រាបសួរលោក ឯក ហឿន។ លោកស្តាប់ខ្ញុំឮទេ? លោក ឯក ហឿន ជម្រាបសួរ!

**លោក ឯក ហឿន៖**

**ឆ៖** បាទ ជម្រាបសួរ។

**ស៖** ខ្ញុំឈ្មោះ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន។ ហើយតទៅនេះ ខ្ញុំមានសំណួរមួយចំនួន។ ដំបូងខ្ញុំចង់សួរលោកទាក់ទងទៅនឹងប្រវត្តិរូបរបស់លោក។ អម្បាញ់មិញនេះ លោកបានជម្រាបហើយថា ម្តាយរបស់លោកជាជនជាតិយួន ហើយពីម្សិលមិញ ខ្ញុំស្តាប់បានថាលោកមានជីតាជាជនជាតិយួនដែលមិនចេះភាសាខ្មែរទេ ហើយជីតាហ្នឹងគឺជាជីតាខាងម្តាយ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយត្រង់ហ្នឹងនោះ ព្រោះខ្ញុំកើតមកឃើញតែតាខ្ញុំ អត់ចេះខ្មែរផង ហើយម៉ែខ្ញុំចេះយួនមួយម៉ាត់ៗ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថាម្តាយរបស់លោកដែលលោកបានជម្រាបពីខាងដើមថា ឈ្មោះ ណាំ ហង គាត់កើតនៅស្រុកខ្មែរ ហើយរស់នៅស្រុកខ្មែររហូត ឬមួយក៏គាត់មានពេលណាមួយរស់នៅប្រទេសវៀតណាម ឬក៏ប្រទេសដទៃទៀត?

**ឆ៖** បាទ គាត់កើតនៅស្រុកខ្មែរ។ យាយខ្ញុំក៏នៅស្រុកខ្មែរ។ ខ្មែរសុទ្ធ យាយខ្ញុំ។ ហើយគាត់អត់ដែលទៅលេងស្រុកកំណើតខាងតា ខាងយាយទេ។ គាត់នៅក្នុងប្រទេសរហូតដល់គាត់អស់អាយុស្លាប់។

[១១:១៣:១០]

**ស៖** បាទ សុំអរគុណ។ លោកអាចបញ្ជាក់បានទេ ភូមិ ឃុំ ស្រុក ខេត្តណា ដែលម្តាយរបស់លោករស់នៅ?

**ឆ៖** រស់នៅសព្វថ្ងៃនៅ ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ។ ហើយកាលពីកំណើតយាយតាខ្ញុំគាត់នៅខេត្តចូវដុក ហៅក្របៅមាត់ជ្រូក មិនដឹងភូមិអី ឃុំអី អត់ដឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់លោកថា ម្តាយរបស់លោករស់នៅទីតាំងដែលលោកបានរៀបរាប់អម្បាញ់មិញនេះតាំងពីមុនឆ្នាំ៧០ និងមុន៧៥ រហូតក្រោយមកដល់ក្រោយឆ្នាំ៧៥ ទៀត។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើម្តាយរបស់លោកមានពេលណាដែលចាកចេញពីកន្លែងដែលគាត់រស់នៅហ្នឹងទេ?

**ធ៖** បាទ អត់មានចេញទៅណាឆ្ងាយពីផ្ទះទេ គាត់ក្រនោះក្រ នៅតែក្នុងផ្ទះក្នុងភូមិហ្នឹង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងបងប្អូនរបស់លោក លោកបានជម្រាបអង្គជំនុំជម្រះរួចហើយ អំពីបងប្រុសរបស់លោកឈ្មោះ តាហេង ដែលជាប្រធានកងពលដែលបានស្លាប់នៅពេលទម្លាក់គ្រាប់បែកឆ្នាំ៧៣ ហើយនិងឈ្មោះ តាយ៉ែវ?

**ធ៖** តាយ៉ែវ។

**ស៖** អ៎! តាៗ តាយ៉ែវ ដែលជាអនុស្រុក នៅស្រុកកោះអណ្តែត។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ធ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា តាយ៉ែវ ជាបង ឬក៏ជាប្អូនរបស់លោក?

**ធ៖** បាទ តាយ៉ែវ, តាហេង គឺបង។

**ស៖** បាទ សម្រាប់ តាយ៉ែវ គាត់ធ្វើជាអនុស្រុកកោះអណ្តែតហ្នឹងពីឆ្នាំណា ដល់ឆ្នាំណា? លោកអាចបញ្ជាក់បានទេ?

[១១:១៥:៥៧]

**ធ៖** បាទ កាលខ្ញុំបានដឹងគាត់ឡើងក្នុងឆ្នាំ៧៨ ជាមួយ តាសឿន ឪអាល្អួស ហ្នឹង។ ឡើងដំណាល តាសឿន ហ្នឹង ឡើងធ្វើអនុស្រុកហ្នឹង។ ចាប់គេបីនាក់ហ្នឹងទៅ ពួកហ្នឹងអង្គុយកៅអីគេហ្នឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា ចាប់អ្នកណាគេបីនាក់?

**ធ៖** បាទ អត់ស្គាល់ទេ ប៉ុនគ្រាន់តែឃើញតែរូប គេចង់នៅលើឡាន អត់ស្គាល់ឈ្មោះផង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា លោកមានបងប្អូនដទៃទៀត ដែលធ្វើការជាកម្មាភិបាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរទេ? ខ្ញុំចាំបានថាលោកមានបងប្អូនជីដូនមួយឈ្មោះ ដន។

**ធ៖** បាទ ពិតណាស់ ខ្ញុំមានបងប្អូនបង្កើត គឺពីរនាក់ តាយ៉ែវ, តាហេង ហ្នឹង។ ហើយពីនោះបន្ទាប់មក មានប្អូនជីដូនឈ្មោះ សោម ដន ប្រធានមន្ទីរស្រុកត្រាំកក់ហ្នឹង។

**ស៖** បាទ មានៗបងប្អូនផ្សេងទៀតទេ?

**ធ៖** បាទ អត់មានទេ។

**ស៖** សម្រាប់រូបលោកផ្ទាល់ តើលោកមានមិត្តភក្តិជិតដិតដែលជាកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងស្រុកត្រាំកក់ដែរទេ?

**ផ៖** បាទ អត់ទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរលោកពីប្រវត្តិផ្ទាល់ខ្លួនរបស់លោកវិញ។ លោកបានបញ្ជាក់រួចហើយថា លោកបាននៅក្នុងស្រុកត្រាំកក់ ក្នុងដំណាក់កាលដំបូង មុនៗឆ្នាំ៧៥ លោកបានធ្វើជាមេក្រុម។ នេះជាសម្ដីចុងក្រោយដែលលោកបានបញ្ជាក់នៅក្នុងបន្ទប់សវនាការនេះ។ ហើយក្រោយមកលោកបានទៅនៅជាមួយផ្ទះ តាជឹម។ ខ្ញុំចង់បញ្ជាក់ថា តើលោករស់នៅក្នុងផ្ទះ តាជឹម ហ្នឹង គឺចាប់ពីខែឬឆ្នាំណាដែរ លោកអាចបញ្ជាក់បានទេ?

[១១:១៨:៥០]

**ផ៖** បាទ ទី១ ខ្ញុំចង់បញ្ជាក់ថាឆ្នាំ៧៣ គេឲ្យខ្ញុំធ្វើប្រធានក្រុម ដល់តែគេបែងចែកវណ្ណៈទៅគេដកសិទ្ធិខ្ញុំ លែងឲ្យធ្វើអីហើយ ហើយយាយខុម ចេះតែបញ្ចេញចង្កូមដាក់រកតែសម្លាប់ខ្ញុំ។ ដល់តែអ៊ីចឹង តាជឹម យកទៅលាក់នៅផ្ទះគាត់ កុំឲ្យ យាយខុម ទៅរកឃើញ។ ដល់៧៦ បាន យាយខុម ហ្នឹងទៅរកខ្ញុំឃើញ។ សូមជម្រាបខ្លីប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បន្ថែមទាក់ទងទៅនឹងរយៈពេលដែលលោកទៅនៅផ្ទះតាជឹម លោកបានបញ្ជាក់រួចហើយថា តាជឹម គឺជាបងប្អូនថ្លៃរបស់លោក។ ខ្ញុំចង់សួរថា នៅពេលដែលលោកនៅផ្ទះ តាជឹម ហ្នឹង លោកធ្វើអ្វី?

**ផ៖** បាទ គាត់គឺឲ្យខ្ញុំទៅនៅ ពេលយាយខុម សម្គុតខ្ញុំនៅមន្ទីរស្រុកហើយ តាជឹម ថ្ងៃហ្នឹងចូលទៅដល់ សោម ដន ថា "យាយខុម មកសម្គុតទាំងវា ទាំងបងហឿន"។ សម្គុតថា "ពូនេះនៅឯណា?" ហើយ សោម ដន ឆ្លើយថា "ប្អូនលោក ពូជឹម។ ជឹមណា?" ហើយគេដើរអេះគូទព្ញខ្វែកៗចេញទៅវិញ។ បានមួយសន្ទុះ តាជឹម មកដល់ថា យាយខុម មកសម្គុតទាំងវាទាំងអី ហើយដល់ឮថាសម្គុតអ៊ីចឹង តាជឹម ដឹងថា យាយខុម មកចាប់តាហ្នឹងហើយ។ អ៊ីចឹង តាជឹម យកទៅលាក់នៅផ្ទះគាត់។ បានតែពីរថ្ងៃ គាត់ឲ្យខ្ញុំទៅចូលខាងក្រសួងសុរិយោដីទៅ។

[១១:២០:៣២]

**ស៖** បាទ អ៊ីចឹងខ្ញុំសូមបញ្ជាក់ឡើងវិញ គឺលោកបានទៅផ្ទះ តាជឹម ហ្នឹងតែក្នុងរយៈពេលពីរថ្ងៃទេ ហើយទៅៗលាក់ខ្លួន។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ផ៖** បាទ ត្រឹមត្រូវ។

**ស៖** ចុះនៅពេលដែល -- ឥឡូវខ្ញុំចង់សួរបញ្ជាក់ពីផ្ទះ តាជឹម វិញ។ តើលោកចាំបានទេថា

ទីតាំងផ្ទះ តាជឹម ហ្នឹងនៅកន្លែងណា?

**ឆ៖** បាទ ផ្ទះ តាជឹម ក៏អត់មានទិសកំណត់ទេ។ គាត់មួយខែនៅនេះ មួយខែនៅនោះ ផ្ទះណាទំនេរគាត់ទៅនៅ ដែលគាត់ទៅនៅ ដែលខ្ញុំទៅនៅហ្នឹង នៅខាងជើងៗវត្តគុស ខាងលិចផ្លូវបំបែក អាផ្លូវចូលវត្តគុសពីខាងជើងហ្នឹង ផ្ទះថ្មគេហ្នឹង។ នៅបានតែពីរបីខែ ៧៧ ខែ៣ គាត់ផ្លាស់មកស្រុកគេ ពាយ័ព្យបាត់អស់មក ហើយខ្ញុំចូលក្រសួងសុរិយោដីរហូតទៅ។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់អំពីផ្ទះ តាជឹម ដែលលោកបានទៅស្នាក់នៅពីរថ្ងៃហ្នឹងនៅវត្តគុស វត្តគុសហ្នឹងនៅក្នុងឃុំគុស អ៊ីចឹងមែនទេ? ហើយភូមិអីដែរ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ឈ្មោះភូមិអីដែរលោក?

**ឆ៖** បាទ មិនឃុំគុសទេ ដូចញ៉ៀងញ៉ងមួយចំហៀង ញ៉ៀងញ៉ង។ ឃុំញ៉ៀងញ៉ង ចុងខាងកើត។ ខាងកើតផ្លូវលេខ១ទៅត្បូង អាហ្នឹងឃុំគុសហើយ។

**ស៖** បាទ សូមអរគុណ។ ចុះពីឃុំគុសហ្នឹងទៅផ្ទះរបស់ យាយខុម មានចម្ងាយពីគ្នាប៉ុន្មានដែរ?

**ឆ៖** បាទ ឆ្ងាយ ប្រហែល១០គីឡូជាង ទៅក្រាំងតាចាន់ហ្នឹងទៅដល់ភូមិខ្ញុំឯណោះ។

[១១:២២:២៨]

**ស៖** បាទ សូមអរគុណ។ ឥឡូវនិយាយអំពីការងាររបស់លោក ដែលលោកថា លោកនៅបានតែពីរថ្ងៃទេ នៅលាក់ខ្លួននៅផ្ទះ តាជឹម ហើយក្រោយមកលោកចេញទៅធ្វើការនៅមន្ទីរសុរិយោ -- នៅក្រសួងសុរិយោដី។ លោកអាចបញ្ជាក់ឲ្យបានច្បាស់ទេថា គេហៅអ្វីដែរ? ជាក្រសួងសុរិយោងដីអ៊ីចឹងឬមួយក៏ជាកង ជាក្រុមស្អីមួយផ្សេងទៀត?

**ឆ៖** បាទ គេឲ្យឈ្មោះថា "ពួកវាស់វែងប្រឡាយ" ទៅធ្វើប្រឡាយដូចក្រឡាវែកអ៊ីចឹង ធ្វើពីស្រុក -- ចុងស្រុកខាងជើងទៅទល់ចុងស្រុកខាងត្បូង ចុងស្រុកខាងកើតមកទល់ស្រុកខាងលិច ឲ្យដូចក្រឡាវែកអ៊ីចឹង ពួកវាស់វែងដីហើយ។

**ស៖** បាទ សូមអរគុណ។ លោកចាំបានថា អ្នកណាជាមេរបស់លោកទេ?

**ឆ៖** បាទ មេដែលក្រសួងសុរិយោដីហ្នឹងគឺមាន ប៊ុន យ៉េន ដែលប្រធានមន្ទីរ តាជឹម ហ្នឹង។ គេខាងសិស្សថ្នាក់ទីបញ្ចប់ គេមានបច្ចេកទេសវាស់វែង ស្ទង់ទាបខ្ពស់អី វាស់តាមខ្សែស្របក្នុងខ្សែផែនទីធ្វើត្រង់ភ្លឹងដូចខ្សែបន្ទាត់អ៊ីចឹង។ ហើយខ្ញុំបានតែលីបង្គោលឲ្យគេទេ លីបង្គោលឲ្យគេ កាប់ឫស្សី ពុះឲ្យគេ

ហ្នឹង។ ធ្វើបានតែត្រឹមហ្នឹង។

**ស៖** បាទ សូមអរគុណ។ មានឈ្មោះជាកង ជាក្រុមអីទេ ក្នុងការងារដែលក្រោមការដឹកនាំរបស់ តាជឹម ហ្នឹង?

**ឆ៖** បាទ មានកងក្រុម ដូចក្រុមវាស់ប្រឡាយហ្នឹង គឺមាន ប៊ុន យ៉េន ហ្នឹងគេធ្វើមេក្រុមហើយនៅលើគេវាស់វែងអី ហើយប្រធានមន្ទីរគេអ្នកក្ដាប់ផ្ទាល់ហើយក្រសួងហ្នឹង។

[១១:២៤:៤០]

**ស៖** លោកអាចបញ្ជាក់ថា មានគ្នាប៉ុន្មាននាក់ដែរនៅក្នុងក្រុមវាស់វែងដីរបស់លោកហ្នឹង?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថាគេសុំតាមឃុំ មួយឃុំមួយៗ ហើយមាន១៥ឃុំ វាមាន១៥នាក់ដែរ។ ហើយខ្ញុំនៅក្នុងមន្ទីរស្រុក, យ៉េន នៅក្នុងមន្ទីរស្រុក វា១៧ -- ១៨ មានគ្រូមួយទៀត វា១៨នាក់ក្នុងមួយក្រុមហ្នឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីកាលបរិច្ឆេទបានទេ ពីថ្ងៃណា ដល់ថ្ងៃណា ដែលលោកធ្វើការនៅក្នុងក្រុមវាស់វែងហ្នឹង?

**ឆ៖** បាទ រឿងហ្នឹងធ្វើតាំងពីឆ្នាំរំដោះទូទាំងប្រទេសហើយ គឺគេរៀបចំធ្វើទំនប់ប្រឡាយហ្នឹងដូចក្រឡាវែកអីចឹង ចាប់ផ្ដើមតម្រង់ហើយ តម្រង់ស្រុកខាងជើង ទៅទល់ស្រុកត្បូង ស្រុកកើត មកទល់ស្រុកលិច ដូចក្រឡាវែកដី ប្រជាជនប្រឹងណាស់ អូ!វែកទាំងយប់ទាំងថ្ងៃ រហូតមកដល់៧៥-៧៦ នៅតែសម្រុក ៧៩បានចប់ ចប់នៅ៧៩។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ឡើងវិញថា លោកនិយាយថាចប់នៅ៧៩ហ្នឹង បានន័យថា នៅពេលដែលលោកចាកចេញពីត្រាំកក់ ទៅកំពង់ចាម ការងារហ្នឹងមិនទាន់ចប់ទេ គេនៅធ្វើនៅឡើយ។ តើអីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១១:២៦:៣៥]

**ស៖** លោកអាចបញ្ជាក់បានទេថា កន្លែងដែលលោកវាស់វែងហ្នឹងមានឈ្មោះអ្វីដែរ? ជាទំនប់ជាប្រឡាយ ឬជាអ្វីដែលមានឈ្មោះដែរទេ?

**ឆ៖** បាទ សុទ្ធតែមានឈ្មោះ ដូចទប់ទំនប់បឹងខ្ពបត្របែក ក៏គេដាក់ឈ្មោះបឹងខ្ពបត្របែកហ្នឹងហ៎! ដាក់ទំនប់មួយទៀត គេដាក់ឈ្មោះទំនប់យាយខុម អាកន្លែងជិតផ្ទះយាយខុមហ្នឹង គេហៅ "ទំនប់

យាយខុម" ហើយទំនប់មួយទៀតនៅជិតផ្ទះខ្ញុំ គេហៅថា "ទំនប់តាម៉ា" ហើយអាទំនប់ហ្នឹងវាស្អែកស្អះទៅ ក្នុងស្រុក អាខ្សែប្រឡាយហ៊ុមព័ទ្ធខ្វាត់ខ្វែងហ្នឹង គឺអត់មានឈ្មោះទេ ហើយជីកប្រឡាយចេញពីខ្ពបត្របែកទៅផ្លូវជាតិលេខ៣ ទៅត្បូងហ្នឹង វាមាន២០គីឡូ គេដាក់ប្រឡាយ០២។ ហើយចែកចេញពីប្រឡាយ០២ហ្នឹងទៅដល់កំពង់អំពិល ស្រុក១០៨ គឺគេដាក់ប្រឡាយ០១ ប្រឡាយហ្នឹងធំៗណាស់ មាត់លើ២០ម៉ែត្រឯណោះ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់លោកថា តើឈ្មោះប្រឡាយ ទំនប់ ដែលលោកបានរៀបរាប់អម្បាញ់មិញនេះ សុទ្ធតែជាទំនប់ប្រឡាយដែលលោកបានទៅវាស់ដោយផ្ទាល់ ឬមួយក៏មានទំនប់ខ្លះ លោកមិនបានចូលរួមវាស់វែងទេ?

**ឆ៖** បាទ ចាប់ពី៧៥ទៅ គឺក្រសួងហ្នឹងគេដើរវាស់ ធ្វើប្រឡាយ គេទៅស្ទង់ ស្ទង់លើកទំនប់កម្ពស់ប៉ុន្មាន គេស្ទង់ដឹង គេរាយការណ៍មកស្រុក ស្រុកកត់ត្រាទុក។ ហ៎! ដូចវាស់ប្រហែលពីកល់កូនទៅស្រុក១០៨ហ្នឹង គេធ្វើហើយ គេយកបញ្ជើហ្នឹងមកឲ្យស្រុក។ ប្រឡាយធំៗហ្នឹង សុទ្ធតែយកបញ្ជើមកឲ្យស្រុក ថាកន្លែងណាវាង កន្លែងណាត្រូវបុក ដល់ពេលហ្នឹងមានភូមិក្នុង--

[១១:២៨:៣៨]

**ស៖** លោក ឯក ហឿន ខ្ញុំសូមកាត់ សូមអធ្យាស្រ័យ។ ខ្ញុំចង់សួរថា តើលោកបានចូលរួមក្នុងការវាស់វែងប្រឡាយទាំងអស់នោះទេ ដែលលោកបានរៀបរាប់អម្បាញ់មិញ?

**ឆ៖** បាទ ចូលរួមគ្រប់ប្រឡាយ គ្រប់ទំនប់ទាំងអស់។

**ស៖** បាទ សូមអរគុណ។ មានប្រឡាយណាដែលគេធ្វើមុនពេលលោកទៅចូលរួមដែរឬទេ?

**ឆ៖** បាទ មុនហ្នឹងអត់មានទេ មានតែទំនប់អូរចាស់ អូរ ត្រពាំងចាស់អីហ្នឹង គេអត់ជួសជុលផង ធ្វើថ្មី។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកទៅនៅវាស់វែងដី ធ្វើទំនប់ប្រឡាយ លោកដែលមានជួបជាមួយ យាយខុម ទៀតទេ?

**ឆ៖** បាទ អត់ដែលជួបទេ យាយខុម ៧៦ ខែ៣ បោកស្រូវហើយ យាយខុម ផ្អើល។ តាម៉ុក ថាកប់ត្រឹម-ក បររនាស់ដីវាស់។ អ៊ីចឹងរត់ទៅរស់នៅខេត្តកោះកុងបាត់ លែងជួបរហូតហើយ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា ម៉េចបានលោកដឹងថា តាម៉ុក វកកប់ត្រឹម-ក ដាក់រនាស់រាស់ហ្នឹង?

**ឆ៖** បាទ ខ្ញុំធ្វើទំនប់ខ្ទបត្របែកហ្នឹង រែកដីទៅខ្ទបត្របែកហ្នឹង តាម៉ុក ធ្វើមីទ្និងនៅបឹងខ្ទបត្របែកហ្នឹងបីដង មហាជនមួយខេត្តធ្វើមីទ្និងហ្នឹង តែទៅគាត់ប្រកាសធ្វើមីទ្និងៗ ហើយដឹងឮគ្រប់គ្នាទាំងអស់ គាត់ប្រកាសក្តែងៗថាអ៊ីចឹង។

[១១:៣០:៣៨]

**ស៖** បាទ សូមអរគុណ។ តើលោកមានដឹងព័ត៌មានផ្សេងទៀតទាក់ទងទៅនឹង យាយខុម ថាហេតុអីបានជា យាយខុម ចាកចេញពីស្រុកត្រាំកក់ទេ?

**ឆ៖** បាទ ដឹង យាយខុម ខ្លាចតាម៉ុកកប់ត្រឹម-ក បរនាស់ជីវាស់ ព្រោះគាត់សម្លាប់ ជំទប់ជាល ហើយ តាម៉ុក ឱ្យអ្នកណាសម្លាប់ ជំទប់ជាល ឱ្យរកឱ្យឃើញ។

**ស៖** បាទ លោក ឯក ហឿន ខ្ញុំស្តាប់បានហើយចំណុចនេះ។ ប៉ុន្តែ ខ្ញុំសួរថាតើលោកមានព័ត៌មានអ្វីបន្ថែមទៀត ផ្សេងទៀត ដែលទាក់ទងទៅនឹង យាយខុម ដែលគាត់ចាកចេញពីស្រុកត្រាំកក់ដែរទេ?

**ឆ៖** បាទ អត់មានអីក្រៅពីហ្នឹង មានតែប៉ុណ្ណឹងទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹង យាយខុម ដដែល ខ្ញុំបានស្តាប់ឮសក្ខីកម្មរបស់លោកថាលោករស់ជិតផ្ទះយាយខុម ចម្ងាយប្រហែលជា១០០ម៉ែត្រពីគ្នា។ លោកអាចបញ្ជាក់បានទេថា លោករស់នៅជិតផ្ទះ យាយខុម ហ្នឹងក្នុងរយៈពេលយូរប៉ុនណាដែរ ដែលនៅជិតគ្នាចម្ងាយប្រហែល១០០ម៉ែត្រនោះ?

**ឆ៖** បាទ យាយខុម ទៅនៅជិតផ្ទះខ្ញុំ គឺនៅពីឆ្នាំ៧០ រហូតដល់៧៦ គាត់ចេញទៅកោះកុង គឺលែងឃើញគាត់កាលហ្នឹងហើយ ខ្ញុំជាប់រហូតហ្នឹង។ បានចេញទៅខែ៣ ឆ្នាំ៧៦។

[១១:៣២:៤៤]

**ស៖** ចុះលោកអាចបញ្ជាក់សាឡើងវិញបានទេ ទាក់ទងនឹងពេលដែលលោកទំនាស់ជាមួយយាយខុម ហ្នឹង ខែ ឆ្នាំណាដែរ?

**ឆ៖** បាទ អត់មានដែលទៅទាក់ទង អត់ប៊ានទៅជិតកន្លែងគេទេ គ្រាន់តែនៅជិត តែដើរកាត់អត់ប៊ានដើរផង។

**ស៖** សូមទោស លោកប្រហែលជាស្តាប់សំណួរខ្ញុំអត់បាន។ សំណួររបស់ខ្ញុំសួរថា នៅពេលដែលយាយខុម គាត់ថាតាមសម្លាប់លោកហ្នឹង ហើយលោកព្យាយាមរត់គេចពីយាយខុម តើឆ្នាំណា ខែ

ណាដែរ ពេលដែលលោករត់គេចហ្នឹង?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ត្រង់ហ្នឹង គឺឆ្នាំ៧៣ គេបែងចែកវណ្ណៈហើយ គឺវាចេញចង្កូម ដាក់ខ្ញុំរហូត យាយខុម ហ្នឹង។ ៧៣ គេបែងចែកកសិករ កណ្តាលកសិករ ក្រោមពលករហ្នឹង គេបែង ចែកហើយ ខ្ញុំនិន្នាការនយោបាយ ម៉ៃយួន ឪខ្មែរ ធ្វើមេៗភូមិសង្គមរាស្ត្រនិយមហ្នឹង អាហ្នឹងគេថាត្រូវ កង់ប្រវត្តិសាស្ត្រកិនហ្នឹង បានខ្ញុំដឹង ហើយតាមជឹម ចេះតែយកខ្ញុំទៅលាក់ហ្នឹង ដឹងថា យាយខុម រកតែ ខ្ញុំហ្នឹង ហើយតាជឹមយកលាក់។

**ស៖** បើតាមខ្ញុំស្តាប់លោកមិនច្រឡំទេ គឺពេលហ្នឹងគឺឆ្នាំ៧៣ ពេលដែលយាយខុម តាមរក សម្លាប់លោក តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ ខ្ញុំគេចវារហូតហ្នឹង។

**ស៖** បាទ សូមអរគុណ។ ចុះពេលដែលយាយខុម តាមសម្លាប់លោកនៅឆ្នាំ៧៣ តើលោករស់ នៅក្បែរផ្ទះ យាយខុម ហ្នឹងរហូតមកទៀត ឬមួយក៏លោកចាកចេញ? ឥឡូវខ្ញុំចង់ឲ្យលោកបញ្ជាក់ពី ពេលវេលាដែលលោកចាកចេញពីភូមិ ពីផ្ទះដែលនៅក្បែរផ្ទះយាយខុមហ្នឹង?

[១១:៣៤:៤០]

**ឆ៖** បាទ អត់ចាកចេញទេនៅតែដដែល។ ប៉ុន្តែ ខ្ញុំទៅដេកតាមទំនប់ តាមប្រឡាយ ទៅធ្វើទំនប់ ខ្ពបត្របែក ដេកខ្ពបត្របែក ទៅធ្វើទំនប់តាមភូមិ ដេកតាមភូមិ អត់ដែលឲ្យយាយខុមឃើញទេ ហើយ ខ្ញុំនៅហ្នឹងតែកន្លែងដដែលរហូតដល់ខែ៨ ៧៨ ថ្ងៃ៨ ខ្ញុំរត់ចោលស្រុកមកហ្នឹង។ រត់ចោលស្រុក យាយ ខុម ក៏គាត់ទៅនៅកោះកុងបាត់តាំង៧៦ ខែ៣ឯណោះ។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងគ្រួសាររបស់លោកវិញ លោកបានបញ្ជាក់រួចហើយថា លោកមានប្រពន្ធ មានកូន។ តើពួកនៅជាមួយលោកដែរទេ?

**ឆ៖** បាទ ប្រពន្ធកូនខ្ញុំនៅសព្វថ្ងៃ។

**ស៖** បាទ សំណួររបស់ខ្ញុំៗចង់បញ្ជាក់ពីពេលវេលាដែលលោកនៅធ្វើការ គឺទៅវាស់វែងដីនោះ តាំងពីឆ្នាំ៧៣រហូតដល់ពេលដែលលោកចេញទៅកំពង់ចាម ទៅជប់ ទៅកំពង់ចាមនោះ។ ខ្ញុំចង់ដឹងថា គ្រួសាររបស់លោកនៅជាមួយជួបជុំគ្នានឹងលោកដែរទេ?

**ឆ៖** បាទ អត់ទេ គ្រួសារខ្ញុំនៅផ្ទះរែកដីទាំងយប់ទាំងថ្ងៃ។

**ស៖** លោកអាចបញ្ជាក់ថា រែកដីនៅឯណាលោក?

**ឆៈ** បាទស្រីៗគេឲ្យដើរកាប់ដីដំបូកពង្រាយគ្រប់ស្រែទាំងអស់។ ស្រែណាមានដំបូកគឺកងហ្នឹងនាទីហ្នឹងគេទៅរែកដីដំបូកហ្នឹង។ ហើយទៅកាប់ដីខែប្រាំង កាប់ផ្ទូងហ្នឹងចេញភ្លើង "ចុញចេញភ្លើង!"។ គ្រាន់តែថាប៉ុណ្ណឹង គេយកទៅអប់រំ យកទៅកែប្រែភ្លាម។

[១១:៣៦:២៨]

**សៈ** អ៊ីចឹងខ្ញុំសូមត្រឡប់មកសំណួរដើមរបស់ខ្ញុំវិញ។ គឺថាពីឆ្នាំ៧៣ នៅពេលដែលលោកមានទំនាស់ជាមួយ យាយខុម ហើយដែលលោកបញ្ជាក់ថាផ្ទះរបស់លោក និងផ្ទះយាយខុម ហ្នឹងនៅក្បែរគ្នាចម្ងាយប្រហែល១០០ម៉ែត្រ។ អ៊ីចឹងមានន័យថាគ្រួសារលោកអត់នៅជាមួយលោកទេ? តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆៈ** បាទ អត់ៗត្រឹមត្រូវទេ ព្រោះគ្រួសារខ្ញុំនៅជាប់ជាមួយរហូតទល់ខ្ញុំដេកប្រឡាយ យាយខ្ញុំនៅផ្ទះ ខ្ញុំមកវិញដេកនៅជាមួយកូនប្រពន្ធតែរហូតហ្នឹង។ អត់ដែលបែកគ្នាទេ ដល់៧៨ ខ្ញុំរត់ឡើងឡានទៅ គេមកយកប្រពន្ធខ្ញុំទៅឲ្យខ្ញុំនៅស្រុកគេទៀតទៅ។ អត់ដែលបែកឆ្ងាយទេ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក ឯក ហឿន។ លោកប្រធាន ដោយសារពេលវេលាហ្នឹង ខ្ញុំសូមសម្រាកសិនបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយកន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោក ឯក ហឿន ឥឡូវនេះដល់ពេលសម្រាកហើយ សម្រាកថ្ងៃត្រង់ ហើយសវនាការយើងបន្តធ្វើចាប់ផ្តើមនៅវេលាម៉ោងមួយកន្លះ នៅរសៀលនេះ។ អ៊ីចឹងសូមលោកមានវត្តមានកន្លែងផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍នៅវេលាម៉ោងមួយកន្លះ។ លោកជ្រាបទេ លោក ហឿន?

**លោក ឯក ហឿន៖**

បាទ ជ្រាបហើយ។

**ប្រធានអង្គជំនុំ៖**

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការវិញនៅរសៀល

នេះឲ្យបានមុនម៉ោងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្ដី លោក ឯក ហឿន តើលោកបានត្រៀមរៀបចំខ្លួនហើយឬនៅ?

**លោក ឯក ហឿន៖**

បាទ រៀបចំរួចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឯក ហឿន។ តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីនេះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជម្រាបសួរ លោក ឯក ហឿន!

**លោក ឯក ហឿន៖**

**ឆ៖** បាទ។

**ស៖** មុនពេលសម្រាកយើងបានពិភាក្សាគ្នាអំពីកន្លែងរស់នៅរបស់លោក ស្រុកកំណើតរបស់លោក គ្រួសាររបស់លោក ហើយនិងទំនាក់ទំនងមួយចំនួនជាមួយនឹង យាយខុម។ ឥឡូវ ខ្ញុំចង់សួរបន្ថែមទៀត ទាក់ទងទៅនឹង យាយខុម ព្រោះលោកបានបញ្ជាក់ថា លោកមានផ្ទះនៅជិតគ្នា ក៏ប៉ុន្តែក្នុង

មួយរយៈលោកបានទៅជីក ទៅវាស់ប្រឡាយ ទំនប់ ជាដើម ក៏ប៉ុន្តែលោកនៅទៅមកភូមិហ្នឹងដដែល។ បានន័យថា លោក ពេលណាលោកទៅៗ ហើយពេលលោកមកវិញ លោកត្រឡប់មកនៅភូមិហ្នឹងវិញ។ ខ្ញុំចង់សួរថា តើលោកចេញពីផ្ទះយូរប៉ុនណាម្ដងៗនៅពេលដែលលោកចេញទៅវាស់ទំនប់ ឬក៏ប្រឡាយ?

**ផ៖** បាទ ពេលដែលវាស់ប្រឡាយគឺ៧៥ ចុងជាងហើយ គេឲ្យខ្ញុំចូលក្រសួងសុរិយោដី។ ពេលរយៈពី ៧០ ដល់៧៥ ខ្ញុំនៅផ្ទះថិតថេរជាមួយក្រុមគ្រួសារ។

[១៣:៣៤:០៣]

**ស៖** បាទ សំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងថាពេលលោកចេញទៅវាស់ម្ដងៗហ្នឹង គឺរយៈពេលប៉ុន្មាន ហើយលោកមកផ្ទះវិញស្នាក់នៅផ្ទះហ្នឹងរយៈពេលប៉ុន្មាន? លោកអាចឆ្លើយបានទេ?

**ផ៖** បាទ បានសូមជម្រាបប្រសាសន៍ ពេលខ្ញុំចេញធ្វើការ គឺទៅចំនួនមួយខែ ឬមួយខែកន្លះ ខ្ញុំមកសួរសុខទុក្ខគ្រួសារម្ដង។ មកតែមួយយប់ ឬពីរយប់ ហ្នឹងយូរណាស់ ត្រឡប់ទៅវិញ អត់ដែលបានពីរយប់ទេ។

**ស៖** បាទ អរគុណ។ អ៊ីចឹងការងារហ្នឹងលោកទៅមកជាលក្ខណៈប្រចាំតែអ៊ីចឹង អាចពីរយប់ បីយប់លោកនៅផ្ទះ ហើយលោកទៅមួយខែ ឬមួយខែជាង ត្រឡប់មកវិញម្ដងទៀត។ តើអ៊ីចឹងមែនទេ?

**ផ៖** បាទ ពិតណាស់។

**ស៖** បាទ សូមអរគុណ។ ចុះពេលលោកមកភូមិ លោកថាមួយយប់ ពីរយប់ដែលលោកមកហ្នឹងលោកមានដែលបានជួបជាមួយ យាយខុម ទេ?

**ផ៖** បាទ យាយខុម អត់ដែលបានជួបទេ គាត់យប់ថ្ងៃគាត់ដើរ។ ថ្ងៃដើរ យប់លែងហ៊ានដើរហើយគាត់។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់រួចហើយទាក់ទងនឹងប្រពន្ធរបស់លោកដែលលោកថា ឲ្យទៅរែកដី រែកដីដំបូកអីជាដើម។ ខ្ញុំចង់ដឹងថា តើប្រពន្ធរបស់លោករស់នៅក្នុងផ្ទះដែលលោកបញ្ជាក់ថានៅក្បែរ យាយខុម ប្រហែល១០០ម៉ែត្រហ្នឹងដែរទេ?

**ផ៖** បាទ ពិតណាស់។

**ស៖** បាទ សូមអរគុណ។ ចុះម្ដាយរបស់លោកនៅជាមួយលោកទេ ពេលហ្នឹង?

**ផ៖** បាទ សូមជម្រាបប្រសាសន៍ ម្ដាយខ្ញុំឪពុកខ្ញុំគាត់នៅគង់វង្សទាំងអស់ ហើយគាត់នៅបែកពីខ្ញុំចម្ងាយប្រហែលជា១០០ម៉ែត្រពីគ្នាទេ។

[១៣:៣៦:១៧]

**ស៖** ស្ថិតនៅក្នុងឃុំត្រពាំងធំហ្នឹងដែរទេ?

**ឆ៖** បាទ ស្ថិតនៅក្នុងឃុំត្រពាំងធំ ចុងខាងត្បូងជាប់ព្រំប្រទល់ឃុំសំរោងខាងជើង។ ហៅថាភូមិត្រពាំងប្រីយ៍។

**ស៖** បាទ សូមអរគុណ។ ចុះខ្ញុំឃើញមានភូមិមួយលោកបញ្ជាក់ថា ភូមិត្រពាំងជ្រៃ។ តើមានភូមិត្រពាំងជ្រៃ ហ្នឹងទេ ឬមួយក៏ភូមិត្រពាំងប្រីយ៍ មិនមែនភូមិត្រពាំងជ្រៃទេ?

**ឆ៖** បាទ ត្រពាំងប្រីយ៍នៅខាងលិចភូមិត្រពាំងជ្រៃ នៅភូមិជាប់ៗគ្នាហ្នឹង។ ហើយ យាយខុម នៅចុងភូមិត្រពាំងជ្រៃពីខាងលិចនោះ ហៅថា ភូមិផ្ទះតាសាន យាយគូ នៅជិតក្រាំងតាចាន់ហ្នឹង។

**ស៖** បាទ សូមអរគុណ។ ចំពោះទំនាក់ទំនងរបស់លោកជាមួយ យាយខុម លោកបានបញ្ជាក់ហើយថា យាយខុម ជាមនុស្សកាចសាហាវ ហើយចូលចិត្តសម្លាប់មនុស្ស ក្នុងពេលព្រឹកមិញនេះក៏លោកបានបញ្ជាក់បន្ថែមដែរ។ ខ្ញុំចង់សួរលោកថា តើលោកស្គាល់ យាយខុម នេះតាំងពីឆ្នាំណា? តាំងពីសម័យលោកនៅក្មេងៗជាមួយគ្នាក្នុងភូមិហ្នឹងជាមួយគ្នា ឬមួយក៏ស្គាល់ក្រោយៗទេ?

**ឆ៖** បាទ ខ្ញុំស្គាល់កូនចៅតាម៉ុក ស្គាល់ទាំងអស់ តាំងពីមុនឆ្នាំ៧០ ស្គាល់ខ្ញុំរកស៊ីអារឈើយកលុយគេ ទៅអារឈើផ្ទះតាម៉ុក។ តាម៉ុក ដង្ហោឈើ ហើយខ្ញុំឃើញ យាយខុម, ឃើញ យាយហូ អីកូនតាម៉ុកហ្នឹង ឃើញទាំងអស់ ស្គាល់ទាំងអស់។

[១៣:៣៨:១៥]

**ស៖** បាទ សូមអរគុណ។ ចុះគ្រួសារលោក ហើយនិងគ្រួសារ តាម៉ុក ឬក៏ យាយខុម ហ្នឹងមានទំនាក់ទំនងរាប់អានគ្នាដូចម្តេចដែរ លោកអាចជម្រាបបានទេ?

**ឆ៖** តាម៉ុក ហើយនិង យាយខុម ដូចអត់មានរាប់អានគ្នាថា ជាកូនជាចៅ ដូចរាងដាច់ឆ្ងាយពីគ្នា ការខុសត្រូវអី តាម៉ុក រវល់តែចាប់កំហុសយាយខុម ហ្នឹង គាត់ធ្វើខុសឆ្គងតែលើគាត់ហ្នឹង តាម៉ុកអត់ដឹង។

**ស៖** បាទ សំណួររបស់ខ្ញុំៗចង់សួរអំពីលោក និង យាយខុម ឬក៏ជាមួយនឹងគ្រួសារ តាម៉ុក។ តើលោកមានរាប់អានគ្នាទេ ជាលក្ខណៈគ្រួសារក្តី ជាលក្ខណៈផ្ទាល់ខ្លួនក្តី ដោយសារលោកនៅផ្ទះជិតគ្នាហើយលោកស្គាល់តាំងពីយូរហើយ?

**ឆ៖** បាទ អត់បានមានរាប់អានគ្នាទេ តាំងពីឆ្នាំ៧០ ឃើញ យាយហ្នឹងស្អប់ដូច -- ឃើញស្អប់

ខ្លា អត់មានដែលទៅជិត ទៅបៀតទេ។

**ស៖** បាទសូមអរគុណ។ ចុះលោកមានទំនាស់អ្វីជាមួយនឹង យាយខុម ទេជាលក្ខណៈផ្ទាល់ខ្លួន?

**ឆ៖** បាទ អត់ដែលមានទំនាស់ទេ អត់ដែលទៅជិត ទៅបៀតផង។

**ស៖** បាទ ចុះសម្ដីដែលលោកនិយាយអម្បាញ់មិញថា ឃើញ យាយខុម ស្អប់ដូចខ្លាហ្នឹង អាហ្នឹងមានន័យថាម៉េច លោកអាចបញ្ជាក់ពីលក្ខណៈដែលនាំឲ្យមានករណីហ្នឹងបានទេ? ហេតុអ្វីបានមានការស្អប់បែបនេះ?

**ឆ៖** បាទ ខ្ញុំតែទៅស្ដាប់គាត់ធ្វើមីទ្ទិងគាត់និយាយថា៖ "ពួកសក្ដិភូមិ នាយទុន ប្រតិកិរិយាប្រហារអត់ឲ្យសល់ម្នាក់ កម្ទេចទាំងរបប កម្ទេចទាំងបុគ្គល" ខ្ញុំស្អប់តាំងពីហ្នឹងមក។

**ស៖** បាទ សូមអរគុណ។ លោកចូលរួមស្ដាប់មីទ្ទិង របស់យាយខុមហ្នឹង ញឹកញាប់ទេ? ហើយចាប់ពីពេលណាដល់ពេលណាដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ មុន ៧០ យាយខុម -- ក្នុងឆ្នាំ៧០ យាយខុមចាត់តាំងរដ្ឋអំណាចហើយធ្វើៗមីទ្ទិងនៅឃុំត្រពាំងធំខាងជើង គេនិយាយតែអ៊ីចឹង ខ្ញុំទៅស្ដាប់ម្ដង។ ហើយធ្វើនៅឃុំគុស ធ្វើនៅថ្នល់បែកគុសហ្នឹងធ្វើម្ដង។ ហើយទី៣ ទៀតធ្វើនៅ ខាងត្បូងវត្តអង្គនារាយណ៍ ហៅថាកោះក្អែកហ្នឹងធ្វើម្ដង ធ្វើបីដងហ្នឹង ខ្ញុំ -- គេកែនយកទៅស្ដាប់ទាំងអស់ហ្នឹង ហើយទៅមីទ្ទិងលើកណាក៏គាត់និយាយតែអ៊ីចឹង ស្អប់អ៊ីចឹង អ្នកណាក៏ស្អប់ដែរ មិនមែនស្អប់តែខ្ញុំទេ។

[១៣:៤១:៣៩]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីពេលវេលាបានទេ ឆ្នាំណាដែរពេលចូលរួមធ្វើមីទ្ទិងហ្នឹង?

**ឆ៖** បាទ ទី១ ឆ្នាំ៧០ គេចាត់តាំងរដ្ឋអំណាចគេហើយ គេបើកធ្វើមីទ្ទិងនៅឃុំត្រពាំងធំត្បូងហ្នឹង។ ដល់ឆ្នាំ៧៣ គេធ្វើអាដែងរោងហូបសហករណ៍ គេធ្វើនៅថ្នល់បែកគុសហ្នឹង នៅក្នុងភូមិគុសហ្នឹង។ ដល់ឆ្នាំប៉ុន្មានទេ ភ្លេចហើយធ្វើនៅឃុំសំរោងម្ដងទៀត ធ្វើបីដង ខ្ញុំទៅស្ដាប់ទាំងបីដង គេឲ្យទៅស្ដាប់ទាំងអស់គ្នា។ អ្នករែកដី រែកអី ក៏គេឲ្យទៅដែរ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដូចជាសំណួរជំនឿទុកចិត្តហ្នឹង ដូចជាច្រើនរហូតដល់ពេលនេះ ដូចជាមិនទាន់ចូលសំណួរសារធាតុទាល់តែសោះ។ គប្បីជំរុញទៅមុខឲ្យចូលសំណួរសារធាតុទៅ ពាក់ព័ន្ធនឹងអង្គហេតុ

ចោទប្រកាន់ ដូចជាឆ្ងាយនឹងអង្គចោទប្រកាន់ពេកហើយ សំណួរទំនុកចិត្តហ្នឹងក៏ដូចជាច្រើនពេកហើយដែរ។

**លោក គង់ សំអុន៖**

បាទ លោកប្រធានខ្ញុំមានពីរសំណួរទៀតទាក់ទងចំណុចនេះ ហើយជាសំណួរផ្ទាល់។

[១៣:៤៣:០២]

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក ឯក ហឿន ទាក់ទងទៅនឹងបទពិសោធន៍ផ្ទាល់របស់លោក ដែលលោកបានស្គាល់ យាយខុម ហើយមុននេះបន្តិចលោកបានជម្រាបអង្គជំនុំជម្រះថា យាយខុម មិនមានការទំនាក់ទំនងអ្វីជិតដិតជាមួយ តាម៉ុក ទេ គឺតាម៉ុក មិនបានចាត់ទុកថាជាកូនដែលត្រូវយកចិត្តទុកដាក់ទេ។ ខ្ញុំសួរថាចុះហេតុម្តេចបាន យាយខុម គាត់អាចប្រើប្រាស់អំណាចក្នុងការចាប់ ឬក៏សម្លាប់មនុស្សបាន? លោកអាចផ្តល់សក្ខីកម្មលើចំណុចនេះបានទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ អង្កាល់ យាយខុម មានរដ្ឋអំណាចហ្នឹង តាសោម លេខាតំបន់ហ្នឹងគេដើរចាត់តាំងរដ្ឋអំណាចគេឆ្នាំ៧០ហ្នឹងហើយអស់ទៅ។ ហើយ យាយខុម ក៏ទទួលអំណាចហ្នឹងពី តាសោម ហ្នឹងរហូតមកទាល់ ៧៦ បានគាត់រត់ចេញពីស្រុកហ្នឹង គាត់អត់ដែលទទួលផែនការពី តាម៉ុក ទេ។

**ស៖** លោកអាចបញ្ជាក់បានទេថា តាសោម ណាមួយ?

**ឆ៖** មិនដឹងថាម៉េចអំមិញហ្នឹង។

**ស៖** បាទ អំមិញហ្នឹងលោកមានប្រសាសន៍អំពី តាសោម ដែលជាអ្នកអាចថានៅពីក្រោយដែលឲ្យ យាយខុម មានអំណាច។ អ៊ីចឹងខ្ញុំចង់សួរថាលោកសំដៅទៅលើ តាសោម ណាមួយ?

[១៣:៤៤:៤៩]

**ឆ៖** បាទ តាសោម ហ្នឹងមេខ្មែរក្រហម ឆ្នាំ៧០ គេធ្វើរដ្ឋប្រហារសម្តេច សីហនុ ហើយតាសោម ហ្នឹងចេញពីព្រៃមករៀបចំរដ្ឋអំណាច ដូចឃុំខាងលើ។ ទី១ ខ្ពបត្របែក ទី២) ត្រពាំងធំខាងជើង ត្រពាំងធំខាងត្បូង ជាងទង សំរោង ញ៉ែងញ៉ង។ អាហ្នឹងគេចាត់ហើយៗ ចាត់តាំងគ្នាគេធ្វើធំអស់ហើយ។ តាសោម គាត់អ្នករៀបចំស្រុកភូមិអស់ហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរលោកទាក់ទងទៅនឹង តាសឿន ហើយលោកមានប្រសាសន៍

កន្លងមកអំពីទំនាស់របស់លោកជាមួយ តាសឿន ដែលលោកត្រូវ តាសឿន ស្នើសុំរកចាប់ខ្លួនលោកសម្លាប់លោក។ លោកចាំបានចំណុចនេះទេ?

**ឆ៖** បាទ ទទួលបាន បញ្ហាហ្នឹងវាវែងឆ្ងាយពេក វាមកយកមនុស្សមកឲ្យ តាឈឿន ប្រធានមន្ទីរហ្នឹងហើយអត់ជួប តាឈឿន មកគំរាមខ្ញុំថា ខ្ញុំអីកាចម្ល៉េះ? គេមកទាក់ទង។ ខ្ញុំថាកាចអីបើខ្ញុំថាកុំចាំងពិលៗ ចេះតែចាំងមុខដាក់ ចាំងពិលដាក់មុខមើលមិនដឹងអ្នកណាអ្នកណីផងហ្នឹង ហើយគាត់ថាកាច។ កាចគាត់ចេះដើរហៅ តាឈឿនអើយ តាឈឿន ទៅលិចទៅ។ ហើយ តាឈឿន នៅដេកឆ្ងាយអត់មកផ្ទះទេ។

**ស៖** បាទៗ សូមអរគុណលោក ឯក ហឿន ចាំខ្ញុំសួរសំណួរ។ ទាក់ទងទៅនឹងឯកសារ E305/13.23.451, ERN ជាភាសាខ្មែរ 00968905, ភាសាអង់គ្លេស 01050194, ភាសាបារាំង 01053727។ ខ្ញុំសុំដកស្រង់នូវសំណួរ-ចម្លើយរបស់លោកដែលជាឯកសារផលិតឡើងដោយ ឌី.ស៊ី.ខេម (មជ្ឈមណ្ឌលឯកសារកម្ពុជា) ខ្ញុំសុំដកស្រង់៖ "ដានី៖ សោម ដន ហ្នឹង? ហឿន៖ បាទ កុំអីគេយកទៅបាត់ហើយអាសឿន គេប្រុងសម្លាប់ខ្ញុំ សុំគេមួយយប់ទល់ភ្លឺ គេអត់ឲ្យ រកសម្លាប់ខ្ញុំ។ អាព្រឹកឡើង នីរសារខ្ញុំរត់ទៅប្រាប់ខ្ញុំថា តាឯងធាក់បងកោះអណ្ដែតម៉េចអំមិញ? គេសុំ តាអ៊ូច យកទៅសម្លាប់ហើយ"។ តើលោកនៅចាំសក្ខីកម្មរបស់លោកបែបនេះទេ?

[១៣:៤៨:៣២]

**ឆ៖** បាទ ការពិតណាស់ដែលរសៀលហ្នឹង តាឈឿន យកមនុស្សគាត់ចាប់មកហើយ គាត់ទៅអត់ប្រាប់អ្នកណាអ្នកណីទេ គាត់ឡើងឡានទៅបាត់។ ទៅតាំងពីម៉ោងមួយដណ្ដប់រហូតសុំ តាអ៊ូច ហ្នឹងពីម៉ោងមួយដណ្ដប់ហ្នឹងរហូតដល់ម៉ោងប្រាំមួយព្រឹកនៅតែសុំ អាកងៗពលនីរសារដែលយកពីស្រុកទៅហ្នឹងវារត់មកប្រាប់ខ្ញុំៗ។ ប្រាប់ខ្ញុំពេលទាញផ្ដិលមិនទាន់លុបមុខវាប្រាប់ ខ្ញុំលុបមុខហើយខ្ញុំរត់ទៅតាកែវទៅជួបគណៈតំបន់ គឺ តាគិត (បងតាជឹម) ហ្នឹង។ ហើយត្រូវអ៊ូច គាត់អត់ឲ្យ។ គាត់ឲ្យអាមនុស្សហ្នឹងមិនមែនគាត់អ្នកចាត់តាំងទេ។ តាចាយ ក៏អត់ចាត់តាំង, តាជឹម ក៏អត់ចាត់តាំង, គាត់ក៏អត់ចាត់តាំង មកឃើញមនុស្សហ្នឹងនៅហ្នឹង។ "អ៊ីចឹងមិត្តឯងយកមិនបានទេ ព្រោះមនុស្សនេះគឺ តាម៉ុក ចាត់តាំង"។ គាត់ឆ្លើយជាកលល្បិចដើម្បីកុំឲ្យ អាសឿន ហ្នឹងមកទាមទារយកតែខ្ញុំ។ គាត់ថា តាម៉ុក ចាត់តាំង។ មិត្តឯងយកប៉ះពាល់ តាម៉ុក, ប៉ះពាល់ តាជឹម, តាចាយ, តាគិត ហើយតែអ៊ីចឹងទៅ វាចប់ហើយ។

[១៣:៤៩:៣៥]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់ទាក់ទងទៅនឹងពាក្យមួយដែលលោកអះអាងថា "នីរសារខ្ញុំរត់ទៅប្រាប់"។ លោកបញ្ជាក់ឈ្មោះបានទេ? ទី១ ម្នាក់ហ្នឹងឈ្មោះអី? នីរសារហ្នឹង?

**ឆ៖** ភ្លេចអស់ហើយហ្នឹង នៅចាំតែ អារុន ហើយ អារិន ពីរនាក់ហ្នឹង គេយកពីស្រុកទៅ។ អារុន ហើយ អារិន ដឹងស្រុកវាឯណា អីឯណា អត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ តើលោកមាននីរសារទេ ក្នុងពេលដែលលោកនៅត្រាំកក់ហ្នឹង?

**ឆ៖** បាទ អត់មានទេ នីរសារ គឺនីរសាររបស់ស្រុក របស់តា សោម ដន ហ្នឹង សម្រាប់រត់សំបុត្រទៅឃុំ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការសម្លាប់មនុស្ស៩០នាក់ លោកបានឆ្លើយក្នុងរយៈពេលពីរថ្ងៃនេះ ខ្ញុំចង់សួរបញ្ជាក់លោកថាតើលោកដឹងព័ត៌មានអំពីការសម្លាប់មនុស្ស៩០នាក់នោះ ពីណាមកដែរ? លោកចាំសាច់រឿងទាក់ទងការសម្លាប់មនុស្ស៩០នាក់ហ្នឹងទេ?

[១៣:៥១:២១]

**ឆ៖** បាទ វាយូរមកហើយ វាភ្លេចភ្លាំងខ្លះហើយ។ ខ្ញុំជាអ្នកដឹកបន្លែទៅឲ្យ តាជឹម នៅស្នាក់ការនៅជាប់ប្រឡាយហ្នឹង ដឹកបន្លែឲ្យពីរថ្ងៃបីថ្ងៃទៅ ដឹកពីរថ្ងៃបីថ្ងៃទៅដប់ថ្ងៃ។ ចុងក្រោយ អ្នកនៅកន្លែងហ្នឹងថា៖ "អើ្ហ! តាជឹម សម្លាប់ខ្មែរដែលយកពីស្រុកយួន៩០នាក់ សម្លាប់អស់រលីង"។ អាហ្នឹង ខ្ញុំចាំតែពាក្យហ្នឹងប៉ុណ្ណឹងទេ។

**ស៖** សូមលោកបញ្ជាក់ម្តងទៀត ថាអ្នកណាអ្នកនិយាយ?

**ឆ៖** បាទ អ្នកជីកប្រឡាយនៅហ្នឹងក៏ដឹង អាអ្នកនៅជុំវិញ តាជឹម ហ្នឹងក៏ដឹង គេនិយាយទាំងអស់គ្នាហ្នឹង អត់មានលាក់ផង។ ដល់ តាម៉ុក ទៅទៀត ក៏ដឹងរឿងហ្នឹង រឹតតែសុះសាយទៅទៀត។

**ស៖** បាទ សូមអរគុណ។ លោកធ្លាប់ជួបអ្នក៩០នាក់ហ្នឹងទេ ពីមុនមានការសម្លាប់ហ្នឹង?

**ឆ៖** បាទ អត់ដឹង អត់ដែលដឹងថាដូរ ថាអីវា ដល់តែពេលងាប់ហើយ បានដឹងថា តាម៉ុក ដូរមនុស្សយកមកឲ្យ តាជឹម ហ្នឹង។ ដឹងត្រឹមហ្នឹង។

**ស៖** អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់បន្ថែមថា តើលោកដឹងពីវត្តមានរបស់អ្នក៩០នាក់ហ្នឹង នៅក្នុងភូមិឬក៏ឃុំដែលលោកធ្វើការហ្នឹងទេ?

**ឆ៖** បាទ អ្នក៩០ហ្នឹងនៅឆ្ងាយគ្នាណាស់ គឺនៅស្រុកកោះអណ្តែត ពេលគេធ្វើរដ្ឋប្រហារ កើតសង្គ្រាម ប្រជាជន៩០នាក់ហ្នឹង រត់ចូលស្រុកយួន។ ដល់ចូលស្រុកយួន ឆ្នាំ៧រំដោះហើយ តាម៉ុក យក

យួនស្រុកខ្មែរ ទៅដូរខ្មែរនៅស្រុកយួនហ្នឹងមក។ ដឹងតែប៉ុណ្ណឹងទេ។

**សៈ** បាទ ខ្ញុំចង់ឲ្យលោកបញ្ជាក់ផងដែរថា ដោយសារអំមិញនេះលោកមានប្រសាសន៍ថា អ្នកនោះនៅស្រុកកោះអណ្តែត។ អ៊ីចឹង សួរថាព័ត៌មានដែលលោកដឹងពីការសម្លាប់អ្នក៩០នាក់នុ៎ង នៅស្រុកកោះអណ្តែត ឬមួយក៏ការសម្លាប់នៅស្រុកត្រាំកក់?

[១៣:៥៣:៣៩]

**ផះ** បាទ ជម្រាបប្រសាសន៍ គឺសម្លាប់ តាម៉ុក យកមកប្រគល់ឲ្យ តាជឹម នៅកន្លែងជីកប្រឡាយចេញពីខ្ពបត្របែក។ តាជឹម នៅៗតាមមើលប្រឡាយហ្នឹង លោកធ្វើកន្លែងស្នាក់ការនៅជាប់ប្រឡាយហ្នឹង។ ហើយ តាម៉ុក យកមនុស្ស៩០នាក់ហ្នឹង មកឲ្យ តាជឹម នៅកន្លែងជីកប្រឡាយហ្នឹង។

**សៈ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ផងបានទេ ម៉េចបានលោកដឹង?

**ផះ** បាទ ត្រង់ហ្នឹងដែលខ្ញុំដឹង គឺខ្ញុំដឹកបន្លែទៅរាល់ថ្ងៃ។ ពីថ្ងៃបីថ្ងៃដឹកទៅឲ្យ តាជឹម។ ពីរថ្ងៃបីថ្ងៃ ដឹកទៅ ដឹកអង្ករ យកឲ្យ តាជឹម ហូបហ្នឹង។ ហើយម្ល៉េះហើយទុកតែទៅដល់ហ្នឹង គេនិយាយអ៊ីវគ្រប់តែគ្នាហ្នឹង។ រហូតដល់មក តាម៉ុក ទៅទៀត បែករឿងពី តាម៉ុក ហ្នឹងរឹតតែច្បាស់ទៀត។

**សៈ** លោកអាចបញ្ជាក់បានទេថា មាននរណាខ្លះផ្សេងទៀត ដែលគេដឹងពីរឿងសម្លាប់អ្នក៩០នាក់ហ្នឹង?

**ផះ** បាទ អត់បានដឹងទៀតទេ។

**សៈ** លោកអាចបញ្ជាក់បានទេ នៅទំនប់ខ្ពបត្របែកហ្នឹង ហើយនិងពីកន្លែងដែលលោកនៅគឺខាងត្រពាំងធំហ្នឹង ចម្ងាយគ្នាប៉ុនណា?

**ផះ** អត់ស្មានត្រូវទេ វាឆ្ងាយដែរ ធ្វើប្រហែលជា៥-៦គីឡូពីផ្ទះខ្ញុំទៅកន្លែងជីកប្រឡាយហ្នឹង បើមកចំពីខាងលិច មកពីខាងកើតផ្ទះអត់បាន១០០ម៉ែត្រ ប្រឡាយនៅមុខនឹងផ្ទះហ្នឹង ប្រឡាយធំ បង្ហូរទឹកស្ទឹង។

[១៣:៥៥:៤១]

**សៈ** បាទ មុននេះអំមិញលោកមានប្រសាសន៍ថា លោកដឹកបន្លែដឹកអីយកទៅខ្ពបត្របែក។ លោកអាចបញ្ជាក់បានទេថា នោះជាការងារអ្វីរបស់លោក?

**ផះ** បាទ ខ្ញុំនៅក្នុងមន្ទីរនុ៎ងដូចជាកម្មករអ៊ីចឹង ណាទៅរត់គ្រប់ផ្លូវទាំងអស់ គេប្រើទៅណាទៅហ្នឹងៗ អត់មាននាទីអីក្រៅពីហ្នឹងទេ។ អត់អង្ករ គេឲ្យយកអង្ករទៅ ដឹកអាត្រាក់ទៅឲ្យ អត់អីគេប្រើ

ហ្នឹង ប្រើទៅគ្រប់ទិសទីទាំងអស់។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ឆ្នាំបានទេ ខែ ឬក៏ឆ្នាំដែលលោកដឹកបន្លែហ្នឹង?

**ឆ៖** បាទ ចាប់ដឹកតាំងពីឆ្នាំរំដោះហើយមក ធ្វើទំនប់ ធ្វើប្រឡាយហ្នឹង ដឹកបន្លែរហូត។ ទៅធ្វើទំនប់ទួលគ្រួរ ក៏ដឹកទៅទួលគ្រួរ ដឹក ធ្វើទំនប់ក្នុងស្រុកក៏ដឹកទៅក្នុងស្រុក យកឲ្យ -- តាជឹម ទៅជាប់តែកន្លែងធ្វើទំនប់ ធ្វើប្រឡាយ ម្ល៉ោះចេះតែដឹកដល់ទៅទុកឲ្យគាត់។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថាការងារវាស់វែងទំនប់ ឬក៏ប្រឡាយដែលលោកបានជម្រាបពីមុនហ្នឹង គឺធ្វើការស្របគ្នានឹងការដឹកបន្លែហ្នឹងដែរទេ ឬក៏មានពេលដែលដឹកបន្លែផ្សេង ការងារវាស់វែងទំនប់នោះផ្សេង?

**ឆ៖** បាទ អង្កាល់ដឹកបន្លែហ្នឹងពី៧០ អំនែ! ពី៧៥ រហូតដល់៧៦ខ្ញុំទៅនៅផ្ទះ តាជឹម ហើយដល់៧៦ហ្នឹង ខ្ញុំចូលក្រសួងសុរិយោដី ដាច់ស្រឡះពីកន្លែងដឹកបន្លែហ្នឹងហើយ ខាងសុរិយោដី។

[១៣:៥៧:៣៧]

**ស៖** សូមលោកបញ្ជាក់សាជាថ្មី ពីព្រោះសក្ខីកម្មរបស់លោកមានចំណុចខ្វែងគ្នា។ ពីមុនមកលោកបញ្ជាក់ថា លោកទៅវាស់ដីនៅក្រសួងសុរិយោដីពី៧៣ កាលពីមុនសម្រាក។ បាទ ឥឡូវលោកបញ្ជាក់ថា៧៦ អ៊ីចឹងលោកបញ្ជាក់សាជាថ្មីមើល ឆ្នាំណាពិតប្រាកដដែលលោកទៅធ្វើការខាងវាស់វែងដីឬក៏ខាងក្រសួងសុរិយោដី លោកមានប្រសាសន៍អំមិញហ្នឹង?

**ឆ៖** បាទ អត់ដែលថាឆ្នាំ៧៣ផង ចិតសិប -- ឆ្នាំ៧៣ គេរៀបចំផែនការធ្វើទំនប់ធ្វើប្រឡាយហ្នឹង អត់ទាន់បានដឹកបន្លែទេ។ ដល់តែចប់សង្គ្រាម តាជឹម យកខ្ញុំទៅដាក់នៅពាណិជ្ជហ្នឹង។ ដាក់នៅពាណិជ្ជហ្នឹងក្នុង៧៥ មាននាទីដឹកបន្លែហើយ។ ដល់ដឹកបន្លែហ្នឹង៧៥ដល់៧៦ ខែ៣ អាហ្នឹង តាជឹម -- យាយខុម ទៅសម្លុតខ្ញុំ, តាជឹម យកខ្ញុំទៅលាក់នៅផ្ទះគាត់ហើយ។ ៧៦ ខែ៣ យាយខុម ទៅសម្លុតខ្ញុំនៅពាណិជ្ជហ្នឹង។ តាជឹម ដឹងថា យាយខុម តាមរកខ្ញុំ អ៊ីចឹងយកទៅលាក់ផ្ទះគាត់បានពីរថ្ងៃ។ ពីរថ្ងៃគាត់ឲ្យខ្ញុំចូលក្រសួងសុរិយោដីហ្នឹងទៅ។

[១៣:៥៩:០៦]

**ស៖** បាទ ក្រែងលោខ្ញុំមានការយល់ច្រឡំ ពីព្រោះលោកបានជម្រាបមុនពេលយើងសម្រាកព្រឹកមិញនេះថា លោកមិនពេញចិត្តនឹង យាយខុម ដោយសារ យាយខុម និយាយពីរឿងកម្ទេចពួកសក្តិភូមិជាដើម។ ហើយ យាយខុម គាត់លើកនិយាយបែបនោះ គឺតាំងពី៧៣មកម្ល៉េះ ហើយក៏មានទំនាស់លោកជា

មួយនឹង យាយខុម ដោយសារតែលោកជាកូនរបស់អតីតមេភូមិ។ តើលោកចាំចំណុចនេះបានទេ?

**ឆ៖** បាទ នៅចាំ ព្រោះឆ្នាំ៧៣ហ្នឹងគេបែងចែកវណ្ណៈ ដល់តែបែងចែកវណ្ណៈ យាយខុម ធ្វើមីទ្ទិង គាត់និយាយតែប្រវត្តិសាស្ត្រ "រឿងសក្តិភូមិ នាយទុន ប្រតិកិរិយាប្រហារអត់ឲ្យសល់ម្នាក់ កម្ទេចទាំងរបប កម្ទេចទាំងបុគ្គល" ខ្ញុំកើតស្អប់គាត់តាំងពីហ្នឹងមក។

**ស៖** បាទសូមអរគុណ។ អ៊ីចឹងតាមខ្ញុំយល់ពីព្រឹកមិញហ្នឹង លោកមានទំនាស់ជាមួយ យាយខុម តាំងពី៧៣?

**ឆ៖** បាទ។

**ស៖** តើយាយខុម តាមចាប់លោកពី៧៣ ដែរទេ ឬមួយក៏មានរឿងក្រោយទេ?

**ឆ៖** បាទ តាំងពីជំនាន់ហ្នឹងមកបែងចែកវណ្ណៈហើយ គេថាខ្ញុំហ្នឹងត្រូវកង់ប្រវត្តិសាស្ត្រកិនហើយ ហើយម៉ែឪវា ក៏ត្រូវកងប្រវត្តិសាស្ត្រកិនដែរ។ អ៊ីចឹងតាជឹម ដឹងរឿង គាត់ដឹងទាំងអស់ គាត់យកខ្ញុំទៅលាក់ ពេល៧៦ហ្នឹង មកផ្ទះគាត់។ យកឡើងទៅពាណិជ្ជ។ ដល់៧៦ ទៅឃើញខ្ញុំនៅពាណិជ្ជនោះទេ យាយខុម ថា តាជឹម យកគាត់ទៅលាក់ -- យកខ្ញុំទៅលាក់នៅផ្ទះគាត់។ ស្អប់ទាំងម៉ែខ្ញុំ ស្អប់ទាំងកូនខ្ញុំ ហើយខ្ញុំក៏ស្អប់គាត់ទាំងម៉ែទាំងឪក៏ស្អប់ដែរ អត់ដែលទំនាក់ទំនងរាប់រក ដែលទៅជិត ទៅបៀតទេ ឃើញខ្លាច ៗដូចខ្លាអ៊ីចឹង។

[១៤:០១:១៥]

**ស៖** បាទ លោក ឯក ហឿន ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា នៅពេលដែលលោកមានទំនាស់ជាមួយ យាយខុម ហើយយាយខុម តាមចាប់លោកហ្នឹងគឺពី៧៣ ឬក៏៧៦? លោកអាចបញ្ជាក់ឲ្យច្បាស់បានទេ?

**ឆ៖** បាទ សូមបញ្ជាក់ជូនថាឆ្នាំ៧៣ គេបែងចែកវណ្ណៈហើយ ដល់បែងចែកវណ្ណៈ យាយខុម មានសិទ្ធិធ្វើមីទ្ទិង ៗគាត់និយាយតែអ៊ីចឹង ហើយខ្ញុំជាមនុស្សមានខ្លួនអ៊ីចឹង ខ្ញុំចេះតែភ័យ ខ្ញុំចេះតែខ្លាច ម៉ែខ្ញុំគាត់ថាកង់ប្រវត្តិសាស្ត្រត្រូវកិនដែរ ប៉ុន្តែគាត់ចាស់ទុកឲ្យគាត់ងាប់ខ្លួនឯងទៅ ដើរថាអ៊ីចឹងហើយ ដែលខ្ញុំស្អប់។ អាហ្នឹងចាំ៧៣ រៀបចំបែងចែកវណ្ណៈហ្នឹង គេរករឿងរហូតហើយ។

**ស៖** បាទសូមអរគុណ។ ចុះហេតុអីបានជាលោកត្រូវទៅលាក់ខ្លួននៅផ្ទះតាជឹម រហូតដល់៧៦?

**ឆ៖** បាទ ទៅលាក់តែពីរថ្ងៃទេ ដល់ពីរថ្ងៃហើយ គាត់ទៅចូលផ្ទះគាត់ៗថា "ហ្អែងទៅៗជួយវាស់វែងប្រឡាយនឹងគេទៅ" ហើយខ្ញុំក៏ទៅៗ បានតែពីរថ្ងៃទេនៅផ្ទះ។ ចូលទៅក្រសួងសុរិយោហ្នឹងចូលបីឆ្នាំ។ ៧៦ ដល់ឆ្នាំ៧៨ ខែ៨ ខ្ញុំរត់តាមគេទៀតហើយ តាសឿន រកសម្លាប់ទៀតហើយ។

**សៈ** បាទ សំណួររបស់ខ្ញុំ លោកអាចពន្យល់បានទេថាហេតុអីបានជាពី៧៣ មកដល់៧៦ លោកអត់រត់គេច ហើយបែរជាមករត់តែឆ្នាំ៧៦ ក្នុងរយៈពេលតែពីរថ្ងៃ លោកអាចពន្យល់បានទេ?

**ឆះ** បាទ យកមកលាក់ក្នុង៧៦ហ្នឹង នៅផ្ទះតាជឹម ហ្នឹង នៅពួនទេ អត់ចុះពីលើផ្ទះទេ ខ្លាចយាយខុម រកឃើញ ដល់គ្រប់ពីរថ្ងៃ តាជឹម គាត់ចូលទៅផ្ទះគាត់ៗថា “ហ្អែងទៅចូលក្រសួងសុរិយោដីនឹងគេទៅ” ហើយខ្ញុំក៏ទៅតាមការចាត់តាំងរបស់គាត់ទៅ។ ហ្នឹងចប់ត្រឹមហ្នឹងហើយ ធ្វើបានបីឆ្នាំអាក្រសួងហ្នឹង។

[១៤:០៣:៥៤]

**សៈ** បាទ សូមអរគុណ។ ឥឡូវខ្ញុំចង់សួរលោកទាក់ទងទៅនឹងសមាសភាពនៅក្នុងតំបន់វិញ គឺតំបន់១៣។ លោកបានរៀបរាប់នូវឈ្មោះមួយចំនួននៅក្នុងឯកសារ E305/13.23.451 សុំបន្តិច ខ្ញុំសូមរកលេខ ERN អាច -- ERN ជាភាសាខ្មែរ 00968895, ERN ជាភាសាអង់គ្លេស 01050186 ដល់ 87, ជាភាសាបារាំង 01053716 ដល់ 17។ ខ្ញុំសូមដកស្រង់សំណួររបស់ ដានី៖ “តើមុន តាគិត ហ្នឹងពីណាខ្លះទៅ? ហឿន៖ មុនហ្នឹង មើលតាសោម មេខ្មែរក្រហម មេកន្ទ្រាញ, តាសោម ហើយភ្លេចទៀតគឺតា -- មានតាគារ (សូមទោស) មានតាញ៉ែវ, តាគារ, តាមុត ជាចៅហ្វាយខេត្តដែរខាងកងទ័ព។ ដានី៖ តាមុត? ហឿន៖ បាទ។ តាញ៉ែវ បេ៥២ទម្លាក់ស្លាប់ដំណាលខ្មោច តាហេង។ ដានី៖ តាសោម បន្ទាប់ពីតាសោម មកតាញ៉ែវ? ហឿន៖ តាគារ។ ដានី៖ តាគារទៀត? ហឿន៖ តាគារ អនុ ដល់ប្រធានស្លាប់ទៅនៅ តាគារ។ ដានី៖ ហើយពីណាទៀតទៅ? ហឿន៖ ដល់ហើយពីតាគារ តាញ៉ែវ ហ្នឹងទៅតាអ៊ូច នេះធ្វើចៅហ្វាយស្រុកទេ ហើយពីហ្នឹង -- អ៊ូ! មានតាប្រាក់ បន្ទាប់ពីតាគារ ទៅ តាប្រាក់ចៅហ្វាយខេត្ត។ ហើយគេនាំឱ្យទៅរៀនសូត្របាត់ទៅ បានឱ្យតាគិត ហ្នឹងចូល”។

លោកស្តាប់បានទេ -- សូមបិតការដកស្រង់ -- លោកស្តាប់បានទេ លោក ឯក ហឿន?

**ឆះ** បាទស្តាប់បានពីត្រឹម តាប្រាក់។ តាប្រាក់ គេយកទៅឱ្យមកធ្វើចៅហ្វាយខេត្តតំបន់២៥ ទឹកខ្មៅ ហើយ តាទិត្យ ឡើងបានធ្វើប៉ុន្មានខែ ដល់៧៧ ខែ៣ គេបញ្ជូនមកភាគពាយ័ព្យតាំងពី តាគិត -- តាំងពី តាជឹម, តាចាយ, យាយថែម មកភាគពាយ័ព្យអស់មក គឺ--

**សៈ** បាទ សូមអរគុណ។ ខ្ញុំនឹងសួរលោកទាក់ទងទៅនឹងចំណុចមួយដែលលោកឆ្លើយថា តាសោម មេខ្មែរក្រហម ជាមេកន្ទ្រាញ។ ខ្ញុំចង់ឱ្យលោកបញ្ជាក់ថា ហេតុអីបានលោកហៅតាសោម ថាជាមេខ្មែរក្រហម ហើយជាមេកន្ទ្រាញ? លោកអាចពន្យល់បានទេ?

[១៤:០៨:៤២]

**ឆ៖** បាទ សូមបញ្ជាក់ជូនថា តាសោម ជាមេខ្មែររូស នៅក្នុងព្រៃលាក់ខ្លួន ឆ្នាំ៦៨-៦៩ហ្នឹង។ ដល់ពេលចប់សង្គ្រាម គាត់មកចាត់តាំងរដ្ឋអំណាចគាត់។ ចាត់តាំងរដ្ឋអំណាចគាត់ហើយ គឺគាត់ហ្នឹង ឃោរឃៅណាស់ យកជាង១០០នាក់ទៅធ្វើសាលានៅភ្នំខ្លែង ហើយធ្វើទៅវាអត់ឲ្យដាក់មេដំបូល ធ្វើឲ្យវាស្រុត យកជាងហ្នឹងទៅសម្លាប់ចោលទាំងអស់។ ខ្ញុំហៅថាមេកន្ទ្រាញតាំងពីហ្នឹងមក។ យកជាងស្រុកត្រាំកក់ហ្នឹងទៅធ្វើនៅភ្នំខ្លែងហ្នឹង។

**ស៖** បាទ ទាក់ទងនឹងឥទ្ធិពលរបស់តាសោម ហ្នឹងយ៉ាងម៉េចដែរ លោកមានធ្វើការកត់សម្គាល់ទេ?

**ឆ៖** បាទ ដឹងតែប៉ុណ្ណឹង អត់មានដឹងអីតទៅទៀតទេ។ ដឹងថាសម្លាប់មនុស្សក្នុងស្រុកត្រាំកក់ក្នុងភូមិខ្ញុំហ្នឹង យកទៅធ្វើជាងហ្នឹងសម្លាប់ចោលទាំងអស់។

**ស៖** លោកអាចបញ្ជាក់ឆ្នាំណាបានទេ?

**ឆ៖** បាទឆ្នាំ៧៥ហ្នឹងតែម្តង កំពុងចប់សង្គ្រាមអស់ហើយហ្នឹង ប្រមូលយកធ្វើនៅភ្នំខ្លែងហ្នឹង ធ្វើសាលានយោបាយហ្នឹង។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងនឹង តាប្រាក់ លោកស្គាល់ តាប្រាក់ ហ្នឹងដែរទេ?

**ឆ៖** បាទឮតែឈ្មោះ អត់ដែលស្គាល់ទេ។

**ស៖** បាទ អរគុណ។ លោកដឹងថា តាប្រាក់ ចូលកាន់តំណែងនៅក្នុងតំបន់ពីឆ្នាំណាដែរ ដល់ឆ្នាំណាដែរ?

**ឆ៖** ចូលហ្នឹងខ្ទង់ឆ្នាំ៧៦ ហើយ ៧៦ហ្នឹងផ្លាស់ មិនមែន ៧៦ទៀត -- អ៊ូ! ៧៦ អ៊ីចឹងហើយ គាត់កាន់អំណាចអត់បានមួយឆ្នាំទេ គេផ្លាស់គាត់មកនៅទឹកខ្មៅ។ បានតាប្រាក់ ចេញទៅ តាទិត្យ។ តាទិត្យ ចេញទៅ តាគិត។ តាគិត ចេញទៅ ខ្ញុំក៏ទៅដែរ មិនដឹងអ្នកណាទៀតទេ ចប់ត្រឹមហ្នឹងអត់ដឹង។

[១៤:១១:០៥]

**ស៖** លោកអាចបញ្ជាក់កាលបរិច្ឆេទច្បាស់លាស់បានទេ នៅពេលដែល តាប្រាក់ កាន់គណៈតំបន់ហ្នឹង?

**ឆ៖** បាទ ខ្ញុំបានអីបញ្ជាក់បើអត់ដែលដឹងគាត់ ពេលខ្លីពេក ពេលគាត់មកកាន់ខេត្តហ្នឹង។ ហើយគាត់ផ្លាស់ទៅបាត់ទៀតទៅ។

**សៈ** មុនហ្នឹងអំមិញលោកបញ្ជាក់ថាឆ្នាំ៧៦ លោកអាចបញ្ជាក់បានថាឆ្នាំ៧៦ហ្នឹង ពេលដែល តាប្រាក់ ចូលមកហ្នឹងចុងឆ្នាំ ដើមឆ្នាំ ឬក៏មានពេលណាដោយឡែក ឬមួយក៏លោកអត់ច្បាស់ទេ?

**ឆៈ** វាអត់ច្បាស់ដែរ បែបមិនដើមឆ្នាំទេ គឺចុងឆ្នាំហើយ។ ៧៦ ចុងឆ្នាំហើយជិតដល់ដាច់ចូល ៧៧ ហើយ។ គាត់មកនៅទឹកខ្មៅ ដល់តាប្រាក់ គេយកតាប្រាក់ទៅបាត់ គេដកតាគិតពីតាកែវហ្នឹង មកនៅជំនួស តាប្រាក់ នៅទឹកខ្មៅហ្នឹងវិញ តំបន់២៥ហ្នឹង។ ហើយ តាគិត មកខ្ញុំមកសុំឡានគាត់បាន មួយឡានចាស់ៗហ្នឹង។ ខ្ញុំមានចាំថ្ងៃខែឯណា។

**សៈ** បាទ លោកអាចបញ្ជាក់បានទេ ទៅលើកាលៈទេសៈអីដែលលោកអាចចាំថាជាឆ្នាំ៧៦ ឬក៏ ឆ្នាំ៧៧ ព្រោះអំមិញនេះលោកនិយាយថាអត់ច្បាស់ទេ។ អ៊ីចឹងលោកអាចរកនឹកមើល តើមានកាលៈ ទេសៈអី ដែលអាចឲ្យលោកកំណត់នៅពេលវេលាដែល តាប្រាក់ មកធ្វើការនៅតំបន់១៣ ហ្នឹង?

**ឆៈ** បាទ វាអត់ច្បាស់ត្រង់ហ្នឹង វាស៊ើបអង្កេតឲ្យច្បាស់លាស់ មិន ចូលជិត៧៧ ហើយហ្នឹង មិនដើមឆ្នាំទេ ចុងឆ្នាំហើយហ្នឹង។ បានគេដក តាគិត ពីតំបន់១៣ មកនៅ២៥ ហ្នឹងវិញ វាអត់ច្បាស់ដែរ ហ្នឹង។

[១៤:១៣:១៤]

**សៈ** បាទ អ៊ីចឹងសូមលោកបញ្ជាក់ម្តងទៀតពីព្រោះដោយសារចម្លើយរបស់លោកអត់ច្បាស់។ ខ្ញុំស្តាប់ទៅក៏អត់ច្បាស់ដែរ។ អ៊ីចឹងបន្ទាប់ពី តាប្រាក់ ចេញទៅគឺ តាគិត មកជំនួស តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆៈ** បាទ ត្រឹមត្រូវ។

**សៈ** ចុះលោកចាំព័ត៌មានទាក់ទងទៅនឹង តាគិត ទេ? តាគិត ហ្នឹងគាត់ចូលមកកាន់តំណែងហ្នឹង នៅពេលណា ឆ្នាំណា ខែណា?

**ឆៈ** តាគិត មកកាន់តំណែងនៅក្នុងតំបន់១៣ ហ្នឹងនៅ៧៦ ហ្នឹងហើយ។ ធ្វើអត់បានមួយឆ្នាំទេ គាត់ចេញទៅពាយ័ព្យទៀត។ អូ៎! មិនមែនៗមួយឆ្នាំទេ។ ៧៦ ដល់៧៧ ខែ៣ បានគាត់ចេញហើយ។ តាជឹម ក៏ចេញ, យាយចែម ក៏ចេញ, តាគិត ហ្នឹងក៏ចេញ។ ច្រឡំឆ្នាំខែអស់ហើយ។

**សៈ** បាទ ឥឡូវសូមលោកសម្រួលអារម្មណ៍បន្តិច ហើយរកនឹកសាជាថ្មី ព្រោះអំមិញ លោកឆ្លើយជាន់គ្នាជាមួយ តាប្រាក់ ហើយនិង តាគិត។ ខ្ញុំសូមលោកគិតៗឲ្យច្បាស់ ថាតើតាប្រាក់ គាត់ ចូលធ្វើការនៅពេលណា? ហើយ តាគិត មកជំនួសតាប្រាក់ ហ្នឹងនៅពេលណា? សូមលោកសម្រួល អារម្មណ៍បន្តិច ហើយចាំឆ្លើយ។

**ឆ៖** បាទ ខ្ញុំសូមជម្រាបទៅវាអត់ច្បាស់ គ្រាន់តែដឹងថា តាប្រាក់ ឡើង។ ដល់តាប្រាក់ ឡើង គេផ្លាស់ តាប្រាក់ ទៅទឹកខ្មៅទៅ តាទិត្យ ទៅ -- អ៎! តាគិត ទៅជំនួស តាប្រាក់ ហ្នឹង។ វាអត់ដឹងច្បាស់ អត់ដឹងថ្ងៃខែ គ្រាន់តែដឹងថាគេផ្លាស់ប្តូរ ព្រោះខ្ញុំចេញចូលពីស្រុកត្រាំកក់ហ្នឹងទៅយកប្រេង យកសាំងអីតែនៅតំបន់ហ្នឹង។ ទៅឃើញ ដឹង ហើយអត់ចាំថ្ងៃចាំខែទេ។

[១៤:១៥:៤៥]

**ស៖** លោកអាចបញ្ជាក់បានទេថា តាគិត គាត់មកកាន់តំបន់ហ្នឹងក្នុងរយៈពេលប៉ុន្មាន? យូរប៉ុនណាដែរ?

**ឆ៖** បាទ កាន់នៅគណៈតំបន់ហ្នឹង អត់នឹក អត់ដឹងខែ ដឹងឆ្នាំទេ ហើយគាត់ចេញទៅជំនួស តាប្រាក់ នៅទឹកខ្មៅទៀតក៏អត់ដឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមដកស្រង់ឯកសារ E319.1.31 ដែលជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់លោក។ ត្រង់សំណួរ-ចម្លើយលេខ៤៤ សួរ សូមដកស្រង់៖ “នៅក្នុងជំនាន់នោះ តើ តាគិត មានតួនាទីអ្វីដែរឬទេ? ឆ្លើយ៤៤៖ តាគិត ជាលេខាតំបន់១៣ ប៉ុន្តែដោយសារគាត់មានជំងឺរបេង ដូច្នេះគាត់ធ្វើជាលេខាតំបន់១៣ បានតែ១ឆ្នាំប៉ុណ្ណោះ ក្រោយមកទៀត គាត់ត្រូវបានគេបញ្ជូនទៅតំបន់២៥ នៅទឹកខ្មៅ។ នៅឆ្នាំ១៩៧៩ គាត់បានរត់ចូលព្រៃហើយចងអង្រឹងនៅក្នុងព្រៃដេកក៏ត្រូវកងទ័ពវៀតណាមបាញ់សម្លាប់តែម្តង។ សួរ៖ តើ តាគិត ធ្វើជាលេខាតំបន់១៣ នៅឆ្នាំណា? ឆ្លើយ៤៥៖ តាគិត ធ្វើជាលេខាតំបន់១៣ នៅឆ្នាំ១៩៧៧”។ សូមចប់ការដកស្រង់។ លោក ឯក ហឿន លោកចាំសក្ខីកម្មដែលខ្ញុំបានអានជូនលោកអម្បាញ់មិញនេះទេ?

**ឆ៖** បាទ វាវែងពេក វាចាំអត់ច្បាស់ ប៉ុន្តែដឹងថា តាគិត គាត់ឡើងធ្វើលេខាស្រុកនៅ៧៧ហ្នឹងហើយ។ ហើយគាត់ផ្លាស់ទៅទឹកខ្មៅនៅ១បានមួយឆ្នាំ គាត់ផ្លាស់ទៅទឹកខ្មៅ។ នៅទឹកខ្មៅហ្នឹង យួនចូលស្រុកបានគាត់រត់ចូលព្រៃរហូត។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា ឆ្នាំ៧៧ហ្នឹង ចុងឆ្នាំ ដើមឆ្នាំ កណ្តាលឆ្នាំ ឬពេលណា ឬក៏មានកាលៈទេសៈអីដែលអាចឲ្យលោកចាំបានទេថា លោកចូល -- តាគិត ហ្នឹងចូលមកកាន់តំណែងនៅពេលណា? ហើយចប់វិញនៅពេលណា? ដោយយោងទៅតាមរដូវជាដើម។

[១៤:១៩:១៣]

**ឆ៖** បាទ អត់ចាំថ្ងៃខែហ្នឹង អត់តែម្តង បើគ្រាន់តែឃើញគាត់ទៅមិននឹកទន្ទេញឲ្យចាំមាត់ អត់

នឹកឃើញថាគាត់នៅធ្វើចៅហ្វាយខេត្តហ្នឹងពេលខ្លី។ ដល់ទៅទឹកខ្មៅ ខ្ញុំទៅជួបគាត់ទៀតរហូតទល់៧៧ ហើយហ្នឹង ហើយជួបគាត់សុំឡាន សុំអីគាត់បានទៅ។ ដល់៧៩ បានយួនចូលស្រុក បានគាត់រត់ចូលព្រៃហ្នឹង ដឹងតែអ៊ីចឹង អត់ដឹងថ្ងៃខែទេ។

**ស៖** ខ្ញុំស្តាប់លោកអត់ទាន់។ អំមិញលោកនិយាយថា៧៧ លោកបានជួបគាត់រឿងសុំឡានសុំអីហ្នឹង លោកចង់ជួបនៅតាខ្មៅ ឬមួយក៏ជួបនៅខាងតំបន់១៣?

**ឆ៖** បាទ ខ្ញុំ គាត់ទៅនៅទឹកខ្មៅ ទៅ ខ្ញុំទៅ៧៧ ហើយបានទៅ -- គាត់ទៅធ្វើចៅហ្វាយខេត្តទឹកខ្មៅ គេថានៅហ្នឹងឡានច្រើន។ អ៊ីចឹងប្រធានមន្ទីរហ្នឹង តាឈឿនហ្នឹង ឲ្យខ្ញុំទៅជាមួយយាយជាលទៅសុំឡានតាគិតបានមួយ ហើយមិនដឹងឆ្នាំណា ខែណា វាភ្លេចអស់ទៅណ៎ា វាយូរពេក។ ហើយបើដឹងគាត់កាន់អំណាចនៅទឹកខ្មៅហ្នឹងរហូតដល់ ៧៩ បានគាត់រត់ចេញ។ អត់ចាំថ្ងៃខែ។

**ស៖** បាទ សូមអរគុណ។ លោក សូមលោកបញ្ជាក់ឲ្យច្បាស់ តាខ្មៅ ឬមួយទឹកខ្មៅ កន្លែងដែលតាគិត ដែលដូរមកហ្នឹង?

**ឆ៖** បាទ កន្លែងហ្នឹងមិនដឹង តាខ្មៅ ឬទឹកខ្មៅទេ ចេះតែហៅតៗតាមគ្នាទៅ នៅកន្លែងហ្នឹងមានសាលាខេត្តពីមុនមក ទៅនៅចំកន្លែងពីខេត្តគេមុនហ្នឹង មិនដឹងហៅអីកន្លែងហ្នឹងអត់ដឹង ចេះតែហៅតៗគ្នាទៅ។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងការសុំឡានអំមិញលោកមានប្រសាសន៍ថា ទៅសុំឡាន តាគិត បានមួយ។ លោកមកសុំឡានហ្នឹងក្នុងឋានៈជាអ្វីដែរ?

**ឆ៖** បាទ ខ្ញុំជាកម្មករនៅមន្ទីរស្រុក១០៥ហ្នឹង។ ប្រធានមន្ទីរ –តាឈឿនហ្នឹង– ប្រើឲ្យមកពីរនាក់ជាល – មកពីរនាក់ជាល – អាជាល មីជាល ហ្នឹង។ សុំបាន គាត់ឲ្យឡានគេចាំ កាយសំរាមចេញយកទៅ។

[១៤:២១:៤១]

**ស៖** លោកមកសុំខ្លួនឯង ឬមួយក៏គេឲ្យហើយ គ្រាន់តែលោកមកយកទេ?

**ឆ៖** បាទ អត់មាន តាគិត អត់ឲ្យទេ។ ប្រធានមន្ទីរតាឈឿន ហ្នឹងប្រើខ្ញុំ ហើយតាជាល ហើយតាឈឿនហ្នឹងឃើញថាខ្ញុំ ហើយតាគិត ហ្នឹងនៅជិតខាងគ្នាគេស្គាល់គ្នាជិតស្និទ្ធ។ អ៊ីចឹងប្រើខ្ញុំឲ្យមកដល់មកទៅចូលផ្ទះគាត់ថា “នែ៎! អាមេចោរមករកអី?” ហើយខ្ញុំថា “ លោកពូៗឡានច្រើនណាស់ ខ្ញុំសុំឡានមួយ មកសុំឡាន” “យី! ឡានគេចោលអស់ហើយ ហ្អែងមកយកធ្វើអី? យកធ្វើកើត? បើហ្អែងធ្វើ

កើតយកប្អូន-ដប់ទៅ!"។ ដល់ពូហ្នឹងគាត់ទៅឲ្យអាល្អ។ ជាល អត់យក យកអាគេចោលសំរាមលុប។ អាចោលសំរាមលុបកាយដីអស់ ដេមីរ័រតែតិចឆេះៗ។ មកប្រាប់គាត់ថា៖ "ឡានខ្ញុំធ្វើឆេះហើយលោកពូ" "អាចម៍ទេ ខ្មោចងាប់មិនដែលអាណាយកធ្វើម៉េចបានរស់ទេ បើហ្អែងធ្វើឆេះអញឲ្យពីរបីហ្នឹង", ថា៖ "ឆេះហើយ"។ ដល់អ៊ីចឹងគាត់មកមើល មកមើលឡានអត់ដេមីរ័រ មកដល់រុញអង្គើៗឆេះៗ គាត់សើច គាត់ថា " ហ្អែងត្រូវការអាណា ទៅលើកយកទៅ"។ គាត់ថាអ៊ីចឹង ប៉ុន្តែយកតែមួយហ្នឹង។

**ស៖** បាទ លោកអាចបញ្ជាក់កាលបរិច្ឆេទបានទេ ពេលដែលលោកមកសុំឡានហ្នឹង ឆ្នាំណា?

**ឆ៖** ឆ្នាំ ៧០ -- ៧៧ ប៉ុន្តែមិនដឹងខែប៉ុន្មានទេ អត់ដឹងទេ។

**ស៖** លោកអាចក្តាប់បានៗថាវាជារដូវវស្សា រដូវប្រាំងអី ទេ?

**ឆ៖** បាទ រដូវប្រាំង ខែបង្កងត្រូវ។ បង្កងត្រូវៗ ហូបតែបង្កង ខែហ្នឹង ខែកត្តិកហើយ។

**ស៖** អ៊ីចឹងបានន័យថាចុងឆ្នាំ៧៧ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ បើជាខែកត្តិក។

**ឆ៖** បាទ ត្រឹមត្រូវហើយ ព្រោះ តាគិត ឲ្យបង្កងបីប្អូនកញ្ចេ ដឹកយកទៅ។

[១៤:២៤:០៣]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំចង់សួរទាក់ទងទៅនឹង តាសឿនម្តង លោកបានមានទំនាស់ជាមួយតាសឿន។ នៅក្នុងឯកសារដែលខ្ញុំបានអានជូនអម្បាញ់មិញនេះដដែល គឺ E319.131 ត្រង់សំណួរចម្លើយលេខ៤៨។ សួរសូមដកស្រង់៖ "តើ តាសឿន មានតួនាទីអ្វី? ឆ្លើយ៤៨៖ តាសឿនឡើងជាចៅហ្វាយស្រុកកោះអណ្តែត គាត់បានចាប់ខ្លួនអតីតគណ:ស្រុកកោះអណ្តែតទាំងបីនាក់ ហើយបញ្ជូនទៅសម្លាប់"។ សុំបិទការដកស្រង់។ លោកបានឆ្លើយបញ្ជាក់រួចហើយអំពីទំនាស់ដែលនាំឲ្យកើត រឿងលោកធាក់ តាសឿន ពីរជើង។ ខ្ញុំចង់សួរលោកថា កាល:ទេស:អីដែលនាំឲ្យមានការចាប់ខ្លួនគណ:ស្រុកកោះអណ្តែត ហើយដែល តាសឿន ត្រូវឡើងជំនួសវិញនោះ? លោកដឹងថាតើមានហេតុការណ៍អីដែលនាំឲ្យមានបញ្ហានេះទេ?

**ឆ៖** បាទ ត្រង់ហ្នឹងវាច្បាស់ណាស់ហើយ ដែលគេចាប់ចៅហ្វាយស្រុកកោះអណ្តែតទាំងបីនាក់ហ្នឹង ប្រធាន អនុប្រធាន សមាជិកហ្នឹង។ ចាប់ហើយ តាសឿន វានាទីជានគរបាលដើរចាប់។ នគរបាលហ្នឹងនគរបាលតំបន់។ ដើរចាប់គេហើយ តាសឿន យកមនុស្សហ្នឹងទៅប្រគល់ឲ្យ តាឈឿន ប្រធានមន្ទីរហ្នឹងហើយ, តាឈឿន បញ្ជូនឲ្យ យាយខុម ហើយក៏ តាសឿន ហ្នឹងឡើងកាន់អំណាចជាមួយ តាយ៉ែវ ហ្នឹងទៅ។ ពេលហ្នឹងអ៊ីចឹងទេ។ ហើយមនុស្សហ្នឹងមិនដឹងជាទំនាស់នយោបាយស្អីខ្លះ មិនដឹង

សេ.អ៊ី.អា ក៏មិនដឹង, កា.ហ្សេ.បេ ក៏មិនដឹងដែរ គេចាប់ហ្នឹង មិនដឹងរឿងអីទេ។

**ស៖** លោកបានបញ្ជាក់រួចហើយថាលោកអត់ស្គាល់អ្នកទាំងបីនាក់ហ្នឹងទេ។ ខ្ញុំចង់សួរលោកថា តើលោកដឹងពីជោគវាសនាអ្នកទាំងបីនាក់ហ្នឹងទេ នៅក្រោយមកទៀត?

**ឆ៖** បាទ អត់ដឹងទេ បើគេបញ្ជូនទៅបាត់ៗហើយ មិនដែលនាំខ្លួនមកវិញទេ។ គេយកកៅអីគាត់អង្គុយអស់តាំងពីថ្ងៃគាត់ចេញផុតហ្នឹង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងទំនាស់សហករណ៍ លោកបានលើកពីម្សិលមិញប្រហែលម៉ោងមួយនិងហាសិបនាទី ហើយដែលលោកនិយាយថាគេយកទៅព្រៃ ហើយអាចគេយកទៅសម្លាប់ដោយសារតែមានទំនាស់សហករណ៍។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើអ្វីទៅដែលហៅថា “ទំនាស់សហករណ៍”?

[១៤:២៨:១៦]

**ឆ៖** បាទ រឿងទំនាស់សហករណ៍ហ្នឹង វាមិនជារឿងធំដុំអីទេ វាជាទំនាស់ស្រាលទេ។ ដូចគេធ្វើសហករណ៍ហ្នឹង គេប្រមូលចានប្រមូលឆ្នាំងអស់ ប្រមូលអស់គ្រប់គ្នាហើយ គេដាក់ ដល់តែនៅយាយសៀក ប្អូនជីដូនមួយជាមួយ តាម៉ុក គាត់អត់ឲ្យ គាត់អត់ដាក់ រទេះសេះមួយក៏គាត់អត់ដាក់។ យាយខុមដឹងថាយាយហ្នឹងអត់ដាក់ យាយខុម ក៏ខ្ចីរទេះ។ ដល់ខ្ចីរទេះមួយខែ គាត់ថាគាត់កំណត់មួយខែឲ្យទៅយកវិញ។ កំណត់មួយខែ យាយសៀក ទៅយកវិញមក។ ដល់យកវិញ គេឲ្យ តារស់ ដែលប្រជាជនកាប់ជ្រាំងហ្នឹងចាប់ យាយសៀក ហ្នឹងចងមុខ។ ចាប់ចងមុខទៅ ទៅតាមផ្លូវឡាន តាម៉ុក ដែលចេញពីព្រៃ។ តាម៉ុក ឃើញ “ហ្អែង! ចងមុខអាណា?” ថា “ខ្មាំងតា” “យីស! ហ្អែងខ្លួនទទេទៅចាប់ខ្មាំងបាន? អាណាគេ ហ្អែងស្រាយមុខមើល? ស្រាយមុខចេញ! មីក្សៀកហ្នឹង? ចុះហ្អែងទៅធ្វើអីមីក្សៀក? មីក្សៀកមនុស្សកំណាញ់ ហ្អែងទៅធ្វើអីគេ? ម៉ោះមីក្សៀកឡើងឡានមក! ហ្អែងថ្ងៃក្រោយតែអត់មីក្សៀក ហ្អែងហ្នឹងហើយ អត់អាណាទេ”។ យកយាយសៀក មកទុករហូតដល់ឥឡូវហ្នឹង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងករណីហ្នឹង លោកអាចបញ្ជាក់បានទេថា លោកដឹងដោយរបៀបណា?

**ឆ៖** បាទ ដែលគេចាប់យាយ សៀក ហ្នឹង? មិនដឹងសួរត្រង់ចំណុចណាអំមិញ។

**ស៖** បាទ ទាក់ទងនឹងករណីដែលចាប់ យាយសៀក ហ្នឹង?

[១៤:២៩:៤៥]

**ឆ៖** បាទ ទាក់ទងហ្នឹងរឿង យាយខុម មកយករទេះគាត់ ហើយគាត់អត់ឲ្យ ដល់គាត់ទៅយកមកវិញ បានគេឲ្យប្រើ អារស់ ដែលគេកាប់ហ្នឹង មកយកយាយសៀក ហ្នឹងទៅព្រៃហ្នឹង។

**ស៖** បាទ សំណួររបស់ខ្ញុំអ៊ីចេះ ថាតើលោកដឹងដោយរបៀបណា? ម៉េចបានលោកដឹងករណីហ្នឹង?

**ឆ៖** បាទ នៅភូមិជាប់គ្នា ធ្វើអីក៏ដឹងដែរ។ ភូមិៗត្រពាំងឈូក ហើយត្រពាំងប្រីយ៍ ភូមិជាប់របងគ្នាហ្នឹង។ ដឹងទាំងយប់ ទាំងថ្ងៃ ដឹងទាំងអស់ ជិតៗគ្នា។

**ស៖** លោកបានឃើញហេតុការណ៍ហ្នឹងផ្ទាល់ភ្នែកទេ?

**ឆ៖** អត់បានឃើញទេ។ គេនិយាយគ្រប់តែគ្នា អត់លាក់ផង។ ដឹងតែ តាម៉ុក ជួយ។

**ស៖** ចុះពាក្យដែលលោកនិយាយថា គេយកទៅព្រៃហ្នឹង អាហ្នឹងវាយ៉ាងម៉េច លោកអាចបញ្ជាក់បានទេ?

**ឆ៖** បានតើ! គេយកទៅព្រៃ គេយកទៅធ្វើបាបហើយ អត់បានត្រឡប់មកវិញទេ ប៉ុន្តែបានព្រះឥន្ទ្រ ព្រះព្រហ្មលោកជួយ តាម៉ុក ក៏ជួយរួចទៅ។ លែងមាននរណាហ៊ានប៉ះពាល់ យាយ សៀក។ លែងហ៊ានប៉ះពាល់ យាយសៀក តទៅទៀតហើយ។

[១៤:៣១:០៥]

**ស៖** លោកអាចពន្យល់មានករណីអីផ្សេងទៀត ទាក់ទងទៅនឹងទំនាស់សហករណ៍ហ្នឹងដែរទេ?

**ឆ៖** បាទ មានទំនាស់សហករណ៍ដូច យប់ឡើង វាបាត់ចាន បាត់ឆ្នាំង បាត់នង្គ័ល រនាស់ យកបោះដាក់ទឹកអស់។ អ៊ីចឹងគេស្រាវជ្រាវរកឃើញ គេអត់ធ្វើបាបទេ គេវាស់ដីឲ្យរែក។ រែកដីមួយខែពីរខែអ៊ីចឹង គេឲ្យរួចមកជាអ្នកជាវិញទៅ គេអត់ធ្វើអីទេ។

**ស៖** សូមលោកជួយពន្យល់បន្ថែមបន្តិច ដោយសារខ្ញុំស្តាប់អត់សូវយល់ ទាក់ទងទៅនឹងលោកមានប្រសាសន៍ថា ទំនាស់សហករណ៍ជាទំនាស់តូចតាច គេមិនធ្វើបាបទេ ប៉ុន្តែបែរជាមានយកទៅព្រៃ។ លោកចង់បញ្ជាក់យ៉ាងម៉េចពីៗចំណុចហ្នឹង ថាតើវាៗធ្ងន់ធ្ងរប៉ុនណាទាក់ទងនឹងទំនាស់សហករណ៍ហ្នឹង?

**ឆ៖** បាទ ទំនាស់សហករណ៍មានតែ យាយសៀក មួយហ្នឹងទេ ដែលយាយខុម គាត់ធ្វើស្រេចតែចិត្តគាត់។ គាត់យកទៅព្រៃហ្នឹង ហើយទៅមិនបានដល់ព្រៃទេ អាហ្នឹងក្រៅពីហ្នឹង គ្រាន់តែជីកដំឡូងជីកអីស៊ី ក៏គេអត់ថាអីដែរ។ រែកដី ក៏អត់រែកដែរ។ ជីកដំឡូង ជីកអី ដំឡូងរួមហ្នឹង គេអត់ថាអត់អីទេ។ គេថាស៊ីៗទៅដើម្បីធ្វើការ។ ដល់ធ្វើការ គឺការងាររួម ហ្អែងស៊ីប៉ុន្មានស៊ីទៅ របស់ហ្អែងដាំដែរ។ ហ្នឹងមេ

ឃុំគាត់ប្រើនយោបាយនៅភូមិមួយៗ គេនិយាយតែអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ ចុះលោកបែងចែកទំនាស់សហករណ៍ ហើយនិងកំហុសដទៃទៀត ឬក៏ទោសដទៃទៀតបានទេ ឧទាហរណ៍ដូចជាផ្នែកសីលធម៌ជាដើម។ អាហ្នឹង វាខុសគ្នាយ៉ាងម៉េចដែរ?

[១៤:៣២:០៤]

**ឆ៖** បាទ រឿងសីលធម៌ ហើយអារឿងទំនាស់កំប៉ិកកំប៉ុកក្នុងភូមិគេថាជាមែកជាធាង មិនមែនជាឫសជាគល់ទេ។ អាទំនាស់សីលធម៌ហ្នឹង គេយកមកដាក់សាលាកែប្រែហ្នឹងសឹងតែទាំងអស់គ្នា មួយសាលាកែប្រែហ្នឹង សុទ្ធតែរឿងសីលធម៌ហ្នឹងហើយ។ គេឲ្យរែកដី យប់ឡើងដេកវិញទៅ ថ្ងៃរែកដី។ អាហ្នឹងទំនាស់រឿងសីលធម៌។ ទំនាស់បាត់នង្គ័ល បាត់រនាស់ហ្នឹង គឺគេទុកស្មើអាសីលធម៌ហ្នឹងដែរ។ គេអត់ធ្វើអីទេ គេគ្រាន់តែវាស់ដីរែកហ្នឹង។

**ស៖** បាទ លោកបានបញ្ជាក់ច្រើនដងហើយទាក់ទងទៅនឹងសាលាអប់រំកែប្រែ ហើយជាពិសេសគឺទាក់ទងទៅនឹងទំនាស់តូចតាច ដែលលោកថាគេយកទៅធ្វើការអប់រំកែប្រែ។ ហើយបើសិនជាមានការកែប្រែល្អ ជាប់តែក្នុងរយៈពេលកន្លះខែអី គេដោះលែងវិញហើយ ហើយគ្មានអ្នកណាគេយកទៅសម្លាប់ទេ។ លោកបានបញ្ជាក់ទៀតពីព្រឹកមិញនេះក្តី ទាក់ទងទៅនឹងកន្លែងសម្លាប់អប់រំកែប្រែហ្នឹង និងផ្ទះរបស់លោកហ្នឹង គឺនៅក្បែរគ្នា ហើយលោកឧស្សាហ៍ចេញចូលទៅដែរ។ តើលោកដឹងពីកម្មវិធីអ្វីខ្លះដែលគេប្រើសម្រាប់អប់រំអ្នកដែលត្រូវយកទៅអប់រំកែប្រែហ្នឹងទេ។ ឧទាហរណ៍ថា មានមេរៀនអ្វីខ្លះដែលត្រូវរៀន ត្រូវសិក្សា ដើម្បីឲ្យមានការកែប្រែឡើងវិញ?

**ឆ៖** បាទ ខ្ញុំឃើញច្បាស់នឹងភ្នែក។ បើកាលតាជឹមនៅ តែខូចកាចអ៊ីចឹង តែត្រូវរួចខ្លួន គេថាមនុស្សហ្នឹងល្អ ខំធ្វើការ។ តាជឹម យកមកអប់រំថា "ឥឡូវមិត្តឯងខូចសីលធម៌ប្រពន្ធកូនគេ មិត្តឯងធានាថាឲ្យយុទ្ធជន យុទ្ធនារីទៅសមរភូមិមុខ។ ខ្ញុំជាប្រធានភូមិធានារ៉ាប់រងហ្អែង ទៅរ៉ាប់រងប្រពន្ធគេ ឥឡូវហ្អែងមានរឿង ឥឡូវហ្អែងកែប្រែនៅ?" អប់រំថាអ៊ីចឹង។ វាថាវាកែប្រែ វាកោរថាំ កាត់កន្ទុយលាបកំបោរអ៊ីចឹង។ គាត់ថា៖ "ចុះឥឡូវបើហ្អែងកែប្រែ ហ្អែងកាត់កន្ទុយលាបកំបោរ ហ្អែងទៅវិញ ហ្អែងធ្វើម៉េចតែថ្ងៃក្រោយមកទៀត ធ្ងន់ហើយ"។ គាត់ថាអប់រំតែប៉ុណ្ណឹង អត់មាននិយាយអីប្លែកទេ អង្គុយស្តាប់គាត់អប់រំ យកមកកន្លែងហ្នឹង។

[១៤:៣៥:៤០]

**ស៖** បាទ សូមអរគុណ។ អំមិញនេះលោកថាលោកអង្គុយស្តាប់ តាជឹម អប់រំអ្នកដែលខុស

សីលធម៌។ លោកអង្គុយស្តាប់យ៉ាងម៉េច លោកអាចបញ្ជាក់បានទេ? ដើម្បីឲ្យមានទំនាក់ទំនងថាលោកមានតួនាទីអីនៅក្នុងពេលហ្នឹងដែរ?

**ឆ៖** បាទ កន្លែងហ្នឹងគេអប់រំចំហ ស្ទើតែអ្នកនៅពាណិជ្ជទាំងអស់ ឈរស្តាប់ទាំងអស់ គេអត់បិទបាំង អត់លាក់ការណ៍អីទេ។ គេអប់រំល្អ មានអ្នកណាលាក់បាំង អ្នកណាក៏ឈរស្តាប់ទាំងអស់គ្នាហ្នឹង ក្នុងមន្ទីរពាណិជ្ជហ្នឹង កម្លាំងក្នុងកម្មករហ្នឹងឈរស្តាប់គ្នាទាំងអស់។ គេអត់មានតួនាទីអី គេឈរស្តាប់ យកពិសោធពីគាត់ យកពិសោធពីអាមនុស្សសីលធម៌ហ្នឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីរបៀបដែល តាជឹម គាត់ធ្វើការបានទេ នៅពេលដែលគាត់ធ្វើការអប់រំអ្នកដែលខុសសីលធម៌ហ្នឹង? គាត់ដាក់នៅកន្លែងណា? អង្គុយយ៉ាងម៉េច? មានអ្នកដែលឈរមើល ដែលលោកមានប្រសាសន៍ថា អ្នកណាក៏អាចឈរមើលបានដែរហ្នឹង។ នៅកន្លែងណា? ហើយមានអ្នកឈរមើលហ្នឹងចំនួនប៉ុន្មាននាក់ដែរជាមធ្យម នៅពេលដែលដោះស្រាយម្តងៗ?

**ឆ៖** បាទ សូមជម្រាបថា ក្នុងពាណិជ្ជហ្នឹងមានប្រាំប្រាំមួយនាក់ ហើយកាត់ដេរមានមួយក្រុមជាង១០នាក់ហ្នឹង មកឈរមើលទាំងអស់ ហើយកន្លែងអប់រំហ្នឹងនៅជឿងផ្ទះថ្ម ឥដ្ឋរនាបហ្នឹងដាក់ជើងមួយ។ អាអ្នកសីលធម៌ក៏អង្គុយជាមួយ តាជឹម។ តាជឹម ក៏អង្គុយមួយគ្នា អង្គុយលើគ្រែហ្នឹង។ អ្នកណាស្តាប់ៗទៅ គាត់និយាយមិនមែននិយាយកាប់សម្លាប់ឯណា គាត់និយាយអប់រំឲ្យល្អ ឲ្យថ្ងៃក្រោយឲ្យរាងចាល។ គេស្តាប់បានហូរហែទាំងអស់គ្នាហ្នឹង។

[១៤:៣៧:៣៦]

**ស៖** បាទ សូមអរគុណ។ ចុះមានអ្នកស្រុកដែលមានផ្ទះនៅក្បែរហ្នឹងៗមានឈរស្តាប់ដែរទេ?

**ឆ៖** បាទ អត់ទេ។ អ្នកស្រុកអត់ហ៊ានចូលមក មានតែនៅក្នុងមន្ទីរហ្នឹង ដូចពួកកាត់ដេរ ពួកនៅកន្លែងចាត់ការហ្នឹង សុទ្ធតែកម្មករហ្នឹងឈរស្តាប់តែទាំងអស់គ្នា។

**ស៖** បាទ សូមអរគុណ។ លោកដឹងថា អ្នកដែលត្រូវ តាជឹម ហៅយកមកអប់រំណែនាំមកហ្នឹងមកពីស្រុក ឬក៏មកពីភូមិឃុំណាដែរទេ?

**ឆ៖** បាទ មកច្រើននៅឃុំខ្ពបត្របែក។ ខ្ពបត្របែកមកហើយមកទៀតៗ តែដដែលៗហ្នឹង ថាឲ្យរាង ថារាងហើយ លែងទៅវិញបានមួយអាទិត្យមកទៀតហើយ។ មកទៀត តាជឹម ថា "ហ្អែងលើកនេះត្រូវទេហើយហ្អែង ច្រើនសាហើយ ហ្អែងថារាង កាត់កន្ទុយលាបកំបោរហើយ នៅហ្អែងតែធ្វើដដែលធ្ងន់ហើយលើកនេះ" ថាតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងចំណុចមួយទៀត ដែលលោកមានប្រសាសន៍ក្នុងរយៈពេលពីរថ្ងៃនេះដែរ គឺទាក់ទងទៅនឹងចំណារប៊ិកក្រហម ប៊ិកខៀវ ដែលលោកបានបញ្ជាក់ថា បើមានគូសរង្វង់ក្រចកប៊ិកក្រហម អាហ្នឹងត្រូវអាចស្រុកយកទៅចាប់ កម្លាំងស្រុកចុះទៅចាប់ ឬក៏បញ្ជាទៅឃុំឲ្យចាប់ជាដើម។ លោកនៅចាំចំណុចនេះទេ?

[១៤:៣៩:៤៨]

**ឆ៖** បាទ ដឹងតែរឿងរង្វង់ក្រចកទឹកប៊ិកក្រហមហ្នឹង មិនដឹងគេសម្រេចពីថ្នាក់ណាទេ ប៉ុន្តែបើដូចថា ស្រុកដឹងថាមនុស្សវាស្រពេចស្រពិល គេឲ្យកងស្រុកហ្នឹងយប់ឡើងទៅលួចស្តាប់ក្រោមគ្រែ ដេកស្តាប់ក្រោមគ្រែ ដេកលើកទី១និយាយអ៊ីចឹង ដល់យប់ក្រោយទៅលួចស្តាប់ទៀត លើកទី២អ៊ីចឹង។ ដល់អ៊ីចឹងមានទឹកប៊ិកក្រហមផ្ញើទៅឲ្យមេកងស្រុកហ្នឹង មេកងស្រុកគេចាត់ចែងហើយ ព្រោះវាច្រើនសាហើយ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការលួចស្តាប់ដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ ជាការលួចស្តាប់ចំពោះបុគ្គលដែលគេត្រូវធ្វើការតាមដាន ឬមួយក៏ការលួចស្តាប់ជាទូទៅគ្រប់ប្រជាពលរដ្ឋទាំងអស់?

**ឆ៖** បាទ កន្លែងហ្នឹងអត់ថាថ្មី អត់ថាចាស់ទេ ឲ្យតែគេស្រពេចស្រពិល ប្រហាក់ប្រហែល គេឲ្យកងគេទៅលបស្តាប់ហើយ អត់ថាថ្មី ថាចាស់ទេ លួចស្តាប់ទាំងអស់។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំគឺចង់សំដៅទៅលើថា នៅពេលដែលគេទៅលួចស្តាប់នរណាម្នាក់ បានន័យថាអ្នកនោះជាប់ពាក់ព័ន្ធ ឬក៏ការសង្ស័យណាមួយទៅនឹងអំពើអ្វីមួយ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ គេធ្វើតែដដែលៗតែអារឿងហ្នឹងរហូត។

**ស៖** ខ្ញុំសូមសួរបន្តថា ហេតុម្តេចបានលោកអាចដឹងពីការទៅលបស្តាប់អ្នកណាម្នាក់នេះ?

[១៤:៤១:៣៨]

**ឆ៖** បាទ កងស្រុកតែវាធ្វើការចប់វាមកលេងកន្លែងមន្ទីរហ្នឹងហើយ ៗមកថា "ហ៊ឺ! អញប្រញាប់ទៅវិញ គេឲ្យអញទៅដេកស្តាប់ផ្ទះនេះ ផ្ទះនោះអ៊ីចឹងទៅ។ និយាយគ្នាថា ឯងទៅស្តាប់គេធ្វើអីហ៎ាយប់ឡើង? ទៅស្តាប់គេៗឲ្យតាមដាន អាមនុស្សហ្នឹងវាយប់ឡើងវានិយាយខុសពីមុខរបរយើងធ្វើការនិយាយពីរឿងនយោបាយ នយោអីហ្នឹង គេឲ្យទៅស្តាប់ហើយ"។ អាហ្នឹងវាមកក្នុងកន្លែងស្រុកហ្នឹង វា

ចេះតែនិយាយ អត់លាក់ អត់អាថ៌កំបាំងអីទេ វាចេះតែនិយាយ យើងដឹងហើយ ឮបាន ចាំបានហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ លោក ឯក ហឿន ឥឡូវហ្នឹងដល់ពេលសម្រាកហើយ យើងសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលមកកន្លែងផ្ដល់សក្ខីកម្មវិញដើម្បីបន្តការផ្ដល់សក្ខីកម្មតទៀត។ លោកស្ដាប់ឮទេ?

**លោក ឯក ហឿន៖**

បាទ ឮ។

**ប្រធានអង្គជំនុំ៖**

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្ដល់វេទិកាជូនទៅលោកមេធាវី គង់ សំអុន។ តើលោកមេធាវីប្រើប្រាស់ពេលវេលាទំនងប្រហែលជាប៉ុន្មានទៀតដើម្បីអង្គជំនុំជម្រះមានលទ្ធភាពពិចារណា សម្របសម្រួលជាមួយខាងអ្នកអង្គភាពដឹកជញ្ជូនក្នុងការពន្យារពេលដើម្បីដឹកជញ្ជូនមន្ត្រីរាជការត្រឡប់ទៅលំនៅដ្ឋានវិញ ព្រោះថ្ងៃនេះ ថ្ងៃសុក្រ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំប្រហែលជាអាចបញ្ចប់មុនម៉ោងបួន។ ដូច្នេះអាចខ្វះ២០-៣០នាទីទៀតនឹងចប់បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អ៊ីចឹងមិនអីទេ។

**ប្រធានអង្គជំនុំ៖**

សួស្ដីលោក ហឿន តើបានត្រៀមខ្លួនហើយនៅ?

**លោក ឯក ហឿន៖**

បាទ ត្រៀមខ្លួនរួចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ចាំស្ដាប់ និងឆ្លើយតបទៅនឹងសំណួរបន្តរបស់មេធាវីការពារក្ដីលោក ខៀវ សំផន។

បាទ សូមអញ្ជើញលោកមេធាវី!

[១៥:០៣:៣២]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក ឯក ហឿន មុននេះអំមិញ យើងពិភាក្សាគ្នាអំពីការគូសបិកក្នុរហម-ខៀវ ជារង្វង់ក្រចកនៅចំពោះឈ្មោះអីជាដើម។ បាទ តទៅនេះ ខ្ញុំសូមអានជូនទូវឯកសារមួយដែលមានលេខ E319.1.32 ត្រង់សំណួរចម្លើយលេខ៤៤។ សូមដកស្រង់៖ "ពេលដែលលោកនៅស្រុកត្រាំកក់ តើលោកធ្លាប់ឃើញឯកសារណាដែលពាក់ព័ន្ធនឹងការបោសសម្អាតខ្មាំងដែរឬទេ? ឆ្លើយ៤៤៖ អត់ទេ"។ ខ្ញុំសូមសួរលោកថា តើលោកគាំទ្រថាសក្ខីកម្មរបស់លោកនេះត្រឹមត្រូវដែរទេ?

**លោក ឯក ហឿន៖**

**ឆ៖** បាទ អត់ៗច្បាស់ ចង់ឲ្យបញ្ជាក់មួយសាទៀត។

**ស៖** បាទ មិនថ្វីទេខ្ញុំសូមអានជូន។ ដកស្រង់ "សំណួរ៖ ពេលដែលលោកនៅស្រុកត្រាំកក់ តើលោកធ្លាប់ឃើញឯកសារណាដែលពាក់ព័ន្ធនឹងការបោសសម្អាតខ្មាំងដែរឬទេ? ឆ្លើយលេខ៤៤៖ អត់ទេ"។ សូមបិទការដកស្រង់។ នេះគឺជាសំណួរ សម្រង់សំណួរដែលសួរដោយសហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងសក្ខីកម្មរបស់លោក។ លោកចាំសម្រង់ដែលខ្ញុំអានជូនអម្បាញ់មិញទេ?

**ឆ៖** បាទ ចាំ ប៉ុន្តែរបស់អស់ហ្នឹង គឺអត់បានឃើញ អត់បានដឹងទេ។ អត់ដែលឃើញឯកសារ

គេគិតបោសសម្អាតហ្នឹង អត់ដែលឃើញសោះ គេមិនឲ្យយើងឃើញទេ គេលាក់របស់គេ។

**ស៖** បាទ សូមអរគុណ។ នៅឯកសារដដែល ត្រង់សំណួរចម្លើយលេខ៤០ ខ្ញុំសូមដកស្រង់៖ “សួរ៖ តើលោកធ្លាប់ឃើញផែនការសម្លាប់ជនជាតិវៀតណាម ដែលសរសេរជាលាយលក្ខណ៍អក្សរដែរឬទេ? ឆ្លើយ៤០៖ នៅខែ១០ ឆ្នាំ១៩៧៨ ខ្ញុំបានឃើញឯកសារដែលសរសេរអំពីផែនការសម្លាប់ជនជាតិវៀតណាម។ សួរ៖ តើឯកសារនោះនិយាយអំពីបោសសម្អាតជនជាតិវៀតណាមមែនទេ? ឆ្លើយ៤១៖ បាទ ដំបូង តាជឹម ឲ្យខ្ញុំទៅធ្វើការក្នុងឃ្លាំង ប៉ុន្តែពេលនោះ ឃ្លាំងពុំមានអ្វីនោះទេ ដូច្នេះខ្ញុំត្រឡប់មកចៀរជ័រវិញម្តង។ មានថ្ងៃមួយ ខ្ញុំចង់ជក់បារី ហើយក៏ឡើងទៅរកក្រដាសក្នុងធុងសំរាមមកមូរបារីជក់ រួចខ្ញុំក៏បានឃើញឯកសារនោះ ហើយតាជឹម បាននិយាយថា បើជក់បារីក៏ជក់ទៅ កុំមើល។ ពេលដែលតាជឹម និយាយដូច្នេះ ខ្ញុំក៏លួចមើលឯកសារនោះតែម្តង។ នៅក្នុងឯកសារនោះ គេសរសេរថា សូមមិត្តបោសសម្អាតខ្មាំងឲ្យអស់ជាបន្ទាន់ ព្រោះខ្មាំងច្រើនណាស់ក្នុងសហករណ៍ ពីសមមិត្តឃាង គណៈមន្ទីរ៨៧០”។ សូមចប់ការដកស្រង់។ ចំណុចនេះលោកចៅក្រម ឡាវ៉ែន៍ គាត់បានសួរបញ្ជាក់រួចហើយ។ ខ្ញុំសូមសួរលោកបន្ថែម ដំបូងសួរថាលោកចាំចំណុចនេះទេ?

[១៥:០៧:៥៣]

**ឆ៖** បាទ សូមជម្រាបប្រសាសន៍ ខ្ញុំបានអាន ខ្ញុំបានឃើញ គឺមិនមែនឯកសារទេ សំបុត្រសរសេរជាពីរបីម៉ាត់ហ្នឹង ក្រដាសតូចដែលត្រូវមូរថ្នាំជក់ហ្នឹង អត់មានឯកសារទេ ហើយសំបុត្រហ្នឹងមិនដឹងជាជនអនាមិក វាសរសេរយកដាក់ធុងសំរាម ហើយក៏សំបុត្រមែនទែន គ្រាន់តែមើលឃើញហើយ គេនិយាយថា “សូមមិត្តបោសសម្អាតខ្មាំងតាមសហករណ៍ សហជីពឲ្យអស់ជាបន្ទាន់ ព្រោះខ្មាំងនៅតាមសហករណ៍ សហជីពច្រើនណាស់ ធ្វើនៅខែ១០ ហត្ថលេខាសមមិត្តឃាង គណៈមន្ទីរ៨៧០”។ ឃើញតែប៉ុណ្ណឹង អត់មានឯកសារទេ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីទម្រង់លិខិតហ្នឹងបានទេ? វាជាអក្សរសរសេរដៃ ឬក៏មានវាដាក់ទីឡូ?

**ឆ៖** បាទ អត់សរសេរពុម្ពទេ អក្សរសរសេរដៃមើលអត់ចង់នឹងរួចផង ក្រវិកក្រវក់ៗ វា ដល់ខ្ញុំមិនច្បាស់ខ្លួនខ្ញុំ យកទៅឲ្យស្មៀនហ្នឹងគេជួយមើល គេថាដូចខ្ញុំអ៊ីចឹងដែរ។

**ស៖** បាទ សូមអរគុណ។ គេសរសេរនៅលើក្រដាសបែបម៉េចដែរ លោកចាំបានទេ?

**ឆ៖** បាទ ក្រដាសតូចមួយ តូចប៉ុនបាតដៃហ្នឹង សរសេរពីរបីម៉ាត់ហ្នឹង ល្មមតែយកមកមូរថ្នាំ

ជក់ តែមួយបារីហ្នឹង វាល្មមហ្នឹងហើយ។

**សៈ** ជាប្រភេទក្រដាសអីដែរ? ជាក្រដាសសៀវភៅ ក្រដាសពុម្ព ឬក្រដាសយ៉ាងម៉េច លោកអាចបញ្ជាក់បានទេ?

**ឆៈ** បាទ ភ្លេចដែរ ព្រោះក្រដាសកាលហ្នឹង គ្រាន់តែយកមក អត់ប៊ានទុកយូរផង ខ្ញុំជក់អស់ទៅ ហើយអត់បានពិនិត្យក្រដាស ក្រដាសហ្នឹងរបៀបក្រដាស ដូចពីដើមគេហៅថាក្រដាសពងមាន់ សស្អាតអ៊ីចឹង។

[១៥:០៩:៥៧]

**សៈ** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមចូលទៅប្រធានបទមួយទៀត ទាក់ទងទៅនឹងអាពាហ៍ពិពាហ៍។ លោកបានជម្រាបជូនអង្គជំនុំជម្រះមួយចំនួនហើយទាក់ទងចំណុចនេះ ខ្ញុំសូមលើកបន្ថែមទៅលើសក្ខីកម្មរបស់ យាយហឿន ដែលលោកបានស្គាល់។ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ លោកស្រី ខឹម ហឿន គាត់បានអញ្ជើញមកឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ហើយខ្ញុំសូមដកស្រង់នូវម៉ោង មុនម៉ោង ០៩:៥២:៥២ បាទ នៅពេលព្រឹក។ ខ្ញុំអានជូនហើយសូមលោក ឯក ហឿន ចាំស្តាប់ ហើយខ្ញុំនឹងតាំងសំណួរចំពោះលោក។ លោកស្តាប់បានទេលោក ឯក ហឿន? លោកឯក ហឿន លោកស្តាប់ខ្ញុំឮទេ?

**ឆៈ** បាទ ឮ ប៉ុន្តែស្តាប់អត់បាន។

**សៈ** បាទ ខ្ញុំជម្រាបលោកថាខ្ញុំនឹងអានសក្ខីកម្មរបស់ ខឹម ហឿន ដែលគាត់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសប្តាហ៍មុននេះ ហើយខ្ញុំនឹងតាំងសំណួរទៅលោក ដូច្នេះសូមលោកចាំស្តាប់។ សូមដកស្រង់៖ "សួរ៖ តើគេអប់រំថាយ៉ាងម៉េច លោកស្រីអាចលម្អិតបន្តិចបានដែរឬទេ? ឆ្លើយ៖ ចាស បាន។ អប់រំប្រជាជនថ្មីត្រូវរៀបចំជាមួយប្រជាជនថ្មី ហើយប្រជាជនចាស់ក៏អ៊ីចឹង ដើម្បីកុំឱ្យម៉្យាងទាស់គ្នា ម៉្យាងទៀតក៏មិនទាន់ស្គាល់ស៊ីចង្វាក់គ្នា ព្រោះប្រជាជនថ្មីវាទើបនឹងមកថ្មី ហើយប្រជាជនចាស់វាចាស់ហ្នឹង ចាស"។ ហើយក្រោយហ្នឹងពីរបីបន្ទាត់ គាត់ថែមទៀត សូមដកស្រង់៖ "ចាស ថ្នាក់ (ប្រហែលជាថ្នាក់លើ) ថាមិនឱ្យរៀបចំប្រជាជនថ្មីនិងប្រជាជនចាស់រៀបការជាមួយគ្នា ព្រោះប្រជាជនថ្មីទើបនឹងមកថ្មី ហើយការរៀបចំរស់នៅក៏ទើបតែនឹងរៀបចំរស់នៅ ហើយមិនស្គាល់គ្នា មិនទុកចិត្តគ្នា ហើយនិយាយក៏អត់ទុកចិត្តគ្នា។ នេះសូមជម្រាបការពិត។" សូមបញ្ចប់ការដកស្រង់។ លោក ឯក ហឿន លោកស្តាប់ខ្ញុំអានអម្បាញ់មិញបានទេ?

[១៥:១៣:១៨]

**ឆ៖** បាទ បាន។ បាទ ចំពោះប្រជាជនចាស់ ប្រជាជនថ្មីហ្នឹង ដូចអត់ដែលឮ ក្នុងស្រុកក្នុងឃុំ អត់ដែលមានលើករឿងហ្នឹងនិយាយ ឃើញតែរៀបការចាស់យកថ្មីៗយកចាស់ ដូចធម្មតាអ៊ីចឹង។ អត់ដែលមានឯកសារនិយាយអីទេ ឃើញតែរៀបទៅមកទៅអ៊ីចឹង។ ហូបចុកអីក៏ដូចគ្នា ស្លៀកពាក់អីក៏ដូចគ្នាសាមគ្គីគ្នាអត់ដែលទាស់ប្រកែកគ្នា អត់ដែលជជែកគ្នា អ្នកណាឈ្លោះគ្នាគេឲ្យរែកដី គេអត់ឈ្លោះទៅ។

**ស៖** បាទ សូមអរគុណ។ តាមលោកដឹងនៅក្នុងភូមិរបស់លោក ក្នុងឃុំរបស់លោក តើមានគូរស្រករណាដែលរៀបគ្នាដោយអ្នកមូលដ្ឋាន ជាប្រជាជនចាស់ រៀបការជាមួយអ្នកថ្មីដែរទេ?

**ឆ៖** បាទ ខ្ញុំភូមិខ្ញុំអត់មានទេ អត់មានប្រជាជនថ្មីទៅស្នាក់នៅផង។ គឺភូមិខ្ញុំគេថាភូមិគំរូៗ គេលំដាប់អស់ហើយ គេនៅតែផ្ទះ គេថា "ភូមិគំរូ"។

**ស៖** សូមលោកបញ្ជាក់ម្តងទៀត អំមិញលោកថានៅក្នុងភូមិរបស់លោកមិនមានប្រជាជនថ្មីទៅស្នាក់នៅទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** លោកអាចបញ្ជាក់បានទេថាហេតុអ្វីបានជាអត់មានអ្នកថ្មីទៅស្នាក់នៅ?

**ឆ៖** បាទ គឺថាភូមិហ្នឹងភូមិគំរូ ហើយអត់មានប្រជាជនថ្មីមកនៅ អត់មានប្រជាជនថ្មី លើសចំនួនផង បើមានចេះតែនៅបាន ប៉ុន្តែអត់មាន។ ប្រជាជននៅគ្រប់ភូមិ គ្រប់ឃុំ គ្រប់ស្រុកអស់ហើយ អត់មានមកដល់ហ្នឹង ផុតត្រឹមហ្នឹង អត់មានមនុស្សមកនៅ។

[១៥:១៥:០៩]

**ស៖** បាទ ចុះលោកមានដឹងពីអាពាហ៍ពិពាហ៍ដែលរៀបចំនៅក្នុងកម្ពុជា សម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង មានអាពាហ៍ពិពាហ៍ណាដែលធ្វើឡើងរវាងអ្នកមូលដ្ឋាន និងអ្នកថ្មីដែរទេ?

**ឆ៖** បាទ អត់ៗដែលដឹងទេ ព្រោះអត់ដឹងគេការគេអី គេការ អត់ដែលដឹង គេការតែគ្នាគេទៅ។ មេភូមិមេអី ការក្នុងឃុំមេឃុំក៏ចូលរួមទៅ បើការក្នុងភូមិមេភូមិគេចូលរួម ហើយយើងនៅមន្ទីរគឺអត់បានដឹង បានឃើញគេទេ។

**ស៖** បាទ អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់ម្តងទៀតថា លោកមិនដែលបានចូលរួមក្នុងអាពាហ៍ពិពាហ៍ណាមួយទេក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។ ខ្ញុំមកនៅជប់ហ្នឹង ឃើញគេរៀបអាពាហ៍ពិពាហ៍ហ្នឹងមាន ៤០០គូ

បាទ ៤០០គូ ឆ្នាំ៧៩ -- ន៉ែ ៧៨ ខែ៩ ហ្នឹងគេរៀប ៤០០នាក់ ហើយរៀបហើយ--

**ស៖** លោក ឯក ហឿន ខ្ញុំសួរពីនៅត្រាំកក់។ លោកមានព័ត៌មានទាក់ទងទៅនឹងអាពាហ៍ពិពាហ៍នៅស្រុកត្រាំកក់ដែរទេ?

**ឆ៖** បាទអត់ អត់ដែលដឹងគេការគេអីផង។ គេការរាល់ថ្ងៃ ប៉ុន្តែអត់បានចូលរួម អត់ដែលបានដឹងទេ។

**ស៖** លោកមានព័ត៌មានទាក់ទងទៅនឹងអាពាហ៍ពិពាហ៍ណាដែលកើតឡើងដោយបង្ខំដែរទេ នៅក្នុងទីកន្លែងដែលលោករស់នៅនោះ?

**ឆ៖** បាទ ទាល់តែសាមីខ្លួនហ្នឹងគេធ្វើសំបុត្រជូនទៅ ដូចថាអង្គការស្រុកគេជូនថា គេស្រឡាញ់ឈ្មោះ "ក" ហើយពីបញ្ជីគេឈ្មោះ "ក", ឈ្មោះ "ខ" គេសុទ្ធតែស្នើអស់ហើយ ស្នើមកអង្គការស្រុក អង្គការឃើញការស្នើគ្រប់កន្លែងបានច្រើនទៅ អង្គការរៀបចំការឲ្យ។ ដល់ការឲ្យហើយ វាអត់យកអាគូដែលវាស្រឡាញ់ហ្នឹង វាទៅយកអាររបស់គេរត់ទៅព្រៃបាត់ទៅ ហ្នឹង៧៩ ហ្នឹង។ ន៉ែឆ្នាំ៨០ ខែ១១, ១០ អីហ្នឹង--

**ស៖** អត់អីទេលោក ឯក ហឿន កាលណាក្រោយ៧៩ ខ្ញុំអត់សួរលោកពីចំណុចនេះទេ។ ខ្ញុំចង់ដឹងពីមុនថ្ងៃ០៧ មករា ១៩៧៩។ លោក ឯក ហឿន ខ្ញុំសុំបញ្ចប់ចំណុចនេះ។ ឥឡូវ ខ្ញុំសុំសួរលោកទាក់ទងទៅនឹង ពេជ្រ ជឹម ដែលលោកបានឆ្លើយថាជាបងថ្លៃរបស់លោក។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ពិតណាស់ត្រឹមត្រូវហើយ។ ប៉ុន្តែគេលែងប្រពន្ធតាំងពីឆ្នាំ៨០ ខែ០៧ លែងមកជិតមកបៀតប្រពន្ធកូនគេតាំងពីហ្នឹង ថ្ងៃហ្នឹងទៅ ដូចជាអ្នកដទៃអ៊ីចឹង។

[១៥:១៨:២៥]

**ស៖** បាទ សុំអរគុណ។ លោក និងលោក ពេជ្រ ជឹម ស្គាល់គ្នាពីពេលណាដែរ? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ស្តាប់ត្រង់ហ្នឹងអត់បាន មានពីពេលណាម៉េច?

**ស៖** ខ្ញុំសួរលោកថា លោកស្គាល់លោក ពេជ្រ ជឹម ពីដំបូងនៅឆ្នាំណាដែរ?

**ឆ៖** បាទ សុំជម្រាបប្រសាសន៍ ភូមិនៅជាមួយគ្នាហ្នឹង ស្គាល់ទាំងម៉ែ ទាំងឪ ទាំងយាយ ទាំងតា ទាំងបង ទាំងប្អូន ទាំងអស់ដូចបងប្អូនបង្កើតអ៊ីចឹង នៅភូមិជាមួយគ្នាហ្នឹង ស្គាល់រហូតទាល់សព្វថ្ងៃហ្នឹង ប៉ុន្តែនៅតែស្គាល់ហ្នឹង។

**ស៖** បាទ សុំអរគុណ។ លោកដឹងថាលោក ពេជ្រ ដឹម គាត់នៅស្រុកត្រាំកក់ហ្នឹង ហើយចេញទៅកំពង់ចាមហ្នឹង ទៅខាងជប់ ខាងចម្ការកៅស៊ូហ្នឹង នៅពេលណា? លោកចាំបានទេ?

**ឆ៖** បាទ ចេញទៅហ្នឹងវាពីរដំណាក់ ៧៧ ខែ៣ គាត់ចេញទៅភូមិភាគឧត្តរ ទៅនៅកាន់កាប់ចម្ការកៅស៊ូ ចម្ការអណ្តូង។ ដល់ឆ្នាំ៧៨ ខែ៨ គាត់ចេញទៅកាន់នៅរោងចក្រជប់ ប៉ុនចម្ការកៅស៊ូ ចម្ការដូងនៅជប់ហ្នឹង នៅគាត់គ្រួតត្រាទាំងពីរហ្នឹងក្នុងអង្គភាពតែមួយទេ។

[១៥:១៩:៥៥]

**ស៖** បាទ សូមអរគុណ។ ចុះពេលដែលលោកចេញពីត្រាំកក់ទៅខាងកំពង់ចាម ទៅចម្ការកៅស៊ូហ្នឹង ដល់ពេលហ្នឹង លោក ពេជ្រ ដឹម គាត់មកដល់ចម្ការកៅស៊ូហើយឬនៅ? លោកបានជួបគាត់ទេ?

**ឆ៖** បាទ ខ្ញុំទៅដល់ម៉ោងប្រាំព្រឹក។ ទៅមួយយប់បានដល់។ ទៅដល់គាត់នៅចម្ការកៅស៊ូជប់ហ្នឹងហើយៗ។ គាត់ផ្លាស់ពីចំម្ការដូងមក មកនៅជប់ហ្នឹង។

**ស៖** អ៊ីចឹងបានន័យថា ពេលដែលលោកទៅចម្ការកៅស៊ូ លោកបានជួប ពេជ្រ ដឹម នៅក្នុងថ្ងៃដំបូងនៃការទៅដល់របស់លោក។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទត្រឹមត្រូវហើយ។ ជួបៗព្រឹកឡើង គេមកបើកវគ្គចាត់ចែងកម្លាំងដែលគេយកទៅហ្នឹងកាន់ៗតំណែងគ្រប់មូលដ្ឋាន គ្រប់កន្លែងទាំងអស់។ អត់តែខ្ញុំ គេអត់ចាត់តាំងផង មានធ្វើការអីនឹងគេ។

**ស៖** បាទ សូមអរគុណ។ ចុះក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ តើលោកមានទំនាស់អ្វីជាមួយ ពេជ្រ ដឹម ដែរទេ?

**ឆ៖** បាទ អត់ទេ មានតែរណបគេ គេធ្វើគ្រូទៅរណបគេ គេធ្វើចៅហ្វាយស្រុករណបវា អត់ដែលប៉ះពាល់ឆ្គងពាក្យ ឆ្គងសម្តីអីទាល់តែសោះ។

[១៥:២១:២៨]

**ស៖** បាទ សូមអរគុណ។ ចុះក្រោយមកលោកមានបញ្ហាអីជាទំនាស់ផ្ទាល់ខ្លួនជាមួយនឹង ពេជ្រ ដឹម ដែរទេ?

**ឆ៖** បាទ ក្រោយមក រឿងហ្នឹងវាវែងណាស់។ ខ្ញុំសូមលើកឡើងពេល៧៩ យួនចូលស្រុក រូបខ្ញុំព្រៃ។ ចូលព្រៃជាមួយ តាដឹម ហ្នឹង។ ដល់ចូលព្រៃដល់ឆ្នាំ៨០ -- ចូលឆ្នាំ៧៩ ដល់ឆ្នាំ៨០ ខែ០១ គាត់ហៅខ្ញុំថាទៅប្រជុំ។ ដល់ខ្ញុំទៅប្រជុំ គេថា គ្រាន់តែទៅដល់ គេដាក់ផែនការឲ្យខ្ញុំកាប់ចម្ការ។ ដល់ខ្ញុំកាប់ចម្ការ ខ្ញុំធ្វើអត់ទាន់បានទេ យួនវាយយើងមួយថ្ងៃប្រាំពីរដងឯណោះ កាប់គេមិនឮស្គរ រលំទៅគេមិន

ឮស្នូរ បើគេវែកព្រៃរកយើង។ អាហ្នឹង ហើយគាត់ៗសម្លុត គាត់សន្ធប់ដី ហើយស្រែកង៉ាង។ ស្រែកដូចដំរីអ៊ីចឹង ថា “អ៊ីចឹងតើបានអញមកអត់ហៅហ្អែងមកហ្នឹង មកគិតការណ៍អីអត់ឯកភាព” ថាអ៊ីចឹង។ ហើយខ្ញុំថាតែគាត់អត់ខឹង ដល់ចប់ខ្ញុំមកកន្លែងវិញ។ ដល់តែមកដល់កន្លែងវិញ ថាអាគេឲ្យក្មេងន៉ែយកពីខ្ញុំទៅបីនាក់ហ្នឹង គេឲ្យក្មេងហ្នឹងមកខ្ញុំ។ ដល់ធ្វើបាយឲ្យហូបមួយសន្ទុះ បានក្មេងហ្នឹងមកដល់។ មកដល់យំ។ “ប្រាប់ថាហ្អែងមកយំធ្វើអី? បើអញមិននៅបបរស៊ីទៅ។ ថា អត់ទេ តាឲ្យខ្ញុំមកសម្លាប់ពូឯង។ ខ្ញុំអត់សម្លាប់ទេពូឯង។ បើពូឯងឲ្យខ្ញុំទៅសម្លាប់តា ខ្ញុំទៅឥឡូវហ្នឹង។ ថា អត់ទេ កុំចងកម្មចងពៀរ យើងរកកន្លែងរស់”។ អ៊ីចឹង ខ្ញុំក៏យប់ឡើងបបួលគ្នារត់មកនៅចម្ការកៅស៊ូ ចម្ការអណ្ដូងទាំងអស់ជាមួយគ្នាហ្នឹង។

[១៥:២៣:០៧]

ដល់មកដល់ហ្នឹងទៀត តាជឹម ឲ្យកម្លាំងមជ្ឈិមមួយក្រុម បេពីរដើម អាកា១០ដើម។ ដល់ពេលខ្ញុំមកពីកំពង់ធំវិញ កងពលធំឈ្មោះ តាជុំ។ តាជុំ ឮខ្ញុំមកពីកំពង់ធំ គាត់មកសម្ភាសសួរថា “មិត្តឯងមកកំពង់ធំរកអីបានស៊ី? ធ្វើអីបាន?” ខ្ញុំថា អត់បានទេ។ អីប្រមូលៗ បានគល់ចេកក៏ប្រមូល មិនបានទេស្រូវធ្វើបានប្រមាណម្ភៃស្លឹក គ្រាន់តែហូប។ យួននៅត្រៀមចាំនៅហ្នឹង យើងដកថយមកហើយ។ អត់មានអីហូបទេ។ ហូបតែស្លឹកឈើហើយនិងត្រីហ្នឹង។ ហើយស្រាប់តែកងតាជឹមគេទៅ ឃើញខ្ញុំនៅអង្គុយនិយាយជាមួយ តាជុំ គេលើកបេលីលើ-កគេទាំងពីរនាក់ ហើយអាពួកអាកាគេអត់អី គេនៅស្ពាយ។ ហើយខ្ញុំនឹកឃើញថា បើហ្អែងបាញ់អញ បាញ់ទៅ បើមេនៅហ្នឹងហើយ ឯងហ៊ាន។ ហើយទ័ពតាជុំ កងពលធំ គាត់ចេញទៅណាបន្តិច សុទ្ធតែមនុស្ស។ ខ្ញុំអត់ភ័យ អត់ខ្លាច។ រឿងហ្នឹងវាៗអ៊ីចឹង។ ហើយពីហ្នឹងក៏ឡើងភ្នំដងរែក។ ខែ៧ ឆ្នាំ៨០ ខែ៧ ឡើងដល់លើភ្នំដងរែក គេឲ្យមកសួរ មកដកកាំភ្លើងខ្ញុំ។ ថាខ្ញុំរត់ចោលជួរអ៊ីចឹង។ ដល់អ៊ីចឹងខ្ញុំថា “ហ្អែង អញអត់ឲ្យទេ បើតាជឹម មកដកបានអញឲ្យ ព្រោះកម្លាំងមកពេញប្រទេស កំពុងតែវាយគ្នា ហ្អែងៗមកយកកាំភ្លើងអញ។ អញបានអីច្បាំង។ ដល់ថាអ៊ីចឹងទៅប្រាប់ តាជឹមៗ អត់ហ៊ានមកយក។

**ស៖** បាទ សូមអរគុណ លោក ឯក ហឿន ។ ខ្ញុំគិតថា ខ្ញុំអាចស្ដាប់យល់បានហើយ។ អ៊ីចឹង ខ្ញុំចង់សួរបន្ថែមថា ពីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបានបញ្ជាក់ហើយថាលោកមិនហ៊ានប៉ះពាល់គឺគោរពតាម ពេជ្រ ជឹម ណាស់។ ហើយចុងក្រោយ បានន័យថាក្រោយពី៧៩នេះ បានលោកមានទំនាស់ជាមួយ ពេជ្រ ជឹម។ ខ្ញុំចង់សួរលោកថា តើលោកមានចំណុចដែលធ្វើឲ្យលោកមិនសប្បាយចិត្ត ឬក៏

អាក់អន់ចិត្តជាមួយនឹង ពេជ្រ ជឹម ហ្នឹង ត្រង់ចំណុចអីដែលៗសំខាន់ជាងគេ ដែលអាចកើតឲ្យទៅជារឿងរកសម្លាប់គ្នាបែបនេះ? លោកអាចបញ្ជាក់ពីបញ្ហាសំខាន់ដែលកើតមានឡើងបានទេ?

[១៥:២៥:៤៥]

**ផ៖** បាទ បាន។ ចំណុចទី១ គាត់ហៅខ្ញុំទៅប្រជុំ ឲ្យកាប់ចម្ការ។ ខ្ញុំថាកាប់អត់ទាន់បានទេ យួនកំពុងវែកព្រៃរកយើង កាច់គេមិនឮសូរ ឲ្យតែសភាពការណ៍ស្រួល ខ្ញុំធានា។ ស្រាប់គាត់សន្ទប់ដីស្រែកង៉ាងដូចដំរីអីចឹង ហើយគាត់ឲ្យក្មេងមកសម្លាប់ខ្ញុំ។ ហើយក្មេងអត់សម្លាប់ បាត់ខ្ញុំ គេឲ្យទ័ពទៅតាមដល់ចម្ការកៅស៊ូចម្ការដូង មករកសម្លាប់ខ្ញុំទៀត កងតាជឹម ហ្នឹង – កងតាជឹម ហ្នឹងគេការពារ តាជឹមហ្នឹង។ ហ្នឹងស្ដីឲ្យខ្ញុំ ជំនាស់តែរឿងគាត់សម្លាប់--

**ស៖** លោកៗអាចបញ្ជាក់បានទេ និយាយពីចម្ការដូង ចម្ការកៅស៊ូចម្ការដូងហ្នឹងនៅឯណា?

**ផ៖** នៅកំពង់ចាម នៅស្រុកស្ទឹងត្រង់ មិនដឹងស្ទឹងត្រង់ ព្រែកប្រសព្វអីទេនេះ ស្ទឹងត្រង់អីចឹងហើយ ស្ទឹងត្រង់។

**ស៖** ក្នុងឆ្នាំណាដែរ លោកអាចបញ្ជាក់បានទេ?

**ផ៖** ឆ្នាំដែល តាជឹម គំរាមហ្នឹង ឆ្នាំ៨០ ខែ០១ ដែលខ្ញុំរត់មកដល់ចម្ការកៅស៊ូ ចម្ការដូងនៅឆ្នាំ៨០ ខែ០២ហើយ ដើរកាត់ព្រៃមួយខែបានដល់។

**ស៖** បាទ សូមអរគុណ។ ចុះឥឡូវលោកដកចេញនូវអ្វីដែលជាទំនាស់របស់លោកនៅពេលដែលតាជឹម ប្រាប់ឲ្យទៅកាប់ដើមឈើ ហើយលោកបដិសេធ។ ហើយលោកពិនិត្យទៅលើអត្តចរិតរបស់តាជឹមជាទូទៅ ជាពិសេសក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើលោកយល់យ៉ាងម៉េចដែរចំពោះអាកប្បកិរិយា ឬក៏ប្រព្រឹត្តអីទាំងឡាយរបស់ តាជឹម ក្នុងនាមជាកម្មាភិបាលម្នាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ផ៖** បាទ ជម្រាប កាលគាត់នៅក្នុងស្រុកមានអី មានហូបមានចុក គាត់អត់មានខឹងសម្បាអីជាមួយអ្នកណាទេ។ ដល់តែអត់ស៊ី ហើយប្រើអត់បាន គាត់ខឹងឆ្លេងហ្នឹង។

[១៥:២៧:៤៧]

**ស៖** បាទ សម្រាប់លោកឥឡូវនេះ លោកមានការអន់ចិត្ត ឬក៏ខឹងនឹង ពេជ្រ ជឹម ទេ?

**ផ៖** បាទ ខឹងតែពេលដែលគេរកសម្លាប់ហ្នឹង តែឥឡូវអត់មានខឹង មានស្អប់ទេ។

**ស៖** តើលោកមកដល់ឥឡូវនេះលោកមានទំនាក់ទំនងគ្នា ឬក៏រាប់អានទាក់ទងគ្នាជាធម្មតាទេ?

**ឆ៖** បាទ ថ្ងៃមុន៣ថ្ងៃហើយគាត់មកធ្វើបុណ្យក្ឆួយ ចូលទៅដល់ផ្ទះខ្ញុំ។ គាត់ចូលទៅដល់ លើកកាតាបគាត់ដាក់លើគ្រែខ្ញុំ ហើយខ្ញុំនៅអង្គុយហ្នឹង គាត់ថា ហ្អែងអ្នកទៅភ្នំពេញដែរ? ខ្ញុំថា ខ្ញុំទៅ ប៉ុន្តែមានគេប្ដឹង អាណាប្ដឹងអញថាអញអនុស្រុក អាហ្អែងហ្នឹងហើយអនុស្រុក ហើយហ្អែងស៊ីបាយហើយយកបាយលាបមាត់ពពែ។ ហ្អែងអនុស្រុក ហ្អែងមកថាអញអនុស្រុក ចុះអញធ្វើការចន្លោះត្រង់ណា? ហើយវាថា វាសារភាពថា៖ វាអត់ថាអ៊ីចឹងទេ វាថាអាហឿន ហ្នឹងវាជាបងប្អូនវា ត្រូវជាប្អូនថ្លៃទៀត វាអត់មានដែលមានធ្វើការអីទេ វាសារភាពតែប៉ុណ្ណឹង។ ប៉ុន្តែខ្ញុំខឹងទៀតហើយ។

**ស៖** សូមទោស ខ្ញុំអត់ស្ដាប់អត់ទាន់អំមិញ កន្លែងនិយាយថា "ហ្អែងអនុស្រុក" លោកចង់និយាយសំដៅលើអ្នកណាគេ?

**ឆ៖** បាទ និយាយសំដៅ តាជឹម ហ្នឹង។ តាជឹម គាត់មកជួបខ្ញុំ ហើយសួរខ្ញុំថា ហ្អែងដែលទៅភ្នំពេញទេ? ខ្ញុំថាទៅ ទើបនឹងមក។ ហើយខ្ញុំថា "ខ្ញុំទៅហ្នឹងបារាំងថា ឮថាមានគេប្ដឹងថាខ្ញុំអនុស្រុក" ហើយខ្ញុំថា ខ្ញុំអនុស្រុកត្រង់ណា ចាំមើលខ្ញុំបញ្ជាក់ជូន៖ ទី១ យាយខុម, ទី២ តាជឹម, ទី៣ តាចាយ, ទី៤ សោម ដន ប្រធានមន្ទីរ ហើយខ្ញុំអនុស្រុកត្រង់ណា!" ដល់អ៊ីចឹង -- ភ្លេចអស់ហើយ និយាយថាម៉េចទេ។ ចប់ហើយ។

[១៥:២៩:៥៤]

**ស៖** បាទ សូមអរគុណ។ អ៊ីចេះលោកមានជជែកគ្នាខ្លាំងទេ នៅពេលដែលលោកថា ពេលតាជឹម ទៅធ្វើបុណ្យក្ឆួយហ្នឹង?

**ឆ៖** បាទ អត់មានជជែកទេ គ្រាន់តែខ្ញុំថាឲ្យ ថាឲ្យតែប៉ុណ្ណឹងទេ ហើយគាត់សារភាពថា គាត់អត់មានថាអនុ ថាអីទេ គាត់ថាអាហ្នឹងវាជាបងប្អូនគាត់ អត់មាននាទីធ្វើការងារអីក្នុងមន្ទីរស្រុកហ្នឹងទេ មានតែ -- អត់មាននាទីអីទេ ថាតែប៉ុណ្ណឹង ជជែកតែប៉ុណ្ណឹង ហើយលែងនិយាយទៅ គាត់មកថ្ងៃ ព្រឹកមិញគាត់មកចូលទៀត រាប់រកធម្មតា អត់អី។

**ស៖** បាទ សូមអរគុណ លោក ឯក ហឿន។

**លោក គង់ សំអុន៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសវនាការនៅថ្ងៃនេះ ឃើញថាប្រព្រឹត្តបានចប់មុនពេលកំណត់ ហើយក៏

ដល់ពេលឈប់សម្រាកហើយដែរ ព្រោះសវនាការថ្ងៃនេះមិនមានសាក្សីបម្រុងទេ។ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៨ ខែឧសភា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃចន្ទ ទី១៨ ខែឧសភា ឆ្នាំ ២០១៥ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-986 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

សូមអរគុណ លោក ឯក ហឿន ដែលបានចំណាយពេលវេលាដ៏មានតម្លៃផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ដល់អង្គជំនុំជម្រះសាលាដំបូងក្នុងឋានៈជាសាក្សីក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ។ ហើយសាក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ ការផ្ដល់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ លោកអាចសម្រាកបានហើយ ហើយសូមលោកមានសុខភាពល្អមាន -- បានទទួលបានសេចក្ដីសុខសេចក្ដីចម្រើន និងជួបតែសំណាងល្អ។ លោក ហឿន!

**លោក ឯក ហឿន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអាចសម្រាកបានហើយ លោក ហឿន។

**លោក ឯក ហឿន៖**

បាទ។ សូមជូនពរអស់លោក សូមឲ្យលោកមានសិរីសួស្ដី ជ័យមង្គលគ្រប់បែបយ៉ាង កុំឲ្យ--

**ប្រធានអង្គជំនុំ៖**

បាទ អរគុណបាទ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការវិញនៅព្រឹកថ្ងៃចន្ទ ទី១៨ ខែឧសភា ឆ្នាំ ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៣២ នាទី)*